United Nations
Educational, Scientific and
Cultural Organization

# ការអប់រំភាពជាពលរដ្ឋសកល

## ប្រធានបទ និង វត្ថុបំណងនៃការសិក្សា



បោះពុម្ពនៅឆ្នាំ២០១៥ដោយអង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (UNESCO)
៧ Place de Fontenoy, ៧៥៣៥២ ប៉ារីស ០៧ SP សាធារណរដ្ឋបារាំង
© UNESCO ២០១៥
ISBN 978-92-3-100102-4

សៀវភៅនេះអាចរកមើលបាននៅលើគេហទំព័ររបស់ Open Access នៅក្រោមអាជ្ញាបណ្ណ Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) (http:creativecommons.org/licenses/by-sa/3.0/igo/)។ ពេលប្រើប្រាស់ខ្លឹមសារនៅក្នុងសៀវភៅនេះ អ្នកប្រើប្រាស់យល់ព្រមទទួលយកលក្ខខណ្ឌរបស់ Open Access Repository នៃអង្គការយូណេស្កូ។ សូមចូលមើលគេហទំព័រ (http://www.unesco.org/open-access/terms-use-ccbysa-en)។

ការប្រើប្រាស់ឈ្មោះ និងការបង្ហាញសម្ភារៈទាំងឡាយនៅក្នុងសៀវភៅនេះ មិនបានបង្ហាញអំពីទស្សនៈណាមួយរបស់អង្គការយូណេស្កូ ទាក់ទងទៅនឹងតួនាទីស្របច្បាប់នៃប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬទាក់ទងទៅនឹងការកំណត់ព្រំដែននៃខណ្ឌសីមារបស់ខ្លួនឡើយ។

គំនិតនិងទស្សនៈដែលបង្ហាញនៅក្នុងសៀវភៅនេះ គឺជារបស់អ្នកនិពន្ធតែប៉ុណ្ណោះ។ គំនិតនិងទស្សនៈទាំងអស់នេះមិនបង្ហាញពីគោលជំហររបស់អង្គការយូណេស្កូ ដែលនឹងមិនមានការទទួលខុសត្រូវណាមួយឡើយ។

រូបភាពក្របមុខ ៖ © Shutterstock/mama_mia
រូបភាពដោយ ៖ pp.12-13, p.20, pp.44-45 © Shutterstock/Danylo Staroshchuk
រចនាសៀវភៅដោយ ៖ Aurelia Mazoyer

បោះពុម្ពដោយអង្គការយូណេស្កូ
បោះពុម្ពនៅប្រទេសបារាំង

# ការអប់រំភាពជាពលរដ្ឋសកល

## ប្រធានបទ និង វត្ថុបំណងនៃការសិក្សា

## មាតិកា

**កថាមុខ**
**សេចក្តីថ្លែងអំណរគុណ**
**បញ្ជីអក្សរកាត់**
**១. សេចក្តីផ្តើម**
១.១. តើអ្វីទៅជាការអប់រំភាពជាពលរដ្ឋសកល?
១.២. តើសៀវភៅណែនាំនេះត្រូវបានអភិវឌ្ឍឡើងដោយរបៀបណា?
១.៣. តើសៀវភៅណែនាំនេះសម្រាប់អ្នកណា និងអាចត្រូវបានប្រើប្រាស់ដោយរបៀបណា?

**២. សេចក្តីណែនាំ ៖ ខ្លឹមសារសម្រាប់ការសិក្សាការអប់រំភាពជាពលរដ្ឋសកល**
២.១. បណ្តុំនៃការសិក្សា
២.២. លទ្ធផលសិក្សា
២.៣. គុណសម្បត្តិសិក្សា
២.៤. ប្រធានបទ
២.៥. វត្ថុបំណង
២.៦. ពាក្យគន្លឹះ
២.៧. តារាងណែនាំ

**៣. ការអនុវត្តការអប់រំភាពជាពលរដ្ឋសកល**
៣.១. តើត្រូវបញ្ជ្រាបប្រធានបទនេះទៅក្នុងប្រព័ន្ធអប់រំដោយរបៀបណា?
៣.២. តើត្រូវបង្រៀនប្រធានបទនេះនៅក្នុងថ្នាក់រៀនដោយរបៀបណា?
៣.៣. តើត្រូវវាយតម្លៃលទ្ធផលសិក្សាដោយរបៀបណា?

**៤. ឧបសម្ព័ន្ធ**
ឧបសម្ព័ន្ធទី១ ៖ ការអនុវត្តនិងប្រភពធនធាននៅក្នុងគេហទំព័រជ្រើសរើស
ឧបសម្ព័ន្ធទី២ ៖ គន្ធនិទ្ទេស
ឧបសម្ព័ន្ធទី៣ ៖ បញ្ជីរាយនាមតំបន់ដែលបានធ្វើតេស្តអ្នកចូលរួម

## បញ្ជីរាយនាមតារាង

តារាង ក ៖ សេចក្តីណែនាំរួម

តារាង ខ ៖ ប្រធានបទ និង វត្ថុបំណងនៃការសិក្សាលម្អិត

ខ.១. ប្រធានបទ ៖ ប្រព័ន្ធនិងរចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល

ខ.២. ប្រធានបទ ៖ បញ្ហាដែលប៉ះពាល់ទៅដល់អន្តរកម្ម និងទំនាក់ទំនងរបស់សហគមន៍ នៅក្នុងកម្រិតមូលដ្ឋាន ជាតិ និងសកល

ខ.៣. ប្រធានបទ ៖ ឥទ្ធិពលនៃការសន្ទត់ និងថាមពលនៃអំណាច

ខ.៤. ប្រធានបទ ៖ កម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណ

ខ.៥. ប្រធានបទ ៖ សហគមន៍ផ្សេងៗគ្នាដែលមនុស្សរស់នៅ និងរបៀបដែលសហគមន៍និងមនុស្សទាំងនេះត្រូវបានតភ្ជាប់

ខ.៦. ប្រធានបទ ៖ ភាពខុសគ្នា និងការគោរពចំពោះពិពិធភាព

ខ.៧. ប្រធានបទ ៖ វិធានការដែលអាចត្រូវបានធ្វើឡើងជាបុគ្គលនិងជាសមូហភាព

ខ.៨. ប្រធានបទ ៖ ឥរិយាបថទទួលខុសត្រូវប្រកបដោយសីលធម៌

ខ.៩. ប្រធានបទ ៖ ការចូលរួម និង ការចាត់វិធានការ

តារាង គ ៖ ពាក្យគន្លិះ

## បញ្ជីរាយនាមប្រអប់

ប្រអប់ទី១ ៖ សមាសធាតុទស្សនសំខាន់ៗនៃការអប់រំភាពជាពលរដ្ឋសកល

ប្រអប់ទី២ ៖ របៀបប្រើប្រាស់សេចក្តីណែនាំបែបគរុកោសល្យនៅកម្រិតជាតិ

ប្រអប់ទី៣ ៖ លទ្ធផលសិក្សាសំខាន់ៗ

ប្រអប់ទី៤ ៖ គុណសម្បត្តិអ្នកសិក្សាសំខាន់ៗ

ប្រអប់ទី៥ ៖ ប្រធានបទ

## អារម្ភកថា

អង្គការយូណេស្កូបានលើកកម្ពស់ការអប់រំភាពជាពលរដ្ឋសកល ចាប់តាំងពីការដាក់ចេញនូវគម្រោងផែនការ «ការផ្តួចផ្តើមដំបូងនៃការអប់រំសកល (GEFI)» របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅក្នុងឆ្នាំ២០១២ ដែលបានធ្វើឱ្យការជម្រុញភាពជាពលរដ្ឋសកល ទៅជាអាទិភាពនៃការអប់រំមួយ នៅក្នុងចំណោមអាទិភាពនៃការអប់រំទាំងបី។

សៀវភៅដែលមានចំណងជើងថា «ការអប់រំភាពជាពលរដ្ឋសកល ៖ ប្រធានបទ និង វត្ថុបំណងនៃការសិក្សា» គឺជាសៀវភៅណែនាំបែបគរុកោសល្យដំបូងបង្អស់របស់អង្គការយូណេស្កូ ស្តីអំពីការអប់រំភាពជាពលរដ្ឋសកល។ សៀវភៅនេះគឺជាលទ្ធផលនៃការស្រាវជ្រាវ និងដំណើរការនៃការពិគ្រោះយោបល់យ៉ាងមធ្យ័ត ជាមួយអ្នកជំនាញ ដែលមកពីផ្នែកផ្សេងៗគ្នាជាច្រើននៅលើពិភពលោក។ សៀវភៅណែនាំនេះត្រូវបានដកចេញស្រង់ពីសៀវភៅរបស់អង្គការយូណេស្កូ ដែលមានចំណងជើងថា «ការអប់រំភាពជាពលរដ្ឋសកល ៖ ការរៀបចំអ្នកសិក្សាសម្រាប់បញ្ហាប្រឈមទាំងឡាយនៃសតវត្សរ៍ទី២១»។ សៀវភៅណែនាំនេះក៏ដកស្រង់ចេញពីលទ្ធផលនៃកិច្ចប្រជុំចម្បងៗរបស់អង្គការយូណេស្កូ ស្តីអំពីការអប់រំភាពជាពលរដ្ឋសាកលផងដែរ ដែលរួមមាន ៖ កិច្ចពិគ្រោះយោបល់បច្ចេកទេសស្តីអំពីការអប់រំភាពជាពលរដ្ឋសកល ដែលត្រូវបានធ្វើឡើងនៅខែកញ្ញា ឆ្នាំ២០១៣ និងវេទិកាអង្គការយូណេស្កូលើកទីមួយស្តីអំពីការអប់រំភាពជាពលរដ្ឋសកល ដែលត្រូវបានប្រារព្ធធ្វើឡើងនៅខែធ្នូ ឆ្នាំ២០១៣ និងវេទិកាលើកទីពីរដែលត្រូវបានប្រារព្ធធ្វើឡើងនៅខែមករា ឆ្នាំ២០១៥។ មុនពេលបញ្ចប់ សៀវភៅនេះត្រូវបានយកទៅធ្វើតេស្តសាកល្បងដោយអ្នកអប់រំ នៅតាមប្រទេសជ្រើសរើសមួយចំនួន នៅគ្រប់តំបន់ទាំងអស់ ដើម្បីធានាថាសៀវភៅនេះ មានភាពសមស្របនៅក្នុងបរិបទភូមិសាស្ត្រ និងសង្គមវប្បធម៌ផ្សេងៗគ្នា។

បន្ទាប់ពីសម្រេចបានការងារជាមូលដ្ឋានរបស់អង្គការយូណេស្កូ ដើម្បីបញ្ជាក់អំពីភាពច្បាស់លាស់ផ្នែកទស្សនៃការអប់រំភាពជាពលរដ្ឋសកល និងដើម្បីផ្តល់ជាគោលនយោបាយ និងទិសដៅផ្នែកកម្មវិធី សៀវភៅនេះត្រូវបានអភិវឌ្ឍឡើង ជាការឆ្លើយតបទៅនឹងតម្រូវការរបស់រដ្ឋជាសមាជិក សម្រាប់ជាសេចក្តីណែនាំរួមមួយ នៅក្នុងការបញ្ចូលការអប់រំភាពជាពលរដ្ឋសកល ទៅក្នុងប្រព័ន្ធអប់រំរបស់ពួកគេ។ សៀវភៅនេះផ្តល់ឱ្យនូវការណែនាំទាំងឡាយសម្រាប់ការបកប្រែទស្សនាទាននៃការអប់រំភាពជាពលរដ្ឋសកល ទៅជាប្រធានបទដែលអាច

អនុវត្តបាននិងសមស្របទៅតាមវ័យជាក់ស្តែង និងទៅជាវត្ថុបំណងនៃការសិក្សា នៅក្នុងរបៀបមួយដែលអនុញ្ញាតដល់ការសម្រួលចូលទៅក្នុងបរិបទមូលដ្ឋាន។ សៀវភៅនេះគឺជាប្រភពធនធានមួយសម្រាប់អ្នកអប់រំ អ្នកអភិវឌ្ឍកម្មវិធីសិក្សា អ្នកបណ្តុះបណ្តាល ក៏ដូចជាអ្នកធ្វើគោលនយោបាយ។ ប៉ុន្តែ សៀវភៅនេះក៏មានប្រយោជន៍ផងដែរសម្រាប់អ្នកអប់រំផ្សេងទៀតនៅក្នុងទម្រង់នៃការអប់រំក្រៅប្រព័ន្ធ និងការអប់រំក្រៅផ្លូវការ។

នៅក្នុងពេលវេលាមួយ ដែលសហគមន៍អន្តរជាតិ ត្រូវបានជម្រុញឱ្យកំណត់នូវសកម្មភាព ដើម្បីលើកកម្ពស់សន្តិភាព សុខុមាលភាព វិបុលភាព និងនិរន្តរភាព សៀវភៅរបស់អង្គការយូណេស្កូថ្មីមួយនេះ ផ្តល់ឱ្យនូវការណែនាំដើម្បីជួយរដ្ឋជាសមាជិក នៅក្នុងការធានាឱ្យបានថាអ្នកសិក្សាគ្រប់វ័យនិងគ្រប់ប្រភេទទាំងអស់ អាចអភិវឌ្ឍខ្លួនឱ្យទៅជាពលរដ្ឋសកល ដែលប្រកបដោយចំណេះដឹង ការត្រិះរិះពិចារណា ទំនាក់ទំនងល្អក្នុងសង្គម សីលធម៌ និងការចូលរួម។

បណ្ឌិត ជៀង តាំង<br>
អគ្គនាយករងទទួលបន្ទុកអប់រំ

# សេចក្តីថ្លែងអំណរគុណ

សៀវភៅណែនាំបែបគរុកោសល្យ ដែលមានចំណងជើងថា«ការអប់រំភាពជាពលរដ្ឋសកល ៖ ប្រធានបទ និង គោលបំណងនៃការសិក្សា» ត្រូវបានផ្តល់បេសកកម្មដោយអង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌។ នៅក្រោមការចង្អុលបង្ហាញរួមរបស់លោក Soo Hyang Choi ដែលជាប្រធាននាយកដ្ឋាននៃការបង្រៀន ការរៀន និងខ្លឹមសារនៃអង្គការយូណេស្កូ ការរៀបចំសៀវភៅនេះត្រូវបានសម្របសម្រួលដោយ Chris Castle, Lydia Ruprecht និង Theophania Chavatzia ដែលធ្វើការនៅក្នុងផ្នែកសុខភាព និងការអប់រំភាពជាពលរដ្ឋសកល។

Dina Kiwan អនុសាស្ត្រាចារ្យនៅឯសកលវិទ្យាល័យអាមេរិកាំង ក្នុងទីក្រុង Beirut និង Mark Evans អនុសាស្ត្រាចារ្យនៅឯសកលវិទ្យាល័យតូរុនតូ (University of Toronto) គឺជាអ្នកនិពន្ធសៀវភៅនេះ។ Kathy Attawell និង Jane Kalista ដែលជាទីប្រឹក្សាឯករាជ្យ គឺជាបណ្ណាធិការដែលបានត្រួតពិនិត្យសេចក្តីព្រាងជាច្រើននៃសៀវភៅនេះ។

អង្គការយូណេស្កូបានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាអ្នកជំនាញ (EAG) ទៅលើការអប់រំភាពជាពលរដ្ឋសកល ដែលត្រូវបានប្រព្រឹត្តធ្វើឡើងនៅក្នុងទីក្រុងប៉ារីស នៅខែមិថុនា ឆ្នាំ២០១៤ និងសូមថ្លែងអំណរគុណទៅដល់អ្នកទាំងអស់ ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំ និងដែលបានផ្តល់យោបល់ទៅលើសេចក្តីព្រាងជាច្រើននៃសៀវភៅនេះ។ អ្នកទាំងនោះរួមមាន ៖ Abbie Raikes (ការិយាល័យកណ្តាលយូណេស្កូ) Albert Motivans (វិទ្យាស្ថានស្ថិតិនៃយូណេស្កូ) Alexander Leicht (ការិយាល័យកណ្តាលយូណេស្កូ) Carolina Ibarra (សកលវិទ្យាល័យ de los Andes នៃប្រទេសកូឡុំប៊ី) Dakmara Georgescu (ការិយាល័យយូណេស្កូក្នុងទីក្រុងបីរុត) Carolee Buckler (ការិយាល័យកណ្តាលយូណេស្កូ) Dirk Hastedt (សមាគមអន្តរជាតិសម្រាប់ការវាយតម្លៃសមិទ្ធផលនៃការអប់រំ) Felisa Tibbitts (នាយកប្រតិបត្តិនិងជាស្ថាបនិកមួយរូបនៃសមាគមនៃការអប់រំសិទ្ធិមនុស្ស) Gwang-Chol Chang (ការិយាល័យយូណេស្កូក្នុងទីក្រុងបាំងកក) Hyojeong Kim (មជ្ឈមណ្ឌលអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការអប់រំការយល់ដឹងជាអន្តរជាតិ) Injairu Kulundu (អង្គការអែកធីវេតសម្រាប់ការផ្លាស់ប្តូរ) Jeongmin Eom (មជ្ឈមណ្ឌលអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការអប់រំការយល់ដឹងជាអន្តរជាតិ) Ji Min Cho (វិទ្យាស្ថានកូរ៉េសម្រាប់ការ

អភិវឌ្ឍកម្មវិធីសិក្សានិងការវាយតម្លៃ) Jinhee Kim (វិទ្យាស្ថានកូរ៉េសម្រាប់ការអភិវឌ្ឍការអប់រំ) Jun Morohashi (ការិយាល័យយូណេស្កូប្រចាំប្រទេសហៃទី) Kate Anderson Simons (ក្រុមការងារពិសេសសម្រាប់វាស់ស្ទង់ការសិក្សានៃវិទ្យាស្ថានប្រូកឃីង) Koji Miyamoto (អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍) Miguel Silva (វិទ្យាស្ថានជើងឥន្ទ្រជនៃក្រុមប្រឹក្សាអឺរ៉ុប) Muhammad Faour (សកលវិទ្យាល័យយ៉ក) Onemus Kiminza (ក្រសួងអប់រំនៃប្រទេសកេនយ៉ា) Ralph Carstens (សមាគមអន្តរជាតិសម្រាប់ការវាយតម្លៃសមិទ្ធផលនៃការអប់រំ) Stephanie Knox Cubbon (គ្រូបង្រៀនគ្មានព្រំដែន) Tony Jenkins (សកលវិទ្យាល័យតូឡេដូ) Werner Wintersteiner (សកលវិទ្យាល័យ Klagenfurt) Wing-On Lee (វិទ្យាស្ថានជាតិអប់រំនៃប្រទេសសឹង្ហបូរី) និង Yolanda Leyvas (វិទ្យាស្ថានជាតិសម្រាប់ការវាយតម្លៃការអប់រំនៃប្រទេសមិចសិក)។

យើងក៏សូមថ្លែងអំណរគុណដល់អ្នកផ្តល់យោបល់ និងការចូលរួមជាសំណេរផ្សេងៗទៀតដែលរួមមាន ៖ Akemi Yonemura (ការិយាល័យយូណេស្កូក្នុងទីក្រុងដាការ) Alié Salmon (ការិយាល័យយូណេស្កូក្នុងទីក្រុងបាំងកក) Amina Hamshari (ការិយាល័យកណ្តាលយូណេស្កូ) Anantha Kumar Duraiappah (វិទ្យាស្ថានមហាត្មៈគន្ធីសម្រាប់ការអប់រំអំពីសន្តិភាពនិងនិរន្តភាព) Christina Von Furstenberg (ការិយាល័យកណ្តាលយូណេស្កូ) Hegazi Idris Ibrahim (ការិយាល័យយូណេស្កូក្នុងទីក្រុងបីរុត) Hugue Charnie Ngandeu Ngatta (ការិយាល័យកណ្តាលយូណេស្កូ) Musafir Shankar (វិទ្យាស្ថានមហាត្មៈគន្ធីសម្រាប់ការអប់រំអំពីសន្តិភាពនិងនិរន្តភាព) Nabila Jamshed (វិទ្យាស្ថានមហាត្មៈគន្ធីសម្រាប់ការអប់រំអំពីសន្តិភាពនិងនិរន្តភាព) និង Opertti Renato (ការិយាល័យអន្តរជាតិសម្រាប់ការអប់រំ)។ អ្នកផ្តល់យោបល់កែលម្អរួមមាន ៖ Margaret Sinclair (អង្គការការពារការអប់រំក្នុងតំបន់អសន្តិសុខនិងជម្លោះ) និងការចូលរួមដោយផ្ទាល់មាត់ពីអ្នកចូលរួមផ្សេងទៀត នៅក្នុងវេទិកាយូណេស្កូលើកទីពីរស្តីអំពីការអប់រំភាពជាពលរដ្ឋសកល ដែលត្រូវបានប្រព្រឹត្តធ្វើឡើងនៅថ្ងៃទី២៨-៣០ ខែមករា ឆ្នាំ២០១៥។

យូណេស្កូក៏សូមថ្លែងអំណរគុណដល់អ្នកទាំងឡាយ ដែលបានចូលរួមនៅក្នុងដំណើរការសាកល្បង ដែលបានផ្តល់យោបល់ត្រឡប់ដ៏មានប្រយោជន៍។ អ្នកទាំងនោះរួមមាន ៖ មជ្ឈមណ្ឌលអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការអប់រំការយល់ដឹងជាអន្តរជាតិ ដែលបានជួយសម្របសម្រួលយោបល់ត្រឡប់ពីគ្រូបង្រៀនកូរ៉េ, Fadi Yarak (ក្រសួងអប់រំនិងឧត្តមសិក្សាដែលបាន

សម្របសម្រួលយោបល់ត្រឡប់ពីមន្ត្រីអប់រំ) Marie-Christine Lecompte (អ្នកសម្របសម្រួលកម្មវិធី ASPnet ក្នុងប្រទេសកាណាដា) Olivia Flores (អ្នកសម្របសម្រួលកម្មវិធី ASPnet ក្នុងប្រទេសមិចសិក) និង Rosie Agoi (អ្នកសម្របសម្រួលកម្មវិធី ASPnet ក្នុងប្រទេសអ៊ុយហ្គាន់ដា) និងរួមទាំងសាលា គ្រូបង្រៀន និងសិស្សនៅក្នុងប្រទេសទាំងនេះ ដែលបានចូលរួមនៅក្នុងដំណើរការធ្វើតេស្តសាកល្បង។

នៅទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ Chantal Lyard ដែលបានផ្តល់ការទ្រទ្រង់ផ្នែកត្រួតពិនិត្យ Aurélia Mazoyer ដែលបានរចនាទម្រង់សៀវភៅ Martin Wickenden និង Nanna Engebretsen ដែលបានផ្តល់ការទ្រទ្រង់ផ្នែកទំនាក់ទំនងសម្រាប់ការបោះពុម្ពសៀវភៅនេះ។

# បញ្ជីរាយនាមពាក្យកាត់

| | |
|---|---|
| APCEIU | មជ្ឈមណ្ឌលអាស៊ីប៉ាស៊ីហ្វិកសម្រាប់ការអប់រំការយល់ដឹងជាអន្តរជាតិ |
| ASPnet | បណ្ដាញគម្រោងសាលារៀន |
| EAG | ក្រុមប្រឹក្សាជំនាញ |
| ECOWAS | សហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិច |
| ESC | ការអប់រំសម្រាប់សាមគ្គីភាពសង្គម |
| ESD | ការអប់រំសម្រាប់ការអភិវឌ្ឍជានិរន្ត |
| GCED | ការអប់រំភាពជាពលរដ្ឋសកល |
| GEFI | ការផ្ដួចផ្ដើមដំបូងសម្រាប់ការអប់រំជាសកល (របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ) |
| GIZ | សង្គមអាលឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ |
| HIV/AIDS | មេរោគអេដស៍ |
| HQ | ការិយាល័យកណ្ដាល |
| IBE | ការិយាល័យអន្តរជាតិសម្រាប់ការអប់រំ (យូណេស្កូ) |
| ICT | បច្ចេកវិជ្ជាព័ត៌មាននិងទំនាក់ទំនង |
| IEA | សមាគមអន្តរជាតិសម្រាប់ការវាយតម្លៃសមិទ្ធិផលនៃការអប់រំ |
| KEDI | វិទ្យាស្ថានកូរ៉េសម្រាប់ការអភិវឌ្ឍការអប់រំ |
| KICE | វិទ្យាស្ថានកូរ៉េសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សានិងការវាយតម្លៃ |
| LMTF | ក្រុមការងារពិសេសសម្រាប់វាស់ស្ទង់ការសិក្សា |
| LTLT | ការរៀនរួមរស់នៅជាមួយគ្នា |
| MGIEP | វិទ្យាស្ថានមហាត្មៈគន្ធីសម្រាប់ការអប់រំអំពីសន្តិភាពនិងការអភិវឌ្ឍជានិរន្ត |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| OHCHR | ការិយាល័យស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្ស |
| OSCE | អង្គការសម្រាប់សុវត្ថិភាពនិងកិច្ចសហប្រតិបត្តិការក្នុងទ្វីបអឺរ៉ុប |
| ODIHR | ការិយាល័យសម្រាប់ស្ថាប័នប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស |

| | |
|---|---|
| PEIC | ការការពារការអប់រំនៅក្នុងតំបន់អសន្តិសុខនិងជម្លោះ |
| SDGs | គោលដៅអភិវឌ្ឍន៍និរន្តរភាព |
| UIS | វិទ្យាស្ថានយូណេស្កូសម្រាប់ស្ថិតិ |
| UN | អង្គការសហប្រជាជាតិ |
| UK | ព្រះរាជាណាចក្រអង់គ្លេស |
| UNEP | កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ |
| UNESCO | អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ |
| UNICEF | មូលនិធិកុមារអង្គការសហប្រជាជាតិ |

១

# សេចក្តីផ្តើម

## ១.១. តើអ្វីទៅជាការអប់រំភាពជាពលរដ្ឋសកល?

*«ការអប់រំផ្តល់ឱ្យយើងនូវការយល់ដឹងជ្រៅជ្រះមួយ ដែលផ្សាភ្ជាប់យើងជាមួយគ្នាក្នុងនាមជាពលរដ្ឋនៃសហគមន៍សកល និងដែលការប្រឈមរបស់យើងទាំងអស់គ្នាមានទំនាក់ទំនងគ្នា។»*

បាន គីម៉ូន
អគ្គលេខាធិការអង្គការសហប្រជាជាតិ

ទស្សនាទាននៃភាពជាពលរដ្ឋវិវត្តទៅតាមពេលវេលា។ ជាប្រវត្តិសាស្ត្រ ភាពជាពលរដ្ឋមិនត្រូវបានផ្តល់ឱ្យមនុស្សគ្រប់គ្នាទេ។ ឧទាហរណ៍ មានតែបុរសនិងម្ចាស់ទ្រព្យសម្បត្តិតែប៉ុណ្ណោះ ដែលអាចមានសិទ្ធិទទួលបានភាពជាពលរដ្ឋ។[1] នៅក្នុងអំឡុងពេលមួយសតវត្សរ៍កន្លងទៅនេះ មានចលនាសន្សឹមៗមួយ ឆ្ពោះទៅរកការយល់ដឹងជាបរិយាប័ន្នជាងមួយនៃភាពជាពលរដ្ឋ ដែលទទួលឥទ្ធិពលពីការអភិវឌ្ឍនៃសិទ្ធិពលរដ្ឋ នយោបាយ និងសង្គម។[2] ទស្សនបច្ចុប្បន្នស្តីអំពីភាពជាពលរដ្ឋជាតិ ប្រែប្រួលរវាងប្រទេសមួយទៅប្រទេសមួយទៀត ដែលបានបង្ហាញអំពីភាពផ្សេងៗគ្នានៃបរិបទនយោបាយនិងប្រវត្តិសាស្ត្រ នៅក្នុងចំណោមកត្តាផ្សេងៗទៀត។

---

[1] សូមមើលសៀវភៅរបស់ Heater (បោះពុម្ពឆ្នាំ១៩៩០) សៀវភៅរបស់ Ichilov (បោះពុម្ពឆ្នាំ១៩៩៨) និងសៀវភៅរបស់ Isin (បោះពុម្ពឆ្នាំ២០០៩)។

[2] សូមមើលសៀវភៅរបស់ Marshall (បោះពុម្ពឆ្នាំ១៩៥៩)។

ការកើនឡើងនូវពិភពលោកមួយដែលកាន់តែរួមគ្នា បាននាំទៅដល់ការលើកឡើងនូវសំណួរស្តីអំពីថាតើអ្វីដែលបង្កើតបានភាពជាពលរដ្ឋដ៏មានអត្ថន័យមួយ និងថាតើអ្វីដែលជាសមាសធាតុសកលនៃភាពជាពលរដ្ឋ។ ទោះបីជាសញ្ញាណនៃភាពជាពលរដ្ឋដែលមានវិសាលភាពហួសពីភាពជារដ្ឋឯករាជ្យមួយ មិនមែនជារឿងថ្មីក៏ដោយ ក៏ការផ្លាស់ប្តូរទាំងឡាយនៅក្នុងបរិបទសកល (ឧទាហរណ៍ ៖ ការបង្កើតអនុសញ្ញានិងសន្ធិសញ្ញាអន្តរជាតិ ការកើនឡើងនូវអង្គការអន្តរប្រទេស សាជីវកម្ម និងចលនាសង្គមស៊ីវិល និងការអភិវឌ្ឍក្របខណ្ឌសិទ្ធិមនុស្សអន្តរជាតិ) មានឥទ្ធិពលយ៉ាងសំខាន់ទៅលើភាពជាពលរដ្ឋសកល។ ត្រូវមានការទទួលស្គាល់ថាមានការយល់ឃើញផ្សេងៗគ្នាទៅលើទស្សនស្តីអំពីភាពជាពលរដ្ឋសកល។ ភាពខុសគ្នាទាំងនោះរួមមាន វិសាលភាពដែលភាពជាពលរដ្ឋសកលពង្រីកនិងបំពេញបន្ថែមទៅលើភាពជាពលរដ្ឋជាប្រពៃណី ការផ្តល់និយមន័យនៅក្នុងក្របខណ្ឌនៃរដ្ឋឯករាជ្យ ឬវិសាលភាពដែលភាពជាពលរដ្ឋសកល ប្រកួតប្រជែងជាមួយនិងភាពជាពលរដ្ឋជាប្រពៃណី។

ភាពជាពលរដ្ឋសកល[3]សំដៅទៅលើអារម្មណ៍ ដែលថាខ្លួនគឺជាផ្នែកមួយនៃសហគមន៍និងភាពជាមនុស្សជាតិទូទៅនិងទូលំទូលាយជាងមួយ។ វាគូសបញ្ជាក់អំពីការអាស្រ័យគ្នាទៅវិញទៅមក និងការជាប់ពាក់ព័ន្ធគ្នាទៅវិញទៅមកផ្នែកនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌រវាងថ្នាក់មូលដ្ឋាន ជាតិ និងសកល។

ការកើនឡើងនូវការចាប់អារម្មណ៍នៃភាពជាពលរដ្ឋសកល បានជះឥទ្ធិពលទៅលើការកើនឡើងនូវការយកចិត្តទុកដាក់ ទៅលើសមាសធាតុនៃការអប់រំភាពជាពលរដ្ឋ និងមានឥទ្ធិពលទៅលើគោលនយោបាយ កម្មវិធីសិក្សា ការបង្រៀន និងការរៀន។[4] ការអប់រំភាពជាពលរដ្ឋសកលរួមបញ្ចូលសមាសធាតុនៃទស្សនសំខាន់ៗចំនួនបី ដែលមានលក្ខណៈរួមចំពោះនិយមន័យនិងការបកស្រាយផ្សេងៗគ្នា។ សមាសធាតុនៃទស្សនសំខាន់ៗទាំងបីនេះ ចេញមកអំពីការពិនិត្យមើលទៅលើការបោះពុម្ពផ្សាយទាំងឡាយ ក្របខណ្ឌទស្សន វិធីសាស្ត្រ និងកម្មវិធីសិក្សាស្តីអំពីការអប់រំភាពជាពលរដ្ឋសកល ក៏ដូចជាការប្រឹក្សាយោបល់ផ្នែកបច្ចេកទេស

---

[3] សូមអានសៀវភៅរបស់អង្គការយូនីស្កូ (បោះពុម្ពឆ្នាំ២០១៤) «ការអប់រំភាពជាពលរដ្ឋសាកល ៖ ការរៀបចំអ្នកសិក្សាសម្រាប់បញ្ហាប្រឈមនៅក្នុងសតវត្សរ៍ទី២១»។

[4] សូមអានសៀវភៅរបស់ Albala-Bertrand (បោះពុម្ពឆ្នាំ១៩៩៥), សៀវភៅរបស់ Banks (បោះពុម្ពឆ្នាំ២០០៤), សៀវភៅរបស់ Merryfield (បោះពុម្ពឆ្នាំ១៩៩៨), សៀវភៅរបស់ Peters, Britton និង Blee (បោះពុម្ពឆ្នាំ២០០៨)។

និងកិច្ចការនាពេលថ្មីៗនេះរបស់អង្គការយូណេស្កូទាក់ទងនឹងប្រធានបទនេះ។ សមាសធាតុជាទស្សនសំខាន់ៗទាំងនេះផ្អែកទៅលើ និងរួមបញ្ចូលទិដ្ឋភាពទាំងឡាយពីគ្រប់ទម្រង់ទាំងអស់នៃការសិក្សា ៖ ចំណេះដឹង, ចិត្តសង្គម និងឥរិយាបថ។ សមាសធាតុទាំងនេះមានទំនាក់ទំនងគ្នាទៅវិញទៅមក និងត្រូវបានបង្ហាញខាងក្រោម ដែលសមាសធាតុនីមួយៗចង្អុលបង្ហាញទម្រង់នៃការសិក្សា ដែលផ្តោតជាសំខាន់នៅក្នុងដំណើរការនៃការសិក្សា។

ប្រអប់ទី១ ៖ សមាសធាតុទស្សនសំខាន់ៗនៃការអប់រំភាពជាពលរដ្ឋសកល

| ចំណេះដឹង |
|---|
| ដើម្បីទទួលបានចំណេះដឹង ការយល់ដឹង និងការត្រិះរិះពិចារណាអំពីបញ្ហានៅថ្នាក់មូលដ្ឋាន ជាតិ តំបន់ និងសកល និងទំនាក់ទំនងនិងការអាស្រ័យគ្នាទៅវិញទៅមក រវាងប្រទេស និងប្រជាជនផ្សេងៗគ្នា។ |

| ចិត្តសង្គម |
|---|
| ដើម្បីទទួលបាននូវអារម្មណ៍ថាជាផ្នែកមួយនៃមនុស្សជាតិទូទៅ ដោយចែករំលែកនូវតម្លៃការទទួលខុសត្រូវ សេចក្តីអាណិតអាសូរ សាមគ្គីភាព និងការគោរពចំពោះភាពខុសគ្នានិងពិពិធភាព។ |

| ឥរិយាបថ |
|---|
| ធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវ នៅថ្នាក់មូលដ្ឋាន ជាតិ និងសកល ដើម្បីទទួលបាននូវពិភពលោក ដែលប្រកបដោយសន្តិភាពនិងនិរន្តរភាពជាងមួយ។ |

ការអប់រំភាពជាពលរដ្ឋសកល មានគោលបំណងដើម្បីសម្រេចឱ្យបាននូវការកែទម្រង់ដើម្បីកសាងចំណេះដឹង ជំនាញ តម្លៃ និងឥរិយាបថ ដែលអ្នកសិក្សាត្រូវការ ដើម្បីអាចចូលរួមនៅក្នុងការបង្កើតពិភពលោកមួយ ដែលប្រកបដោយការរួមបញ្ចូលគ្នា យុត្តិធម៌ និងសន្តិភាព។ ការអប់រំភាពជាពលរដ្ឋសកល ជ្រើសរើសយកពហុវិធីសាស្រ្ត ដោយប្រើប្រាស់ទស្សនាទាន និងវិធីសាស្រ្តបង្រៀន ដែលត្រូវបានអនុវត្តរួចហើយនៅក្នុងមុខវិជ្ជាផ្សេងៗទៀត ដែលរួមមាន

ការអប់រំពីសិទ្ធិមនុស្ស ការអប់រំពីសន្តិភាព ការអប់រំពីការអភិវឌ្ឍជានិរន្តរ៍ និងការអប់រំដើម្បីការយល់ដឹងជាអន្តរជាតិ[5] និងមានបំណងធ្វើឱ្យកាន់តែជឿនលឿននូវគោលបំណងរួមនៃការអប់រំទាំងនេះ។ ការអប់រំភាពជាពលរដ្ឋសកល អនុវត្តនូវគោលគំនិតនៃការរៀនមួយជីវិត ដោយចាប់ផ្តើមពីដំណាក់កាលដំបូងនៃកុមារភាព និងបន្តទៅគ្រប់កម្រិតនៃការអប់រំរហូតដល់វ័យជំទង់ ដោយត្រូវការវិធីសាស្ត្រ កម្មវិធីសិក្សា និងអន្តរាគមន៍ពីកម្មវិធីសិក្សាបន្ថែម ទាំងផ្លូវការ និងក្រៅផ្លូវការ និងត្រូវការទាំងវិធីសាស្ត្រចូលរួមបែបប្រពៃណី និងបែបទំនើប។[6]

**ការអប់រំភាពជាពលរដ្ឋសកលមានបំណងចង់ឱ្យអ្នកសិក្សាសម្រេចបាននូវ ៖**

- អភិវឌ្ឍនូវការយល់ដឹងមួយស្តីអំពីរចនាសម្ព័ន្ធអភិបាលកិច្ចសកល សិទ្ធិនិងការទទួលខុសត្រូវ បញ្ហាសកល និងទំនាក់ទំនងរវាងប្រព័ន្ធនិងដំណើរការនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល។
- ទទួលស្គាល់ និងលើកសរសើរភាពខុសគ្នា និងពហុអត្តសញ្ញាណ ដូចជាវប្បធម៌ ភាសា សាសនា ភេទ និងមនុស្សជាតិទូទៅ និងអភិវឌ្ឍជំនាញសម្រាប់ការរស់នៅ នៅក្នុងពិភពលោកមួយដែលកាន់តែមានពិពិធភាព។
- អភិវឌ្ឍ និងអនុវត្តជំនាញក្នុងការត្រិះរិះពិចារណា ដើម្បីក្លាយទៅជាអក្ខរកម្មពលរដ្ឋ។ ជំនាញទាំងនោះរួមមាន ៖ ការសួរដេញដោលប្រកបដោយការត្រិះរិះពិចារណា បច្ចេកវិជ្ជាព័ត៌មាន អក្ខរកម្មសារព័ត៌មាន ការត្រិះរិះពិចារណា ការធ្វើសេចក្តីសម្រេចចិត្ត ការដោះស្រាយបញ្ហា ការចរចារ ការកសាងសន្តិភាព និងការទទួលខុសត្រូវជាលក្ខណៈបុគ្គលនិងសង្គម។
- ទទួលស្គាល់ និងពិនិត្យមើលទៅលើជំនឿនិងតម្លៃ និងរបៀបដែលពួកវាមានឥទ្ធិពលទៅលើទស្សននិងការធ្វើសេចក្តីសម្រេចចិត្តផ្នែកសង្គមនិងនយោបាយ ស្តីអំពីយុត្តិធម៌សង្គមនិងការចូលរួមរបស់ពលរដ្ឋ។

---

[5] សូមអានសៀវភៅរបស់អង្គការយូនីស្កូ (បោះពុម្ពឆ្នាំ២០១៤) ដែលមានចំណងជើងថា «យុទ្ធសាស្ត្រអប់រំ ២០១៤-២០២១ ទំព័រ៤៦។

[6] សូមអានសៀវភៅរបស់អង្គការយូនីស្កូ (បោះពុម្ពឆ្នាំ២០១៤) ដែលមានចំណងជើងថា «ការអប់រំភាពជាពលរដ្ឋសាកល ៖ ការរៀបចំអ្នកសិក្សាសម្រាប់បញ្ហាប្រឈមនៅក្នុងសតវត្សរ៍ទី២១»។

- អភិវឌ្ឍឥរិយាបថយកចិត្តទុកដាក់ និងសេចក្ដីអាណិតអាសូរសម្រាប់អ្នកដទៃនិងបរិស្ថាន និងការគោរពចំពោះពិពិធភាព។
- អភិវឌ្ឍតម្លៃនៃភាពត្រឹមត្រូវនិងយុត្តិធម៌សង្គម និងជំនាញក្នុងការវិភាគប្រកបដោយការត្រិះរិះពិចារណាអំពីវិសមភាព ដែលផ្អែកលើភេទ ឋានៈសង្គមសេដ្ឋកិច្ច វប្បធម៌ សាសនា វ័យ និងបញ្ហាផ្សេងៗទៀត។
- ចូលរួម និងរួមចំណែកនៅក្នុងបញ្ហាសកលនាសហសម័យ នៅក្នុងកម្រិតមូលដ្ឋាន ជាតិ និងសកល ក្នុងនាមជាពលរដ្ឋសកល ដែលប្រកបដោយចំណេះដឹង ការចូលរួម ការទទួលខុសត្រូវ និងការឆ្លើយតប។

*អាទិភាពនៃសមភាពយេនឌ័រ ៖* ការអប់រំភាពជាពលរដ្ឋសកល អាចដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការចូលរួមចំណែកទៅក្នុងសមភាពយេនឌ័រ ដែលជាអាទិភាពដ៏សំខាន់មួយនៅក្នុងចំណោមអាទិភាពសំខាន់ទាំងពីររបស់អង្គការយូណេស្កូ។ ការអប់រំភាពជាពលរដ្ឋសកល គឺផ្អែកលើសិទ្ធិមនុស្ស ហើយសមភាពយេនឌ័រគឺជាមូលដ្ឋាននៃសិទ្ធិមនុស្ស។ កុមារា និងកុមារីសិក្សាអំពីឥរិយាបថយេនឌ័រ តួនាទី ការរំពឹងទុក និងអាកប្បកិរិយានៅសាលារៀន ក៏ដូចជានៅឯផ្ទះ។ ការអប់រំភាពជាពលរដ្ឋសកល អាចជួយទ្រទ្រង់សមភាពយេនឌ័រ តាមរយៈការអភិវឌ្ឍចំណេះដឹង ជំនាញ តម្លៃ និងឥរិយាបថ ដែលលើកកម្ពស់តម្លៃស្មើគ្នារវាងស្ត្រីនិងបុរស បង្កើតឱ្យមានការគោរព និងអនុញ្ញាតឱ្យមនុស្សវ័យក្មេងធ្វើការចោទសួរប្រកបដោយការត្រិះរិះពិចារណា ទៅលើតួនាទីនិងការរំពឹងទុករបស់យេនឌ័រ ដែលអាចបង្កជាគ្រោះថ្នាក់ ឬក៏ជម្រុញឱ្យមានការរើសអើង ឬការគិតបែបអវិជ្ជមានដោយផ្អែកទៅលើយេនឌ័រ។

## ១.២. តើសៀវភៅណែនាំនេះត្រូវបានអភិវឌ្ឍឡើងដោយរបៀបណា?

សៀវភៅណែនាំនេះត្រូវបានអភិវឌ្ឍឡើងពីការស្រាវជ្រាវ និងការអនុវត្តការអប់រំភាពជាពលរដ្ឋសកល។ វាក៏ទទួលបាននូវប្រភពព័ត៌មានបន្ថែម ពីសៀវភៅដែលត្រូវបានបោះពុម្ពផ្សាយដោយអង្គការយូណេស្កូនាពេលថ្មីៗនេះ និងការផ្តល់ប្រឹក្សាផ្នែកបច្ចេកទេសនៅក្នុងប្រធានបទនេះ[7] ក៏ដូចជាការរួមចំណែករបស់អ្នកជំនាញស្តីពីភាពជាពលរដ្ឋសកល និងតំណាងយុវជន។ ឯកសារនេះត្រូវបានត្រួតពិនិត្យដោយក្រុមប្រឹក្សាអ្នកជំនាញ ដែលត្រូវបានរៀបចំឡើងដោយអង្គការយូណេស្កូ ជាមួយនឹងអ្នកជំនាញទាំងខាងក្នុងនិងខាងក្រៅ មកពីគ្រប់តំបន់ទាំងអស់នៅជុំវិញពិភពលោក ដែលមានជំនាញទៅលើការអប់រំភាពជាពលរដ្ឋសកល គរុកោសល្យប្រកបដោយការផ្លាស់ប្តូរ ការអភិវឌ្ឍកម្មវិធីសិក្សា និងការអប់រំក្រៅប្រព័ន្ធ។ ក្រុមប្រឹក្សាអ្នកជំនាញបានពិភាក្សាគ្នា និងផ្តល់យោបល់ត្រឡប់ទៅលើសេចក្តីព្រាងលើកទីមួយនៃឯកសារនេះ នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំមួយ នៅក្នុងខែមិថុនា ឆ្នាំ២០១៤។ ការផ្តល់យោបល់បន្ថែម ត្រូវបានផ្តល់ឱ្យតាមរយៈកិច្ចពិគ្រោះយោបល់បន្តនៅក្នុងខែកញ្ញា និងខែតុលា ឆ្នាំ២០១៤។ សៀវភៅណែនាំនេះក៏ត្រូវបានពិភាក្សា នៅក្នុងអំឡុងពេលនៃវេទិកាអង្គការយូណេស្កូលើកទីពីរ ស្តីអំពីការអប់រំភាពជាពលរដ្ឋសកល ដែលត្រូវបានប្រារព្ធធ្វើឡើងនៅក្នុងទីក្រុងប៉ារីស នៅខែមករា ឆ្នាំ២០១៥ និងទទួលបានយោបល់ត្រឡប់ពីអ្នកចូលរួម។

មុនពេលសម្រេចបញ្ចប់ជាលើកចុងក្រោយ សៀវភៅណែនាំនេះត្រូវបានធ្វើការសាកល្បងនៅតាមមូលដ្ឋានដោយអ្នកអប់រំ ដែលរួមមានមន្ត្រីក្រសួង អ្នកអភិវឌ្ឍកម្មវិធីសិក្សា និងគ្រូបង្រៀននៅក្នុងប្រទេសជ្រើសរើសនៅគ្រប់តំបន់ទាំងអស់។

នេះគឺជាការបោះពុម្ពលើកទីមួយនៃសៀវភៅណែនាំនេះ ដែលមានគោលបំណងក្លាយទៅជាឯកសាររស់។ ការបោះពុម្ពលើកក្រោយៗទៀត នឹងត្រូវបានធ្វើឡើងតាមការចាំបាច់ និងនៅពេលដែលយើងសិក្សាបន្ថែមពីបទពិសោធន៍ នៃការអនុវត្តការអប់រំភាពជាពលរដ្ឋសកល

[7] ឧទាហរណ៍ សៀវភៅដែលមានចំណងជើងថា «ការអប់រំភាពជាពលរដ្ឋសាកល ៖ ទស្សនដែលទើបតែលេចឡើងមួយ» ដែលផ្អែកលើមូលដ្ឋាននៃការប្រជុំពិភាក្សាបច្ចេកទេស ស្តីអំពីការអប់រំភាពជាពលរដ្ឋសាកល ដែលត្រូវបានធ្វើឡើងនៅខែកញ្ញា ឆ្នាំ២០១៣ និង សៀវភៅ «ការអប់រំភាពជាពលរដ្ឋសាកល ៖ ការរៀបចំអ្នកសិក្សាសម្រាប់បញ្ហាប្រឈមនៅក្នុងសតវត្សរ៍ទី២១» ដែលដកស្រង់ចេញពីលទ្ធផលនៃវេទិកាអង្គការយូណេស្កូលើកទីមួយ ស្តីអំពីការអប់រំភាពជាពលរដ្ឋសាកល ដែលត្រូវបានធ្វើឡើងនៅខែធ្នូ ឆ្នាំ២០១៣។

នៅក្នុងបរិបទផ្សេងៗគ្នា។ អង្គការយូណេស្កូស្វាគមចំពោះមតិយោបល់ និងឧទាហរណ៍នៃការស្រាវជ្រាវនិងការអនុវត្តសម្រាប់ការបោះពុម្ពលើកក្រោយៗទៀត។

## ១.៣. តើសៀវភៅណែនាំនេះសម្រាប់អ្នកណា និងអាចត្រូវបានប្រើប្រាស់ដោយរបៀបណា?

សៀវភៅណែនាំនេះគឺសម្រាប់ជាប្រភពធនធានមួយសម្រាប់អ្នកអប់រំ អ្នកអភិវឌ្ឍកម្មវិធីសិក្សា អ្នកបណ្ដុះបណ្ដាល ក៏ដូចជាអ្នកធ្វើគោលនយោបាយ។ សៀវភៅណែនាំនេះក៏មានប្រយោជន៍ផងដែរសម្រាប់អ្នកអប់រំផ្សេងទៀត ដែលធ្វើការទាក់ទងទៅនឹងការរៀបចំផែនការការចងក្រងនិងការអនុវត្តការអប់រំភាពជាពលរដ្ឋសកល ទាំងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ។ ឧទាហរណ៍ អ្នកអប់រំអាចប្រើប្រាស់សៀវភៅណែនាំនេះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងរបស់ខ្លួន អំពីការអប់រំភាពជាពលរដ្ឋសកល និងជាប្រភពធនធានមួយនៃគំនិតសម្រាប់អនុវត្តសកម្មភាព។ អ្នកអភិវឌ្ឍកម្មវិធីសិក្សាអាចប្រើប្រាស់ និងយកលំនាំតាមប្រធានបទនិងវត្ថុបំណងនៃការសិក្សា ដែលមាននៅក្នុងសៀវភៅណែនាំនេះ ទៅក្នុងបរិបទនៅក្នុងប្រទេស និងការអភិវឌ្ឍកម្មវិធីសិក្សាជាតិ។ អ្នករៀបចំគោលនយោបាយអប់រំអាចប្រើប្រាស់សៀវភៅណែនាំនេះ ដើម្បីវាយតម្លៃតួនាទីនៃការអប់រំភាពជាពលរដ្ឋសកល និងកំណត់អាទិភាពនៃការអប់រំជាតិដែលពាក់ព័ន្ធ។

ដូចដែលបានបង្ហាញនៅក្នុងក្រាហ្វិកខាងក្រោម សៀវភៅណែនាំនេះត្រូវបានរៀបរៀងឡើង នៅក្នុងវិធីមួយដែលអាចបត់បែនបាន ដែលអនុញ្ញាតឱ្យមានការប្រឹក្សាយោបល់ ការយកលំនាំ និងការដាក់ចូលទៅក្នុងបរិបទ នៅក្នុងកម្រិតជាតិដោយអ្នកអប់រំ ដែលអាចកំណត់នូវចំណុចចូលដែលពាក់ព័ន្ធ ដែលអាចអភិវឌ្ឍសេចក្ដីណែនាំជាក់លាក់ ស្របតាមបរិបទច្បាស់លាស់ និងលម្អិតមួយ ដែលអាចដោះស្រាយជាមួយនឹងតម្រូវការសមត្ថភាពក្នុងការអនុវត្ត និងដែលអាចទ្រទ្រង់ដំណើរការនៃការអនុវត្ត ដោយមានការប្រឹក្សាជាមួយអ្នកពាក់ព័ន្ធទាំងឡាយ។

**ប្រអប់ទី២ ៖ របៀបប្រើប្រាស់សេចក្តីណែនាំបែបគរុកោសល្យនៅកម្រិតជាតិ**

ការអប់រំភាពជាពលរដ្ឋសកល ៖ ប្រធានបទ និង វត្ថុបំណងនៃការសិក្សា (TLOs)

↓

សម្របសម្រួល TLOs ទៅក្នុងបរិបទកម្រិតជាតិ ដោយអ្នកពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន (ឧទាហរណ៍ ៖ អ្នករៀបចំផែនការអប់រំ និងអ្នកអភិវឌ្ឍកម្មវិធីសិក្សា និងនៅពេលចាំបាច់ ដោយមានការគាំទ្រពីដៃគូនិងអ្នកពាក់ព័ន្ធផ្សេងៗទៀត)

↓

អភិវឌ្ឍសេចក្តីណែនាំជាក់លាក់ ស្របតាមបរិបទ ច្បាស់លាស់ និងលម្អិត និងដោះស្រាយបញ្ហាសមត្ថភាព

↓

អនុវត្តនិងប្រើប្រាស់ដោយអ្នកអប់រំនៅក្នុងកម្រិតផ្សេងៗគ្នា (ឧទាហរណ៍ ៖ កម្រិតជាតិ ខេត្ត និងសាលារៀន)

សៀវភៅណែនាំនេះមិនមែនជាការដាក់បញ្ញត្តទេ ប៉ុន្តែមានបំណងផ្តល់ឱ្យនូវក្របខណ្ឌណែនាំមួយសម្រាប់ការអប់រំភាពជាពលរដ្ឋសកល ដែលអាចសម្របសម្រួលបានយ៉ាងស្រួលទៅក្នុងបរិបទមូលដ្ឋាននិងបរិបទជាតិផ្សេងៗគ្នា។ សៀវភៅណែនាំនេះក៏អាចប្រើប្រាស់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការងារដែលមានស្រាប់ នៅក្នុងមុខវិជ្ជាពាក់ព័ន្ធ (ឧទាហរណ៍ ការអប់រំសីលធម៌ ការអប់រំសិទ្ធិមនុស្ស ការអប់រំសម្រាប់ការអភិវឌ្ឍជានិរន្ត ការអប់រំសម្រាប់ការយល់ដឹងជាអន្តរជាតិ ឬការអប់រំផ្សេងៗទៀត)។ ប្រធានបទនិងវត្ថុបំណងនៃការសិក្សាដែលត្រូវបានផ្តល់យោបល់បញ្ចូលទៅក្នុងសៀវភៅណែនាំនេះ មិនទាន់អស់នៅឡើយទេ។ ប្រធានបទនិងវត្ថុបំណងនៃការសិក្សាទាំងនេះ គួរត្រូវបានបំពេញបន្ថែមដោយប្រធានបទនិងបញ្ហាដែលពាក់ព័ន្ធនិងសមស្របនៅក្នុងមូលដ្ឋាន។ ជាងនេះទៅទៀត ប្រធានបទថ្មីៗដែលកើតឡើងជាបន្តបន្ទាប់ នៅក្នុងពិភពលោកដែលប្រកបដោយពិពិធភាពនិងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនេះ អាចត្រូវបានបន្ថែមចូលទៅក្នុងប្រធានបទនិងវត្ថុបំណងនៃការសិក្សា ដែលត្រូវបានបញ្ចូលទៅក្នុងសៀវភៅណែនាំនេះ។ ប្រធានបទនិងវត្ថុបំណងនៃការសិក្សានៅក្នុងសៀវភៅណែនាំនេះប្រហែលជាត្រូវបានគ្រប់ដណ្តប់រួចហើយ ដោយកម្មវិធីអប់រំដែលមានស្រាប់។ នៅក្នុងករណី

នេះ សៀវភៅណែនាំនេះអាចត្រូវបានប្រើប្រាស់ជាប្រភពធនធានបន្ថែម ឬជាបញ្ជីត្រួតពិនិត្យ ឬជាឯកសារយោង សម្រាប់ការវិភាគទៅលើចន្លោះខ្វះខាត នៅពេលពិនិត្យមើល ឬស្វែងរក ការពង្រឹងកម្មវិធីសិក្សាដែលមានស្រាប់ទាំងនេះ។

២

# សេចក្ដីណែនាំ ៖ ខ្លឹមសារសម្រាប់ការសិក្សាការអប់រំភាពជាពលរដ្ឋសកល

## ២.១. បណ្ដុំនៃការសិក្សា

ការអប់រំភាពជាពលរដ្ឋសកល ផ្អែកទៅលើបណ្ដុំនៃការសិក្សាចំនួនបី ៖ ចំណេះដឹង ចិត្តសង្គម និងឥរិយាបថ។ បណ្ដុំទាំងនេះឆ្លើយតបទៅនឹងសរសរស្ដម្ភទាំងបួននៃការសិក្សា ដែលត្រូវបានរៀបរាប់នៅក្នុងរបាយការណ៍ ដែលមានចំណងជើងថា «ការសិក្សា ៖ រតនៈសម្បត្តិពីខាងក្នុង» ដែលរួមមាន រៀនដើម្បីចេះ រៀនដើម្បីធ្វើ រៀនដើម្បីមានឥរិយាបថ និងរៀនរួមរស់នៅជាមួយគ្នា។

- ចំណេះដឹង ៖ ចំណេះដឹងនិងជំនាញក្នុងការគិត ដែលចាំបាច់សម្រាប់ការយល់ដឹងប្រសើរជាងមុន អំពីពិភពលោកនិងភាពស្មុគស្មាញរបស់វា។
- ចិត្តសង្គម ៖ តម្លៃ ឥរិយាបថ និងជំនាញសង្គម ដែលអនុញ្ញាតឱ្យអ្នកសិក្សាធ្វើការអភិវឌ្ឍខ្លួនប្រកបដោយសេចក្ដីស្រលាញ់ ផ្នែកចិត្តសាស្ត្រ និងផ្នែកសារពាង្គកាយ និងអនុញ្ញាតឱ្យពួកគេរស់នៅជាមួយអ្នកដទៃ ប្រកបដោយការគោរពនិងសន្តិភាព។
- ឥរិយាបថ ៖ ការប្រព្រឹត្ត ការសម្ដែង ការអនុវត្តជាក់ស្ដែង និងការចូលរួម។

លទ្ធផលសិក្សាចម្បងៗ គុណសម្បត្តិសិក្សាចម្បងៗ ប្រធានបទ និងវត្ថុបំណងនៃការសិក្សា ដែលត្រូវបានផ្ដល់ឱ្យនៅក្នុងសៀវភៅណែនាំនេះ គឺផ្អែកទៅលើបណ្ដុំនៃការសិក្សាដែលត្រូវបានលើកឡើងខាងលើ។ ពួកគេមានទំនាក់ទំនងគ្នា និងត្រូវបានបញ្ជ្រាបទៅក្នុងដំណើរការនៃការសិក្សា ហើយមិនគួរត្រូវបានយល់ថាជាដំណើរការនៃការសិក្សាដាច់ដោយឡែកនោះទេ។

## ២.២. លទ្ធផលសិក្សា

លទ្ធផលសិក្សាពណ៌នាអំពីចំណេះដឹង ជំនាញ តម្លៃ និងឥរិយាបថ ដែលអ្នកសិក្សាអាចសម្រេច និងបង្ហាញបាន ដែលជាលទ្ធផលនៃការអប់រំភាពជាពលរដ្ឋសកល។ ឆ្លើយតបទៅនឹងបណ្តុំនៃការសិក្សាទាំងបី ដែលត្រូវបានលើកឡើងខាងលើ (ចំណេះដឹង ចិត្តសង្គម និងឥរិយាបថ) បណ្តុំនៃលទ្ធផលសិក្សាដែលបំពេញឱ្យគ្នាទៅវិញទៅមក ត្រូវបានកំណត់នៅក្នុងសៀវភៅណែនាំនេះ។

**ប្រអប់ទី៣ ៖ លទ្ធផលសិក្សាសំខាន់ៗ**

| ចំណេះដឹង |
| --- |
| ▪ អ្នកសិក្សាទទួលបានចំណេះដឹងនិងការយល់ដឹង អំពីបញ្ហានៅក្នុងមូលដ្ឋាន ជាតិ និងសកល និងទំនាក់ទំនងគ្នា និងការអាស្រ័យគ្នាទៅវិញទៅមក រវាងប្រទេសនិងប្រជាជនផ្សេងៗគ្នា។<br>▪ អ្នកសិក្សាអភិវឌ្ឍជំនាញសម្រាប់ការត្រិះរិះពិចារណា និងការវិភាគ។ |

| ចិត្តសង្គម |
| --- |
| ▪ អ្នកសិក្សាពិសោធអារម្មណ៍នៃការក្លាយទៅជាផ្នែកមួយនៃមនុស្សជាតិទូទៅ ចែករំលែកតម្លៃនិងការទទួលខុសត្រូវ ដោយផ្អែកទៅលើសិទ្ធិមនុស្ស។<br>▪ អ្នកសិក្សាអភិវឌ្ឍឥរិយាបថនៃការអាណិតអាសូរ សាមគ្គីភាព និងការគោរពចំពោះភាពខុសគ្នា និងពិពិធភាព។ |

| ឥរិយាបថ |
| --- |
| ▪ អ្នកសិក្សាធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវ នៅក្នុងកម្រិតមូលដ្ឋាន ជាតិ និងអន្តរជាតិ សម្រាប់ពិភពលោកមួយដែលមានសន្តិភាពនិងនិរន្តរភាពជាង។<br>▪ អ្នកសិក្សាអភិវឌ្ឍការលើកទឹកចិត្តនិងការស្ម័គ្រចិត្តក្នុងការចាត់វិធានការចាំបាច់។ |

## ៣. គុណសម្បត្តិសិក្សា

សៀវភៅណែនាំនេះរកឃើញគុណសម្បត្តិអ្នកសិក្សាបីយ៉ាង ទាក់ទងទៅនឹងការអប់រំភាពជាពលរដ្ឋសកល ដែលសំដៅទៅដល់ចរិកលក្ខណៈនិងគុណភាព ដែលការអប់រំភាពជាពលរដ្ឋសកល មានបំណងចង់អភិវឌ្ឍទៅដល់អ្នកសិក្សា និងឆ្លើយតបទៅនឹងវត្ថុបំណងនៃការសិក្សា ដែលបានលើកឡើងពីខាងដើម។ ទាំងនេះរួមមាន ៖ *ចំណេះដឹងនិងការត្រិះរិះពិចារណា ទំនាក់ទំនងក្នុងសង្គមនិងការគោរពចំពោះពិពិធភាព និងការទទួលខុសត្រូវនិងការចូលរួមប្រកបដោយសីលធម៌*។ គុណភាពនៃអ្នកសិក្សាទាំងបីនេះ ដកស្រង់ចេញពីការសិក្សាទៅលើការបោះពុម្ពផ្សាមុនៗ និងក្របខណ្ឌទស្សនាទាននៃការអប់រំភាពជាពលរដ្ឋ ការពិនិត្យមើលទៅលើវិធីសាស្រ្តនិងកម្មវិធីសិក្សា ក៏ដូចជាកិច្ចពិគ្រោះយោបល់បច្ចេកទេស និងកិច្ចការនាពេលថ្មីៗនេះរបស់អង្គការយូនីស្កូ ស្តីអំពីការអប់រំភាពជាពលរដ្ឋសកល។ គុណសម្បត្តិទាំងនេះត្រូវបានសង្ខេបដូចខាងក្រោម ៖

| ចំណេះដឹងនិងការត្រិះរិះពិចារណា |
| --- |
| ចំណេះដឹងស្តីអំពីប្រព័ន្ធអភិបាលកិច្ច រចនាសម្ព័ន្ធ និងបញ្ហាសកល ការយល់ដឹងអំពីការអាស្រ័យគ្នាទៅវិញទៅមក និងទំនាក់ទំនងរវាងការព្រួយបារម្ភនៅថ្នាក់មូលដ្ឋាននិងសកល ចំណេះដឹងនិងជំនាញដែលត្រូវការសម្រាប់ជាចំណេះដឹងរបស់ពលរដ្ឋ ដូចជាការចោទសួរប្រកបដោយការត្រិះរិះពិចារណា និងការវិភាគ ដោយសង្កត់ធ្ងន់ទៅលើការចូលរួមយ៉ាងសកម្មនៅក្នុងការសិក្សា។<br><br>អ្នកសិក្សាអភិវឌ្ឍការយល់ដឹងរបស់ខ្លួន ទៅលើពិភពលោក ប្រធានបទសកល ប្រព័ន្ធនិងរចនាសម្ព័ន្ធអភិបាលកិច្ច ដែលរួមមាននយោបាយ ប្រវត្តិសាស្រ្ត និងសេដ្ឋកិច្ច យល់អំពីសិទ្ធិនិងការទទួលខុសត្រូវរបស់បុគ្គលនិងក្រុម (ឧទាហរណ៍ សិទ្ធិរបស់ស្រ្តីនិងកុមារ សិទ្ធិរបស់ជនជាតិដើម និងកតព្វកិច្ចសង្គមរបស់សាជីវកម្ម) និងទទួលស្គាល់ភាពទំនាក់ទំនងគ្នារវាងបញ្ហា រចនាសម្ព័ន្ធ និងដំណើរការនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល។ អ្នកសិក្សាអភិវឌ្ឍជំនាញទៅលើការចោទសួរប្រកបដោយការត្រិះរិះពិចារណា (ឧទាហរណ៍ តើត្រូវរក |

ព័ត៌មាននៅកន្លែងណា និងតើត្រូវវិភាគនិងប្រើប្រាស់ភស្តុតាងដោយរបៀបណា) ចំណេះដឹងស្ដីអំពីសារព័ត៌មាន និងការយល់ដឹងអំពីរបៀបដែលព័ត៌មានត្រូវបានសម្របសម្រួល និងធ្វើទំនាក់ទំនងគ្នា។ អ្នកសិក្សាអភិវឌ្ឍសមត្ថភាពរបស់ខ្លួនក្នុងការចោទសួរទៅប្រធានបទនិងបញ្ហាសកល (ឧទាហរណ៍ សកលភាវូបនីយកម្ម ការអាស្រ័យគ្នាទៅវិញទៅមក ទេសន្តរប្រវេសន៍ សន្តិភាព ជម្លោះ និងការអភិវឌ្ឍជានិរន្តន៍) ដោយរៀបចំផែនការស៊ើបអង្កេត វិភាគទិន្នន័យ និងផ្សព្វផ្សាយការរកឃើញរបស់ខ្លួន។ បញ្ហាចម្បងមួយគឺរបៀបដែលភាសាត្រូវបានប្រើប្រាស់ និងជាក់លាក់ជាងនេះទៅទៀត របៀបដែលចំណេះដឹងប្រកបដោយការត្រិះរិះពិចារណា ទទួលរងផលប៉ះពាល់ពីភាពលុបលើនៃភាសាអង់គ្លេស និងថាតើភាពលុបលើនេះជះឥទ្ធិពលដូចម្ដេចខ្លះ ទៅលើលទ្ធភាពក្នុងការទទួលបានព័ត៌មានរបស់អ្នកដែលមិននិយាយភាសាអង់គ្លេស។ មានការផ្ដោតការយកចិត្តទុកដាក់មួយ ក្នុងការអភិវឌ្ឍជំនាញចំណេះដឹងពលរដ្ឋប្រកបដោយការត្រិះរិះពិចារណា និងការប្ដេជ្ញាចិត្តមួយចំពោះការសិក្សាអស់មួយជីវិត ដើម្បីចូលរួមនៅក្នុងសកម្មភាពពលរដ្ឋប្រកបដោយចំណេះដឹងនិងមានគោលបំណងច្បាស់លាស់។

## ទំនាក់ទំនងក្នុងសង្គមនិងការគោរពចំពោះពិពិធភាព

យល់ដឹងអំពីអត្តសញ្ញាណ ទំនាក់ទំនង និងភាពជាម្ចាស់ យល់ដឹងអំពីតម្លៃរួម និងមនុស្សជាតិរួម អភិវឌ្ឍការកោតសរសើរនិងការគោរពចំពោះភាពខុសគ្នានិងពិពិធភាព និងយល់ដឹងអំពីទំនាក់ទំនងដ៏ស្មុគស្មាញរវាងពិពិធភាពនិងលក្ខណៈរួម។

អ្នកសិក្សារៀនអំពីអត្តសញ្ញាណរបស់ខ្លួន និងអំពីរបៀបដែលពួកគេត្រូវបានដាក់ទៅក្នុងពហុទំនាក់ទំនង (ឧទាហរណ៍ ទំនាក់ទំនងក្នុងគ្រួសារ មិត្តភក្តិ សាលារៀន សហគមន៍មូលដ្ឋាន ប្រទេស) ដែលជាមូលដ្ឋានមួយសម្រាប់ការយល់ដឹងអំពីសមាសធាតុជាសកលនៃភាពជាពលរដ្ឋ។ អ្នកសិក្សាអភិវឌ្ឍការយល់ដឹងមួយអំពីភាពខុសគ្នានិងពិពិធភាព (ឧទាហរណ៍ វប្បធម៌ ភាសា យែនឌ័រ អារម្មណ៍ផ្លូវភេទ និងសាសនា) អំពីរបៀបដែលជំនឿ និងតម្លៃមានឥទ្ធិពលទៅលើទស្សនរបស់មនុស្ស ទៅលើអ្នកទាំងឡាយដែលខុសពីខ្លួន និងអំពីមូលហេតុនិងផលប៉ះពាល់នៃវិសមភាពនិងការរើសអើង។ អ្នកសិក្សាក៏ពិចារណាអំពី

កត្តារួមដើម្បីជំនះភាពខុសគ្នា និងអភិវឌ្ឍចំណេះដឹង ជំនាញ តម្លៃ និងឥរិយាបថ ដែលចាំបាច់សម្រាប់ការគោរពភាពខុសគ្នា និងការរស់នៅជាមួយអ្នកដទៃ។

## ការទទួលខុសត្រូវនិងការចូលរួមប្រកបដោយសីលធម៌

ផ្អែកលើមូលដ្ឋានវិធីសាស្ត្រសិទ្ធិមនុស្ស និងដោយរួមបញ្ចូលឥរិយាបថនិងតម្លៃនៃការយកចិត្តទុកដាក់ទៅលើអ្នកដទៃនិងបរិស្ថាន កតព្វកិច្ចនិងការផ្លាស់ប្តូរសង្គមនិងបុគ្គល និងការអភិវឌ្ឍជំនាញសម្រាប់ចូលរួមនៅក្នុងសហគម និងរួមចំណែកធ្វើឱ្យប្រសើរឡើងនូវពិភពលោកមួយ តាមរយៈសកម្មភាពប្រកបដោយចំណេះដឹង សីលធម៌ និងសន្តិភាព។

អ្នកសិក្សាស្វែងយល់ជំនឿនិងតម្លៃផ្ទាល់ខ្លួននិងរបស់អ្នកដទៃ។ អ្នកសិក្សាយល់ដឹងអំពីរបៀបដែលជំនឿនិងតម្លៃ ជួយដល់ការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយនិងសង្គម នៅក្នុងកម្រិតមូលដ្ឋាន ជាតិ តំបន់ និងសកល និងបញ្ហាប្រឈមសម្រាប់ការគ្រប់គ្រងជំនឿនិងតម្លៃ ដែលមានភាពផ្ទុយគ្នានិងប្រកបដោយជម្លោះ។ អ្នកសិក្សាក៏នឹងអភិវឌ្ឍការយល់ដឹងរបស់ខ្លួនអំពីបញ្ហាយុត្តិធម៌សង្គម នៅក្នុងបរិបទមូលដ្ឋាន ជាតិ តំបន់ និងសកល និងអំពីរបៀបដែលបរិបទទាំងនេះមានទំនាក់ទំនងគ្នា។ បញ្ហាសីលធម៌ (ឧទាហរណ៍ បញ្ហាទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់និយម សកលភាវូបនីយកម្មផ្នែកសេដ្ឋកិច្ច យុត្តិធម៌ផ្នែកពាណិជ្ជកម្ម ទេសន្តរប្រវេសន៍ ភាពក្រីក្រ ទ្រព្យសម្បត្តិ ការអភិវឌ្ឍជានិរន្ត ភេរវកម្ម និងសង្គ្រាម) ក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ។ អ្នកសិក្សានឹងត្រូវបានរំពឹងថាធ្វើការឆ្លុះបញ្ចាំងទៅលើជម្លោះផ្នែកសីលធម៌ ទាក់ទងទៅនឹងកតព្វកិច្ចផ្នែកសង្គមនិងនយោបាយ និងឥទ្ធិពលទូលំទូលាយជាងនេះ ទៅលើជម្រើសនិងការសម្រេចចិត្តរបស់ពួកគេ។ អ្នកសិក្សាក៏នឹងអភិវឌ្ឍចំណេះដឹង ជំនាញ តម្លៃ និងឥរិយាបថ ក្នុងការយកចិត្តទុកដាក់ចំពោះអ្នកដទៃនិងបរិស្ថាន និងក្នុងការចូលរួមសកម្មភាពពលរដ្ឋ។ ទាំងនេះរួមមានសេចក្តីករុណា សេចក្តីអាណិតអាសូរ ការសហការ កិច្ចសន្ទនា សហគ្រិនភាពសង្គម និងការចូលរួមយ៉ាងសកម្ម។ ពួកគេសិក្សាអំពីឱកាសសម្រាប់ការចូលរួមក្នុងនាមជាពលរដ្ឋ នៅក្នុងកម្រិតមូលដ្ឋាន ជាតិ និងសកល និងអំពីឧទាហរណ៍ទាំងឡាយនៃសកម្មភាពរបស់បុគ្គល

និងសកម្មភាពជាសមូហភាព ដែលត្រូវបានធ្វើឡើងដោយអ្នកទៃ ក្នុងការដោះស្រាយបញ្ហាសកលនិងយុត្តិធម៌សង្គម។

## ២.៤. ប្រធានបទ

ដោយផ្អែកទៅលើគុណសម្បត្តរបស់អ្នកសិក្សា ដែលត្រូវបានកំណត់ខាងលើ និងការឆ្លើយឆ្លងគ្នារវាងបណ្តុំនៃការសិក្សា និងលទ្ធផលសិក្សាសំខាន់ៗ ប្រធានបទចំនួន៩ ដែលមានប្រធានបទ៣សម្រាប់គុណសម្បត្តិរបស់អ្នកសិក្សានីមួយៗ ត្រូវបានបង្ហាញនៅក្នុងសៀវភៅណែនាំនេះ។ ប្រធានបទទាំងនេះរួមមាន ៖

**ចំណេះដឹងនិងការត្រិះរិះពិចារណា**

១. រចនាសម្ព័ន្ធនិងប្រព័ន្ធមូលដ្ឋាន ជាតិ និងសកល

២. ប្រធានបទដែលប៉ះពាល់ទៅដល់អន្តរកម្ម និងទំនាក់ទំនងនៃសហគមន៍នៅថ្នាក់មូលដ្ឋាន ជាតិ និងសកល

៣. ឥទ្ធិពលនៃការសន្ទត់ និងថាមពលនៃអំណាច

**ទំនាក់ទំនងក្នុងសង្គមនិងការគោរពចំពោះពិពិធភាព**

៤. កម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណ

៥. សហគមន៍ផ្សេងៗគ្នាដែលជារបស់មនុស្ស និងថាតើវាមានទំនាក់ទំនងគ្នាដោយរបៀបណា

៦. ភាពខុសគ្នា និងការគោរពចំពោះពិពិធភាព

**ការទទួលខុសត្រូវនិងការចូលរួមប្រកបដោយសីលធម៌**

៧. សកម្មភាពដែលអាចត្រូវបានចាត់វិធានការដោយបុគ្គល និងដោយសមូហភាព

៨. ឥរិយាបថទទួលខុសត្រូវប្រកបដោយសីលធម៌

៩. ការចូលរួម និងការចាត់វិធានការ

ដោយផ្អែកទៅលើប្រធានបទទាំងនេះ វត្ថុបំណងនៃការសិក្សាដែលជាក់លាក់និងសមស្របទៅតាមអាយុ និងខ្លឹមសារសំខាន់ ត្រូវបានអភិវឌ្ឍឡើង។

## ២.៥. វត្ថុបំណង

សម្រាប់ប្រធានបទនីមួយៗដែលត្រូវបានលើកឡើងពីខាងដើម វត្ថុបំណងនៃការសិក្សាជាក់លាក់និងខ្លឹមសារដែលទាក់ទងចំនួន៤ ត្រូវបានណែនាំ ដោយឆ្លើយតបទៅនឹងក្រុមអាយុ និងកម្រិតនៃការសិក្សាផ្សេងៗគ្នា ដូចដែលបានបង្ហាញនៅខាងក្រោម ៖

- ថ្នាក់មុនបឋមសិក្សា និងបឋមសិក្សាកម្រិតទាប (អាយុចន្លោះពី៥ទៅ៨ឆ្នាំ)
- បឋមសិក្សាកម្រិតខ្ពស់ (អាយុចន្លោះពី៩ទៅ១២ឆ្នាំ)
- មធ្យមសិក្សាបឋមភូមិ (អាយុចន្លោះពី១២ទៅ១៥ឆ្នាំ)
- មធ្យមសិក្សាទុតិយភូមិ (អាយុចន្លោះពី១៥ទៅ១៨ឆ្នាំ និងខ្ពស់ជាងនេះ)

គោលបំណងគឺបង្ហាញវត្ថុបំណងនៃកាសិក្សា ទៅតាមកម្រិតនៃភាពស្មុគស្មាញ ដោយផ្តល់ឱ្យនូវវិធីសាស្រ្តនៃ«កម្មវិធីសិក្សាវិលជុំ»មួយ ដែលតាមរយៈវិធីសាស្រ្តនេះ ទស្សនាទានទាំងឡាយដែលពាក់ព័ន្ធនឹងការអប់រំភាពជាពលរដ្ឋសកល អាចត្រូវបានណែនាំទៅដល់កម្រិតថ្នាក់មុនបឋមសិក្សា ឬបឋមសិក្សាកម្រិតទាប និងត្រូវបានបង្រៀនឱ្យកាន់តែស៊ីជម្រៅនិងស្មុគស្មាញឡើង នៅពេលអ្នកសិក្សាកាន់តែពេញវ័យ នៅគ្រប់កម្រិតទាំងអស់នៃការអប់រំ។ ដោយសារប្រព័ន្ធអប់រំ កម្រិតនៃការអប់រំ និងក្រុមអាយុរបស់សិស្ស ខុសគ្នាៗពីប្រទេសមួយទៅប្រទេសមួយ ក្រុមទាំងនេះគឺគ្រាន់តែជាសញ្ញាចង្អុលបង្ហាញតែប៉ុណ្ណោះ។ អ្នកប្រើប្រាស់គួរតែមានសេរីភាពក្នុងការជ្រើសរើស យកលំនាំតាម និងរៀបចំវត្ថុបំណងនៃការសិក្សា នៅក្នុងរបៀបមួយដែលសមស្រប ទៅតាមបរិបទជាក់លាក់ និងការត្រៀមខ្លួនរបស់សិស្ស នៅក្នុងប្រទេសរបស់ពួកគេ។[8]

---

[8] នៅក្នុងអំឡុងពេលនៃដំណើរការនៃការត្រួតពិនិត្យ មានទស្សនខុសគ្នាមួយចំនួន ទាក់ទងទៅនឹងភាពសមស្របនៃអាយុ ប្រធានបទ និងវត្ថុបំណងនៃការសិក្សាមួយចំនួន ជាពិសេសនៅកម្រិតថ្នាក់មុនបឋមសិក្សា និងបឋមសិក្សាកម្រិតទាប។ អ្នកត្រួតពិនិត្យមួយចំនួនបានគូសបញ្ជាក់ថា សមត្ថភាពរបស់កុមារតូចៗក្នុងការស្វែងយល់

## ២.៦. ពាក្យគន្លិះ

ដើម្បីលើកទឹកចិត្តនិងសម្រួលដល់ការពិភាក្សានិងសកម្មភាព ដែលផ្អែកទៅលើប្រធានបទនិងវត្ថុបំណងនៃការសិក្សា ដែលត្រូវបានបង្ហាញនៅក្នុងសៀវភៅណែនាំនេះ បញ្ជីរាយនាមពាក្យគន្លិះត្រូវបានផ្តល់ឱ្យនិងរៀបចំទៅតាមខ្លឹមសារ។

បញ្ជីនេះអាចត្រូវបានបំពេញបន្ថែម ជាមួយនឹងប្រធានបទទាំងឡាយ ដែលសមស្របនៅក្នុងបរិបទរៀងៗខ្លួន។

## ២.៧. តារាងណែនាំ

តារាងទាំងឡាយខាងក្រោម បង្ហាញបណ្តុំនៃការសិក្សាទាំងបី លទ្ធផលសិក្សាសំខាន់ៗ គុណសម្បត្តិអ្នកសិក្សាសំខាន់ៗ ប្រធានបទ និងវត្ថុបំណងនៃការសិក្សាប្រកបដោយការឆ្លើយតប សម្រាប់ក្រុមអាយុនិងកម្រិតនៃការអប់រំផ្សេងៗគ្នា ក៏ដូចជាពាក្យគន្លិះសម្រាប់ការពិភាក្សា។

- **តារាង ក** បង្ហាញតារាងណែនាំ និងបង្ហាញអំពីរបៀបដែលផ្នែកផ្សេងៗមានទំនាក់ទំនងគ្នា។
- **តារាង ខ** គឺជាការរៀបរាប់លម្អិតទៅលើ «តារាង ក»។ តារាងនេះបង្ហាញវត្ថុបំណងនៃការសិក្សាលម្អិត ទៅតាមអាយុ និងកម្រិតអប់រំសម្រាប់ប្រធានបទនីមួយៗ។
- **តារាង ខ.១ ទៅ ខ.៩** រៀបរាប់លម្អិតទៅលើប្រធានបទនិងវត្ថុបំណងនៃការសិក្សានីមួយៗ និងផ្តល់សេចក្តីលម្អិតបន្ថែមទៀត អំពីអ្វីដែលអ្នកសិក្សាត្រូវបានរំពឹងថាត្រូវដឹង យល់ និងអាចធ្វើបាន ក៏ដូចជាចំណេះដឹង ជំនាញ តម្លៃ និងឥរិយាបថ ដែលអ្នកសិក្សាត្រូវបានរំពឹងថា នឹងអភិវឌ្ឍនៅក្នុងដំណាក់កាលផ្សេងៗគ្នានៃការសិក្សា។ តារាង

---

ទស្សនរបៀបនេះ មិនគួរត្រូវបានមើលស្រាល ខណៈដែលអ្នកផ្សេងទៀតមានអារម្មណ៍ថា ទស្សនដែលត្រូវបានស្នើឡើង ប្រហែលជាស្មុគស្មាញពេកសម្រាប់កុមារតូចៗ។ វិធីមួយក្នុងការដោះស្រាយជាមួយនឹងបញ្ហាបែបនេះ គឺត្រូវធ្វើការណែនាំទស្សនទាំងនេះ ទៅតាមអាយុសមស្រប និងវិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិតនិងអន្តរសកម្មភាព ដូចជាការសម្តែង គំនូរជីវចល ឬតាមវិធីសាស្ត្រណាក៏ដោយ ដែលអ្នកអប់រំយល់ថាសមស្របនៅក្នុងបរិបទរបស់ពួកគេរៀងៗខ្លួន។

ទាំងអស់ត្រូវបានរៀបទៅតាមដំណាក់កាល។ ដូច្នេះ កម្រិតនីមួយៗរួមមានវត្ថុបំណង នៃការសិក្សានិងខ្លឹមសារ ដែលសមស្របទៅតាមអាយុ ដែលផ្តល់ឱ្យនូវបណ្តុំចំណេះដឹងរឹងមាំមួយសម្រាប់កម្រិតបន្ទាប់ ដែលផ្លាស់ប្តូរប្រធានបទសាមញ្ញ ទៅប្រធានបទស្មុគស្មាញជាងមួយ។

- **តារាង គ** បង្ហាញតារាងពាក្យគន្លឹះ ដែលអាចជម្រុញលើកទឹកចិត្ត និងសម្រួលដល់ការពិភាក្សានិងសកម្មភាពពាក់ព័ន្ធ។

តារាងទាំងនេះគឺជាសញ្ញាចង្អុលបង្ហាញ និងមិនមែនជាការដាក់បញ្ញត្ត ឬជាតារាងពេញលេញនោះទេ។ តារាងទាំងនេះអាចត្រូវបានប្រើប្រាស់ យកលំនាំតាម ឬបន្ថែម ស្របទៅតាមបរិបទនៅមូលដ្ឋាននិងជាតិ។

វាគួរត្រូវបានបញ្ជាក់ថា តារាងទាំងនេះបង្ហាញអំពីភាពជាតំណាងនៃទស្សនមួយ និងមិនមានន័យថា ការសិក្សានេះត្រូវធ្វើឡើងដាច់ដោយឡែកដោយឯកឯងនោះទេ។ នៅក្នុងដំណើរការនៃការបង្រៀននិងការរៀនជាក់ស្តែង ទស្សននិងសមាសធាតុទាំងអស់ មានទំនាក់ទំនងគ្នា និងជួយពង្រឹងគ្នាទៅវិញទៅមក។

## តារាង ក ៖ សេចក្តីណែនាំរួម

តារាង ក បង្ហាញរចនាសម្ព័ន្ធរួមនៃសេចក្តីណែនាំ ដោយផ្អែកលើបណ្តុំនៃការសិក្សាទាំងបី និងបង្ហាញលទ្ធផលសិក្សាសំខាន់ គុណសម្បត្តិអ្នកសិក្សាសំខាន់ៗ ប្រធានបទ និងវត្ថុបំណងសិក្សាឆ្លើយតប គួសបញ្ជាក់អំពីទំនាក់ទំនងគ្នារបស់ពួកគេទាំងខ្សែបណ្តោយនិងខ្សែទទឹង។

### ការអប់រំភាពជាពលរដ្ឋសកល

#### បណ្តុំនៃការសិក្សា

| ចំណេះដឹង | ចិត្តសង្គម | ឥរិយាបថ |
|---|---|---|
| **លទ្ធផលសិក្សាសំខាន់ៗ** | | |
| ▪ អ្នកសិក្សាទទួលបានចំណេះដឹងនិងការយល់ដឹងអំពីបញ្ហានៅថ្នាក់មូលដ្ឋាន ជាតិ និងសកល និងទំនាក់ទំនងគ្នា និងការអាស្រ័យគ្នាទៅវិញទៅមកនៃប្រទេសនិងប្រជាជនផ្សេងៗគ្នា។<br>▪ អ្នកសិក្សាអភិវឌ្ឍជំនាញសម្រាប់ការត្រិះរិះពិចារណា និងការវិភាគ។ | ▪ អ្នកសិក្សាឆ្លងកាត់ពិសោធននៃអារម្មណ៍ថាជាផ្នែកមួយនៃមនុស្សជាតិទូទៅ ដោយចែករំលែកតម្លៃនិងការទទួលខុសត្រូវ ដោយផ្អែកលើទ្រឹស្តីសិទ្ធិមនុស្ស។<br>▪ អ្នកសិក្សាអភិវឌ្ឍឥរិយាបថនៃការអាណិតអាសូរ សាមគ្គីភាព និងការគោរពចំពោះភាពខុសគ្នា និងពិពិធភាព។ | ▪ អ្នកសិក្សាប្រព្រឹត្តិប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវ នៅថ្នាក់មូលដ្ឋាន ជាតិ និងសកល សម្រាប់ពិភពលោកដែលមានសន្តិភាពនិងនិរន្តរភាពជាងមួយ។<br>▪ អ្នកសិក្សាអភិវឌ្ឍការជំរុញលើកទឹកចិត្តនិងការស្ម័គ្រចិត្តក្នុងការចាត់វិធានការចាំបាច់។ |
| **គុណសម្បត្តិអ្នកសិក្សាសំខាន់ៗ** | | |
| **ចំណេះដឹងនិងការត្រិះរិះពិចារណា**<br>▪ ដឹងអំពីបញ្ហា អភិបាលកិច្ច ប្រព័ន្ធ និងរចនាសម្ព័ន្ធ នៅថ្នាក់មូលដ្ឋាន ជាតិ និងសកល។<br>▪ យល់អំពីភាពអាស្រ័យគ្នាទៅវិញទៅមក និងទំនាក់ទំនង | **ទំនាក់ទំនងក្នុងសង្គមនិងការគោរពចំពោះពិពិធភាព**<br>▪ បណ្តុះនិងគ្រប់គ្រងអត្តសញ្ញាណ ទំនាក់ទំនង និងអារម្មណ៍នៃភាពជាចំណែកមួយ។ | **ការទទួលខុសត្រូវនិងការចូលរួមប្រកបដោយសីលធម៌**<br>▪ អនុវត្តជំនាញ តម្លៃ ជំនឿ និងឥរិយាបថសមស្រប។<br>▪ បង្ហាញអំពីកតព្វកិច្ចបុគ្គល និងសង្គម សម្រាប់ពិភព |

| | | |
|---|---|---|
| រវាងការខ្វល់ខ្វាយនៅថ្នាក់មូលដ្ឋាននិងសកល។<br>▪ អភិវឌ្ឍជំនាញសម្រាប់ការចោទសួរប្រកបដោយការត្រិះរិះពិចារណា និងការវិភាគ។ | ▪ ចែករំលែកតម្លៃនិងការទទួលខុសត្រូវ ដោយផ្អែកលើទ្រឹស្តីសិទ្ធិមនុស្ស។<br>▪ អភិវឌ្ឍឥរិយាបថ ក្នុងការកោតសរសើរនិងគោរពភាពខុសគ្នា និងពិពិធភាព។ | លោកមួយដែលសន្តិភាពនិងនិរន្តរភាព។<br>▪ អភិវឌ្ឍការជំរុញលើកទឹកចិត្ត និងការស្ម័គ្រចិត្ត ក្នុងការខ្វល់ខ្វាយសម្រាប់ភាពល្អប្រសើររួម។ |
| **ប្រធានបទ** | | |
| ១. ប្រព័ន្ធនិងរចនាសម្ព័ន្ធមូលដ្ឋានជាតិ និងសកល<br>២. បញ្ហាដែលប៉ះពាល់ដល់អន្តរកម្មនិងទំនាក់ទំនងនៃសហគមន៍ទាំងឡាយ នៅកម្រិតមូលដ្ឋាន ជាតិ និងសកល<br>៣. ឥទ្ធិពលនៃការសន្មត់ និងថាមពលនៃអំណាច | ៤. កម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណ<br>៥. សហគមន៍ផ្សេងៗគ្នាដែលជាចំណែករបស់មនុស្ស និងរបៀបដែលពួកគេត្រូវបានផ្សាភ្ជាប់<br>៦. ភាពខុសគ្នា និងការគោរពចំពោះពិពិធភាព | ៧. សកម្មភាពដែលអាចត្រូវបានធ្វើឡើងដោយបុគ្គលនិងដោយសមូហភាព<br>៨. អាកប្បកិរិយាទទួលខុសត្រូវប្រកបដោយសីលធម៌<br>៩. ការចូលរួមនិងការចាត់វិធានការ |

| **វត្ថុបំណងនៃការសិក្សាតាមអាយុ និងកម្រិតនៃការសិក្សា** | | | |
|---|---|---|---|
| ថ្នាក់មុនបឋមសិក្សា និងបឋមសិក្សាកម្រិតទាប (៥-៩ឆ្នាំ) | ថ្នាក់បឋមសិក្សាកម្រិតខ្ពស់ (៩-១២ឆ្នាំ) | មធ្យមសិក្សាបឋមភូមិ (១២-១៥ឆ្នាំ) | មធ្យមសិក្សាទុតិយភូមិ (១៥-១៨ឆ្នាំ និងខ្ពស់ជាងនេះ) |

## តារាង ខ ៖ ប្រធានបទ និងវត្ថុបំណងនៃការសិក្សាលម្អិត

តារាងនេះគឺជាសេចក្តីលម្អិតនៃតារាង ក ដោយបានផ្តល់យោបល់ចំពោះវត្ថុបំណងនៃការសិក្សា សម្រាប់ប្រធានបទនីមួយៗនៅក្នុងតរាង ក។ ដោយសារកម្រិតនៃការអប់រំ ក៏ដូចជាការត្រៀមខ្លួនរបស់សិស្ស មានភាពខុសៗគ្នាទៅតាមប្រទេស អាយុ និងកម្រិតនៃការអប់រំ បណ្តុំវត្ថុបំណងនៃការសិក្សា ដែលត្រូវបានផ្តល់យោបល់ឱ្យនៅទីនេះ គឺគ្រាន់តែជាការចង្អុលបង្ហាញ និងអាចត្រូវបានយកលំនាំតាម ទៅតាមភាពសមស្របដែលអ្នកប្រើប្រាស់យល់ឃើញ។

ប្រធានបទនិងវត្ថុបំណងនៃការសិក្សា ត្រូវបានរៀបរាប់លម្អិតបន្ថែមទៀតនៅក្នុងតារាង ខ.១ ដល់ ខ.៩ ដូចខាងក្រោម។

| ប្រធានបទ | វត្ថុបំណងនៃការសិក្សា | | | |
|---|---|---|---|---|
| | ថ្នាក់មុនបឋមសិក្សា និងបឋមសិក្សាកម្រិតទាប (៥-៩ឆ្នាំ) | ថ្នាក់បឋមសិក្សាកម្រិតខ្ពស់ (៩-១២ឆ្នាំ) | ថ្នាក់មធ្យមសិក្សាបឋមភូមិ (១២-១៥ឆ្នាំ) | ថ្នាក់មធ្យមសិក្សាទុតិយភូមិ (១៥-១៨ឆ្នាំ និងខ្ពស់ជាងនេះ) |
| ១. ប្រព័ន្ធនិងរចនាសម្ព័ន្ធកម្រិតមូលដ្ឋាន ជាតិ និងសកល | រៀបរាប់អំពីរបៀបដែលបរិស្ថាននៅកម្រិតមូលដ្ឋានត្រូវបានរៀបចំ និងរបៀបដែលវាផ្សាភ្ជាប់ទៅពិភពលោកធំធេងជាងមុន និងណែនាំអំពីទស្សនៃភាពជាពលរដ្ឋ | កំណត់រចនាសម្ព័ន្ធអភិបាលកិច្ច ដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងសមាសធាតុនៃភាពជាពលរដ្ឋ | ពិភាក្សាអំពីរបៀបដែលរចនាសម្ព័ន្ធអភិបាលកិច្ចសកល ធ្វើអន្តរកម្មជាមួយរចនាសម្ព័ន្ធមូលដ្ឋាននិងជាតិ និងស្វែងយល់ភាពជាពលរដ្ឋសកល | វិភាគប្រកបដោយការត្រិះរិះពិចារណាទៅលើប្រព័ន្ធអភិបាលកិច្ច រចនាសម្ព័ន្ធ និងដំណើរការ និងវាយតម្លៃអំពីផលប៉ះពាល់ទៅលើភាពជាពលរដ្ឋសកល |
| ២. បញ្ហាដែលប៉ះពាល់ដល់អន្តរកម្មនិងទំនាក់ទំនងនៃសហគមន៍ទាំងឡាយ នៅកម្រិតមូលដ្ឋាន ជាតិ និងសកល | រាយបញ្ហាចម្បងៗនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល និងស្វែងយល់អំពីរបៀបដែលបញ្ហាទាំងនេះអាចមានទំនាក់ទំនងគ្នា | ស៊ើបអង្កេតទៅលើមូលហេតុដែលនៅពីក្រោយការខ្វល់ខ្វាយរួមជាសកលចម្បងៗ និងផលប៉ះពាល់របស់វានៅកម្រិតមូលដ្ឋាននិងជាតិ | វាយតម្លៃទៅលើឫសគល់នៃបញ្ហាចម្បងៗនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល និងភាពទាក់ទងគ្នានៃកត្តាមូលដ្ឋាននិងសកល | ពិនិត្យមើលប្រកបដោយការត្រិះរិះពិចារណាទៅលើបញ្ហាការទទួលខុសត្រូវ និងលទ្ធផលនៃការធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល និងពិនិត្យមើល និងស្នើការឆ្លើយតបសមស្រប |

| | | | | |
|---|---|---|---|---|
| ៣. ឥទ្ធិពលនៃការសន្ទត់ និងថាមពលនៃអំណាច | ដាក់ឈ្មោះប្រភពផ្សេងៗគ្នានៃព័ត៌មាន និងអភិវឌ្ឍជំនាញបឋមសម្រាប់ការចោទសួរ | បង្ហាញភាពខុសគ្នារវាងការពិតនិងទស្សន ភាពជាក់ស្តែងនិងការប្រឌិតនិងទស្សននិងគោលគំនិតផ្សេងៗគ្នា | ស៊ើបអង្កេតឥទ្ធិពលនៃការសន្ទត់ និងពណ៌នាវិសមភាព និងថាមពលនៃអំណាច | វាយតម្លៃប្រកបដោយការត្រិះរិះពិចារណារបៀបដែលថាមពលនៃអំណាចប៉ះពាល់ទៅលើសម្លេង ឥទ្ធិពលការទទួលបាននូវប្រភពធនធាន ការធ្វើសេចក្តីសម្រេចចិត្ត និងអភិបាលកិច្ច |
| ៤. កម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណ | ទទួលស្គាល់អំពីរបៀបដែលយើងអាចសម្របខ្លួន និងធ្វើអន្តរកម្មជាមួយពិភពលោក និងអភិវឌ្ឍជំនាញទំនាក់ទំនងជាមួយខ្លួនឯង និងទំនាក់ទំនងជាមួយអ្នកដទៃ | ពិនិត្យមើលកម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណនិងផលប៉ះពាល់របស់ពួកគេក្នុងការគ្រប់គ្រងទំនាក់ទំនងជាមួយអ្នកដទៃ | បែងចែកភាពខុសគ្នារវាងអត្តសញ្ញាណបុគ្គលនិងអត្តសញ្ញាណរួម និងក្រុមសង្គមផ្សេងៗទៀត និងបណ្តុះគំនិតថាខ្លួនជាផ្នែកមួយនៃមនុស្សជាតិទូទៅ | ពិនិត្យមើលប្រកបដោយកាត្រិះរិះពិចារណាអំពីរបៀបដែលកម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណ មានអន្តរកម្មនិងរស់នៅជាមួយក្រុមសង្គមផ្សេងៗគ្នាប្រកបដោយសន្តិភាព |
| ៥. សហគមន៍ផ្សេងៗគ្នាដែលជាចំណែករបស់មនុស្ស និងរបៀបដែលពួកគេត្រូវបានផ្សាភ្ជាប់ | ពន្យល់ភាពខុសគ្នានិងទំនាក់ទំនងរវាងក្រុមសង្គមផ្សេងៗគ្នា។ | ប្រៀបធៀបនិងប្រៀបផ្ទុយបទដ្ឋានច្បាប់ វប្បធម៌ និងសង្គមដែលមានលក្ខណៈរួមនិងផ្សេងៗគ្នា | បង្ហាញការកោតសរសើរនិងការគោរពចំពោះភាពផ្សេងគ្នានិងពិពិធភាព និងបណ្តុះសេចក្តីអាណិតអាសូរនិងសាមគ្គីភាពទៅកាន់បុគ្គលនិងក្រុមសង្គមផ្សេងទៀត | វាយតម្លៃប្រកបដោយការត្រិះរិះពិចារណាទំនាក់ទំនងរវាងក្រុមសហគមន៍ និងប្រទេសខុសៗគ្នា |
| ៦. ភាពខុសគ្នា និងការគោរពចំពោះពិពិធភាព | បែងចែករវាងភាពដូចគ្នានិងភាពផ្សេងគ្នា និងទទួលស្គាល់ថាមនុស្សគ្រប់រូបមានសិទ្ធិនិងការទទួលខុសត្រូវ | បណ្តុះទំនាក់ទំនងល្អជាមួយបុគ្គលនិងក្រុមប្រកបដោយពិពិធភាព | ជជែកដេញដោលទៅលើផលប្រយោជន៍និងបញ្ហាប្រឈមនៃភាពផ្សេងគ្នានិងពិពិធភាព | អភិវឌ្ឍនិងអនុវត្តនូវតម្លៃ ឥរិយាបថ និងជំនាញ ដើម្បីគ្រប់គ្រងនិងចូលរួមជាមួយក្រុមនិងគោលគំនិតប្រកបដោយពិពិធភាព |
| ៧. សកម្មភាពដែលអាចត្រូវបានធ្វើឡើងដោយបុគ្គលនិងដោយសមូហភាព | ស្វែងយល់អំពីវិធីទាំងឡាយដែលអាចធ្វើបានក្នុងការចាត់វិធានការដើម្បីធ្វើឱ្យពិភពលោកដែលយើងរស់នៅមានភាពល្អប្រសើរ | ពិភាក្សាអំពីសារសំខាន់នៃសកម្មភាពជាបុគ្គលនិងសកម្មភាពជាសមូហភាព និងការចូលរួមនៅក្នុងកិច្ចការសហគមន៍ | ពិនិត្យមើលអំពីរបៀបដែលបុគ្គលនិងក្រុមចាត់វិធានការទៅលើបញ្ហាដែលមានសារសំខាន់នៅថ្នាក់មូលដ្ឋាន ជាតិ និងសកលនិងចូលរួមនៅក្នុងការឆ្លើយតបទៅនឹងបញ្ហា | អភិវឌ្ឍនិងអនុវត្តជំនាញដើម្បីអនុវត្តការចូលរួមរបស់ពលរដ្ឋប្រកបដោយប្រសិទ្ធភាព |

| | | | | |
|---|---|---|---|---|
| | | | ទាំងនោះនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល | |
| ៨. អាកប្បកិរិយាទទួលខុសត្រូវប្រកបដោយសីលធម៌ | ពិភាក្សាអំពីរបៀបដែលជម្រើសនិងសកម្មភាពរបស់យើង ប៉ះពាល់ទៅដល់អ្នកដទៃនិងភពផែនដី និងប្រកាន់យកនូវអាកប្បកិរិយាប្រកបដោយការទទួលខុសត្រូវ | យល់អំពីទស្សនាទាននៃយុត្តិធម៌សង្គមនិងកតព្វកិច្ចប្រកបដោយសីលធម៌ និងសិក្សាអំពីរបៀបក្នុងការអនុវត្តទស្សនាទានទាំងនេះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ | វិភាគបញ្ហាប្រឈមនិងទ្វេគ្រោះដែលពាក់ព័ន្ធជាមួយនឹងយុត្តិធម៌សង្គមនិងកតព្វកិច្ចប្រកបដោយសីលធម៌ និងពិចារណាផលប៉ះពាល់ទៅលើសកម្មភាពជាបុគ្គលនិងសកម្មភាពជាសមូហភាព | វាយតម្លៃប្រកបដោយការត្រិះរិះពិចារណាទៅលើបញ្ហាយុត្តិធម៌សង្គមនិងកតព្វកិច្ចប្រកបដោយសីលធម៌ និងចាត់វិធានការក្នុងការជំនះការរើសអើងនិងវិសមភាព |
| ៩. ការចូលរួមនិងការចាត់វិធានការ | ទទួលស្គាល់សារសំខាន់និងផលប្រយោជន៍នៃការចូលរួមរបស់ពលរដ្ឋ | កំណត់កាលានុវត្តភាពសម្រាប់ការចូលរួមនិងផ្តួចផ្តើមសកម្មភាព | អភិវឌ្ឍជំនាញសម្រាប់ការចូលរួមយ៉ាងសកម្មនិងចាត់វិធានការដើម្បីជំរុញភាពល្អប្រសើររួម | ស្នើវិធានការ និងធ្វើខ្លួនឱ្យទៅជាភ្នាក់ងារសម្រាប់ការផ្លាស់ប្តូរដោយវិជ្ជមាន |

## ខ.១. ប្រធានបទ ៖ ប្រព័ន្ធ និង រចនាសម្ព័ន្ធ កម្រិតមូលដ្ឋាន ជាតិ និងសកល

**ថ្នាក់មុនបឋមសិក្សា និង បឋមសិក្សាកម្រិតទាប (៥-៩ឆ្នាំ)**

**វត្ថុបំណងនៃការសិក្សា ៖ រៀបរាប់អំពីរបៀបដែលបរិស្ថាននៅកម្រិតមូលដ្ឋានត្រូវបានរៀបចំ និងរបៀបដែលវាផ្សារភ្ជាប់ទៅពិភពលោកធំធេងជាងមួយ និងណែនាំអំពីទស្សនៃភាពជាពលរដ្ឋ**

**ខ្លឹមសារសំខាន់ៗ ៖**

- ➢ ខ្លួនឯង គ្រួសារ សាលា ភូមិស្ថាន សហគមន៍ ប្រទេស ពិភពលោក
- ➢ របៀបដែលពិភពលោកត្រូវបានរៀបចំ (ក្រុម សហគមន៍ ភូមិ ក្រុង ប្រទេស តំបន់
- ➢ ទំនាក់ទំនង សមាជិកភាព ការធ្វើច្បាប់ និងការចូលរួម (គ្រួសារ មិត្តភក្តិ សាលា សហគមន៍ ប្រទេស ពិភពលោក)
- ➢ ហេតុអ្វីបានជាច្បាប់និងកតព្វកិច្ចកើតមាន និងហេតុអ្វីបានជាពួកគេប្រហែលជាត្រូវផ្លាស់ប្តូរទៅតាមពេលវេលា។

**ថ្នាក់បឋមសិក្សាកម្រិតខ្ពស់ (៩-១២ឆ្នាំ)**

**វត្ថុបំណងនៃការសិក្សា ៖ កំណត់រចនាសម្ព័ន្ធអភិបាលកិច្ច ដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងសមាសធាតុនៃភាពជាពលរដ្ឋ**

**ខ្លឹមសារសំខាន់ៗ ៖**

- ➢ ប្រព័ន្ធនិងរចនាសម្ព័ន្ធអភិបាលកិច្ចកម្រិតមូលដ្ឋាន ជាតិ និងសកល និងរបៀបដែលប្រព័ន្ធនិងរចនាសម្ព័ន្ធទាំងនេះ មានទំនាក់ទំនងគ្នានិងអាស្រ័យគ្នាទៅវិញទៅមក (ពាណិជ្ជកម្ម ទេសន្តប្រវេសន៍ បរិស្ថាន សារព័ត៌មាន អង្គការអន្តរជាតិ សម្ព័ន្ធភាពនយោបាយនិងសេដ្ឋកិច្ច វិស័យសាធារណៈនិងឯកជន និងសង្គមស៊ីវិល
- ➢ ភាពប្រហាក់ប្រហែលគ្នានិងភាពខុសគ្នា នៅក្នុងសិទ្ធិនិងកតព្វកិច្ច បទបញ្ញត្តនិងការសម្រេចចិត្ត និងរបៀបដែលសង្គមផ្សេងៗគ្នាលើកកម្ពស់ភាពប្រហាក់ប្រហែលគ្នានិងភាពខុសគ្នាទាំងនេះ (ដោយរួមទាំងការពិនិត្យមើលទៅលើប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងវប្បធម៌)
- ➢ ភាពប្រហាក់ប្រហែលគ្នានិងភាពខុសគ្នា អំពីរបៀបដែលភាពជាពលរដ្ឋត្រូវបានកំណត់
- ➢ អភិបាលកិច្ចល្អ នីតិរដ្ឋ ដំណើរការប្រជាធិបតេយ្យ និងតម្លាភព

**ថ្នាក់មធ្យមសិក្សាបឋមភូមិ (១២-១៥ឆ្នាំ)**

**ថ្នាក់មធ្យមសិក្សាទុតិយភូមិ (១៥-១៨ឆ្នាំ និងខ្ពស់ជាងនេះ)**

| | |
|---|---|
| **វត្ថុបំណងនៃការសិក្សា ៖ ពិភាក្សាអំពីរបៀបដែលរចនាសម្ព័ន្ធអភិបាលកិច្ចសកល ធ្វើអន្តរកម្មជាមួយរចនាសម្ព័ន្ធមូលដ្ឋាននិងជាតិ និងស្វែងយល់ភាពជាពលរដ្ឋសកល**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ បរិបទជាតិនិងប្រវត្តិសាស្ត្ររបស់ខ្លួន ទំនាក់ទំនង ការតភ្ជាប់ និងការអាស្រ័យគ្នាទៅវិញទៅមកជាមួយប្រទេសផ្សេងទៀត អង្គការអន្តរជាតិ និងបរិបទសកលទូលំទូលាយជាងមួយ (វប្បធម៌ សេដ្ឋកិច្ច បរិស្ថាន និងនយោបាយ)<br>➢ ដំណើរការនិងរចនាសម្ព័ន្ធអភិបាលកិច្ចសកល (នីតិរដ្ឋ ប្រព័ន្ធយុត្តិធម៌) និងការតភ្ជាប់គ្នាទៅវិញទៅមក ជាមួយនឹងប្រព័ន្ធអភិបាលកិច្ចកម្រិតមូលដ្ឋាននិងជាតិ<br>➢ របៀបដែលការសម្រេចចិត្តជាសកល ប៉ះពាល់ដល់បុគ្គល សហគមន៍ និងប្រទេស<br>➢ សិទ្ធិនិងកតព្វកិច្ចនៃភាពជាពលរដ្ឋ ទាក់ទងទៅនឹងក្របខណ្ឌសកល និងរបៀបដែលសិទ្ធិនិងកតព្វកិច្ចទាំងនេះត្រូវបានអនុវត្ត<br>➢ ឧទាហរណ៍នៃពលរដ្ឋសកល | **វត្ថុបំណងនៃការសិក្សា ៖ វិភាគប្រកបដោយការត្រិះរិះពិចារណាទៅលើប្រព័ន្ធអភិបាលកិច្ច រចនាសម្ព័ន្ធ និងដំណើរការ និងវាយតម្លៃអំពីផលប៉ះពាល់ទៅលើភាពជាពលរដ្ឋសកល**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ ប្រព័ន្ធអភិបាលកិច្ចសកល ដំណើរការនិងរចនាសម្ព័ន្ធ និងរបៀបដែលបទបញ្ញត្ត នយោបាយ និងការសម្រេចចិត្ត ត្រូវបានធ្វើឡើង និងអនុវត្តនៅក្នុងកម្រិតផ្សេងៗគ្នា។<br>➢ របៀបដែលបុគ្គល ក្រុម ដែលរួមទាំងវិស័យសាធារណៈនិងឯកជន ចូលរួមនៅក្នុងដំណើរការនិងរចនាសម្ព័ន្ធអភិបាលកិច្ចសកល<br>➢ ការឆ្លុះបញ្ចាំងប្រកបដោយការពិចារណា ទៅលើអ្វីដែលមានន័យថា ជាសមាជិកមួយរូបនៃសហគមន៍សកល និងអំពីរបៀបក្នុងការឆ្លើយតបទៅនឹងបញ្ហារួម (តួនាទី ការតភ្ជាប់ជាសកល ទំនាក់ទំនងគ្នាទៅវិញទៅមក សាមគ្គីភាព និងផលប៉ះពាល់មកលើជីវិតរស់នៅប្រចាំថ្ងៃ)<br>➢ វិសមភាពរវាងរដ្ឋប្រជាជាតិ និងផលប៉ះពាល់របស់ពួកគេនៅក្នុងការអនុវត្តសិទ្ធិនិងកតព្វកិច្ច ក្នុងអភិបាលកិច្ចសកល |

| **ខ.២. ប្រធានបទ ៖ បញ្ហាដែលប៉ះពាល់ដល់អន្តរកម្មនិងទំនាក់ទំនងនៃសហគមន៍ទាំងឡាយ នៅកម្រិតមូលដ្ឋាន ជាតិ និងសកល** | |
|---|---|
| **ថ្នាក់មុនបឋមសិក្សា និង បឋមសិក្សាកម្រិតទាប (៥-៩ឆ្នាំ)**<br>វត្ថុបំណងនៃការសិក្សា ៖ រាយបញ្ហាចម្បងៗនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល និងស្វែងយល់អំពីរបៀបដែលបញ្ហាទាំងនេះអាចមានទំនាក់ទំនងគ្នា<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ បញ្ហាទាំងឡាយដែលប៉ះពាល់ដល់សហគមន៍មូលដ្ឋាន (បរិស្ថាន សង្គម នយោបាយ សេដ្ឋកិច្ច ឬបញ្ហាផ្សេងៗទៀត)<br>➢ បញ្ហាប្រហាក់ប្រហែលគ្នាឬខុសគ្នា ដែលសហគមន៍ផ្សេងទៀតនៅក្នុងប្រទេសដូចគ្នា ឬប្រទេសផ្សេងទៀត កំពុងប្រឈមមុខ<br>➢ ផលប៉ះពាល់នៃបញ្ហាសកល ចំពោះជីវិតរស់នៅរបស់បុគ្គល និងសហគមន៍ | **ថ្នាក់បឋមសិក្សាកម្រិតខ្ពស់ (៩-១២ឆ្នាំ)**<br>វត្ថុបំណងនៃការសិក្សា ៖ ស៊ើបអង្កេតទៅលើមូលហេតុដែលនៅពីក្រោយការខ្វល់ខ្វាយរួមជាសកលចម្បងៗ និងផលប៉ះពាល់របស់វានៅកម្រិតមូលដ្ឋាននិងជាតិ<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ ការផ្លាស់ប្តូរនិងការអភិវឌ្ឍជាសកល និងផលប៉ះពាល់របស់ពួកគេមកលើជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន<br>➢ បញ្ហាសកល (ការប្រែប្រួលអាកាសធាតុ ភាពក្រីក្រ វិសមភាពយែនឌ័រ ការបំពុលបរិស្ថាន ឧក្រិដ្ឋកម្ម ជម្លោះ ជំងឺ គ្រោះមហន្តរាយធម្មជាតិ) និងមូលហេតុនៃបញ្ហាទាំងនេះ<br>➢ ការតភ្ជាប់និងភាពអាស្រ័យគ្នាទៅវិញទៅមក រវាងបញ្ហានៅកម្រិតមូលដ្ឋាននិងសកល |
| **ថ្នាក់មធ្យមសិក្សាបឋមភូមិ (១២-១៥ឆ្នាំ)**<br>វត្ថុបំណងនៃការសិក្សា ៖ វាយតម្លៃទៅលើដើមហេតុនៃបញ្ហាចម្បងៗនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល និងភាពទាក់ទងគ្នានៃកត្តាមូលដ្ឋាន និងសកល<br><br>**ខ្លឹមសារសំខាន់ៗ ៖** | **ថ្នាក់មធ្យមសិក្សាទុតិយភូមិ (១៥-១៨ឆ្នាំ និងខ្ពស់ជាងនេះ)**<br>វត្ថុបំណងនៃការសិក្សា ៖ ពិនិត្យមើលប្រកបដោយការត្រិះរិះពិចារណាទៅលើបញ្ហា ការទទួលខុសត្រូវ និងលទ្ធផលនៃការធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល និងពិនិត្យមើលនិងស្នើការឆ្លើយតបសមស្រប |

| | |
|---|---|
| ➢ ការខ្វល់ខ្វាយរួមនៅកម្រិតមូលដ្ឋាន ជាតិ និងសកល និងមូលហេតុសំខាន់ៗ<br>➢ ការផ្លាស់ប្តូរកម្លាំងនិងទម្រង់ជាសកល និងផលប៉ះពាល់របស់ពួកគេទៅលើជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន<br>➢ របៀបដែលប្រវត្តិសាស្ត្រ ភូមិសាស្ត្រ នយោបាយ សេដ្ឋកិច្ច សាសនា បច្ចេកវិទ្យា សារព័ត៌មាន ឬកត្តាផ្សេងៗទៀត មានឥទ្ធិពលទៅលើបញ្ហាជាសកលនាពេលបច្ចុប្បន្ន (សេរីភាព ឬការបញ្ចេញមតិ ឋានៈរបស់ស្ត្រី ជនភៀសខ្លួន ទេសន្តរប្រវេសន៍ជន មរតកនៃអាណានិគមនិយម ទាសភាព ក្រុមភាគតិចនៃជាតិពន្ធុនិងសាសនា ការបំផ្លាញបរិស្ថាន)<br>➢ របៀបដែលការធ្វើសេចក្តីសម្រេចចិត្តជាសកល ឬនៅក្នុងផ្នែកមួយនៃពិភពលោក អាចប៉ះពាល់ដល់សុខុមាលភាពនាពេលបច្ចុប្បន្ននិងទៅអនាគត របស់ប្រជាជននិងបរិស្ថាននៅផ្នែកផ្សេងទៀត | **ខ្លឹមសារសំខាន់ៗ ៖**<br>➢ ការសួរដេញដោលទៅលើបញ្ហានិងគោលគំនិត នៅកម្រិតមូលដ្ឋាន ជាតិ និងអន្តរជាតិ ទៅលើ (ការរើសអើងយែនឌ័រ សិទ្ធិមនុស្ស ការអភិវឌ្ឍជានិរន្ត សន្តិភាពនិងជម្លោះ ជនភៀសខ្លួន ទេសន្តរប្រវេសន៍ គុណភាពបរិស្ថាន ភាពគ្មានការងារធ្វើរបស់យុវជន)<br>➢ ការវិភាគស៊ីជម្រៅទៅលើធម្មជាតិ នៃការតភ្ជាប់គ្នានៃបញ្ហាសកល (ដើមហេតុ កត្តា ភ្នាក់ងារ សមាសធាតុ អង្គការអន្តរជាតិ សាជីវកម្មពហុជាតិ)<br>➢ ការវាយតម្លៃទៅលើរបៀប ដែលដំណើរការនិងរចនាសម័ន្ធអភិបាលកិច្ចសកល ឆ្លើយតបទៅនឹងបញ្ហាសកល និងប្រសិទ្ធិភាពនិងភាពសមស្របនៃការឆ្លើយតប (ការសម្រុះសម្រួល មជ្ឈិត្តកម្ម ការដាក់ទណ្ឌកម្ម សម្ព័ន្ធភាព)<br>➢ ការឆ្លុះបញ្ចាំងប្រកបដោយការត្រិះរិះពិចារណា ទៅលើឥទ្ធិពលលើបញ្ហានិងភាពអាស្រ័យគ្នាទៅវិញទៅមកជាសកល នៃប្រវត្តិសាស្ត្រ ភូមិសាស្ត្រ នយោបាយ សេដ្ឋកិច្ច វប្បធម៌ និងកត្តាផ្សេងៗទៀត<br>➢ ការស្រាវជ្រាវ ការវិភាគ និងការធ្វើទំនាក់ទំនង ទៅលើបញ្ហាដែលមានការតភ្ជាប់រវាងកម្រិតមូលដ្ឋាននិងសកល (សិទ្ធិកុមារនិងការអភិវឌ្ឍជានិរន្ត) |

| ខ.៣. ប្រធានបទ ៖ ឥទ្ធិពលនៃការសន្ទត់ និង ថាមពលនៃអំណាច | |
|---|---|
| **ថ្នាក់មុនបឋមសិក្សា និង បឋមសិក្សាកម្រិតទាប (៥-៩ឆ្នាំ)**<br>**វត្ថុបំណងនៃការសិក្សា ៖ ដាក់ឈ្មោះប្រភពផ្សេងៗគ្នានៃព័ត៌មាន និងអភិវឌ្ឍជំនាញបឋមសម្រាប់ការចោទសួរ**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ ប្រភពផ្សេងៗគ្នានៃព័ត៌មាន និងការប្រមូលព័ត៌មាន ដោយប្រើប្រាស់ឧបករណ៍និងប្រភពជាច្រើន (មិត្តភក្តិ គ្រួសារ សហគមន៍មូលដ្ឋាន សាលារៀន គំនូរជីវចល សៀវភៅរឿង ភាពយន្តសារព័ត៌មាន)<br>➢ ស្តាប់និងប្រាស្រ័យទាក់ទង ប្រកបដោយភាពប្រត្យក្សនិងច្បាស់លាស់ (ជំនាញនៃការប្រាស្រ័យទាក់ទង និងភាសា)<br>➢ កំណត់គំនិតសំខាន់ៗ និងទទួលស្គាល់គោលគំនិតផ្សេងៗគ្នា | **ថ្នាក់បឋមសិក្សាកម្រិតខ្ពស់ (៩-១២ឆ្នាំ)**<br>**វត្ថុបំណងនៃការសិក្សា ៖ បង្ហាញភាពខុសគ្នារវាងការពិតនិងទស្សនភាពជាក់ស្តែងនិងការប្រឌិត និងទស្សននិងគោលគំនិតផ្សេងៗគ្នា**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ ចំណេះដឹងស្តីអំពីសារព័ត៌មាន និងជំនាញសារព័ត៌មានសង្គម (ទម្រង់ផ្សេងៗគ្នានៃសារព័ត៌មាន ដែលរួមទាំងសារព័ត៌មានសង្គម)<br>➢ ទស្សនផ្សេងៗគ្នា អញ្ញថាភាព ភស្តុតាង និងភាពលម្អៀង<br>➢ កត្តាទាំងឡាយដែលមានឥទ្ធិពលទៅលើទស្សន (យែនឌ័រ អាយុ សាសនា ជាតិពន្ធុ វប្បធម៌ សង្គមសេដ្ឋកិច្ច និងបរិបទភូមិសាស្ត្រ មនោគមវិជ្ជា និងជំនឿ ប្រព័ន្ធ ឬស្ថានភាពផ្សេងៗទៀត) |
| **ថ្នាក់មធ្យមសិក្សាបឋមភូមិ (១២-១៥ឆ្នាំ)**<br>**វត្ថុបំណងនៃការសិក្សា ៖ ស៊ើបអង្កេតឥទ្ធិពលនៃការសន្ទត់ និងពណ៌នាវិសមភាព និងថាមពលនៃអំណាច**<br><br>**ខ្លឹមសារសំខាន់ៗ ៖** | **ថ្នាក់មធ្យមសិក្សាទុតិយភូមិ (១៥-១៨ឆ្នាំ និងខ្ពស់ជាងនេះ)**<br>**វត្ថុបំណងនៃការសិក្សា ៖ វាយតម្លៃប្រកបដោយការត្រិះរិះពិចារណារបៀបដែលថាមពលនៃអំណាចប៉ះពាល់ទៅលើសម្លេង ឥទ្ធិពល ការ** |

| | |
|---|---|
| ➢ ទស្សនាទាននៃសមភាព វិសមភាព ការរើសអើង<br>➢ កត្តាទាំងឡាយដែលមានឥទ្ធិពលទៅលើវិសមភាព និងថាមពលនៃអំណាច និងបញ្ហាប្រឈមដែលមនុស្សមួយចំនួនជួបប្រទះ (ទេសន្តរប្រវេសន៍ជន ស្ត្រី យុវជន ប្រជាជនបន្ទាប់បន្សំ)<br>➢ ការវិភាគទៅលើទម្រង់នៃព័ត៌មានផ្សេងៗគ្នា ស្តីអំពីបញ្ហាសកល (កំណត់គំនិតសំខាន់ៗ ប្រមូលភស្តុតាង ប្រៀបធៀប និងប្រៀបផ្ទុយ ភាពប្រហាក់ប្រហែលគ្នានិងភាពខុសគ្នា ស្វែងរកទស្សនឬភាពលម្អៀង ទទួលស្គាល់សារប្រកបដោយជម្លោះ ប៉ាន់ស្មាននិងវាយតម្លៃព័ត៌មាន | ទទួលបាននូវប្រភពធនធាន ការធ្វើសេចក្តីសម្រេចចិត្ត និងអភិបាលកិច្ច<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ ការវិភាគទៅលើបញ្ហាសកលសហសម័យ ពីទស្សនៃថាមពលនៃអំណាច (សមភាពយែនឌ័រ ពិការភាព ភាពគ្មានការងារធ្វើរបស់យុវជន)<br>➢ កត្តាទាំងឡាយដែលសម្រួល ឬបង្អាក់ភាពជាពលរដ្ឋ និងការចូលរួមរបស់ពលរដ្ឋ នៅកម្រិតមូលដ្ឋាន ជាតិ និងសកល (វិសមភាពសង្គមនិងសេដ្ឋកិច្ច ថាមពលនយោបាយ ទំនាក់ទំនងអំណាច ការធ្វើទុក្ខបុកម្នេញ ការរើសអើង រដ្ឋ អំណាចយោធា អំណាចនយោបាយ ចលនាសង្គម សហជីពពាណិជ្ជកម្ម)<br>➢ ការពិនិត្យមើលប្រកបដោយការត្រិះរិះពិចារណា ទៅលើទស្សនផ្សេងៗគ្នា គូបដិបក្ខ ឬទស្សនរបស់ក្រុមភាគតិច និងការរិះគន់ដែលរួមទាំងការវាយតម្លៃទៅលើតួនាទី របស់ប្រព័ន្ធផ្សព្វផ្សាយ និងសារព័ត៌មានសង្គម នៅក្នុងការជជែកដេញដោលជាសកល និងទៅលើភាពជាពលរដ្ឋសកល |

| ខ.៤. កម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណ | |
|---|---|
| ថ្នាក់មុនបឋមសិក្សា និង បឋមសិក្សាកម្រិតទាប (៥-៩ឆ្នាំ) | ថ្នាក់បឋមសិក្សាកម្រិតខ្ពស់ (៩-១២ឆ្នាំ) |
| **វត្ថុបំណងនៃការសិក្សា ៖ ទទួលស្គាល់អំពីរបៀបដែលយើងអាចសម្របខ្លួន និងធ្វើអន្តរកម្មជាមួយពិភពលោក និងអភិវឌ្ឍជំនាញទំនាក់ទំនងជាមួយខ្លួនឯង និងទំនាក់ទំនងជាមួយអ្នកដទៃ**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ អត្តសញ្ញាណផ្ទាល់ខ្លួន ជាកម្មសិទ្ធិ និងទំនាក់ទំនង (ខ្លួនឯង គ្រួសារ មិត្តភក្តិ សហគមន៍ តំបន់ ប្រទេស)<br>➢ កន្លែងដែលខ្ញុំរស់នៅ និងរបៀបដែលសហគមន៍របស់ខ្ញុំ ផ្សារភ្ជាប់ទៅនឹងពិភពលោកទូលំទូលាយជាងមួយ<br>➢ តម្លៃរបស់ខ្លួនឯង និងតម្លៃរបស់អ្នកដទៃ<br>➢ ធ្វើទំនាក់ទំនងជាមួយអ្នកដទៃ និងកសាងទំនាក់ទំនងជាវិជ្ជមាន<br>➢ ទទួលស្គាល់អារម្មណ៍ខ្លួនឯង និងអារម្មណ៍អ្នកដទៃ<br>➢ សួរនាំនិងផ្តល់ជំនួយ<br>➢ ការប្រាស្រ័យទាក់ទង ការខ្វល់ខ្វាយអំពីកិច្ចសហការ និងការយកចិត្តទុកដាក់ចំពោះអ្នកដទៃ | **វត្ថុបំណងនៃការសិក្សា ៖ ពិនិត្យមើលកម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណ និងផលប៉ះពាល់របស់ពួកគេក្នុងការគ្រប់គ្រងទំនាក់ទំនងជាមួយអ្នកដទៃ**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ របៀបដែលបុគ្គលផ្សារភ្ជាប់ទៅនឹងសហគមន៍ (តាមរយៈប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងសេដ្ឋកិច្ច)<br>➢ របៀបដែលយើងតភ្ជាប់ជាមួយពិភពលោកទូលំទូលាយជាងមួយ ហួសពីសហគមន៍ដែលយើងកំពុងរស់នៅ និងតាមរយៈបែបបទផ្សេងៗគ្នា (ព័ត៌មាន ការធ្វើដំណើរ តន្ត្រី កីឡា និងវប្បធម៌)<br>➢ រដ្ឋប្រជាជាតិ អង្គការនិងអង្គភាពអន្តរជាតិ សាជីវកម្មពហុជាតិ<br>➢ សេចក្តីអាណិតអាសូរ សាមគ្គីភាព ការគ្រប់គ្រងជម្លោះ ការដោះស្រាយជម្លោះ ការទប់ស្កាត់អំពើហិង្សា ដែលរួមទាំងអំពើហិង្សាផ្អែកលើយែនឌ័រ និងការធ្វើទុក្ខបុកម្នេញ<br>➢ ការចរចារ ការសម្របសម្រួល ការផ្សះផ្សា ដំណោះស្រាយឈ្នះឈ្នះ<br>➢ ការដាក់បញ្ញត្ត និងការគ្រប់គ្រងអារម្មណ៍ពុះកញ្ជ្រោល (វិជ្ជមាន និងអវិជ្ជមាន)<br>➢ ការប្រឆាំងទៅនឹងសម្ពាធអវិជ្ជមានពីមិត្តភក្តិ |

| ថ្នាក់មធ្យមសិក្សាបឋមភូមិ (១២-១៥ឆ្នាំ) | ថ្នាក់មធ្យមសិក្សាទុតិយភូមិ (១៥-១៨ឆ្នាំ និងខ្ពស់ជាងនេះ) |
| --- | --- |
| **វត្ថុបំណងនៃការសិក្សា ៖ បែងចែកភាពខុសគ្នារវាងអត្តសញ្ញាណបុគ្គលនិងអត្តសញ្ញាណរួម និងក្រុមសង្គមផ្សេងៗទៀត និងបណ្តុះគំនិតថាខ្លួនជាផ្នែកមួយនៃមនុស្សជាតិទូទៅ**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ ពហុអត្តសញ្ញាណ ដែលជាកម្មសិទ្ធិ និងពាក់ព័ន្ធទៅនឹងក្រុមផ្សេងៗគ្នា<br>➢ ភាពស្មុគស្មាញនៃអត្តសញ្ញាណបុគ្គល និងអត្តសញ្ញាណរួម ជំនឿនិងគោលគំនិត (បុគ្គល ក្រុម ក្រុមវិជ្ជាជីវៈ និងក្រុមពលរដ្ឋ)<br>➢ ការចូលរួម និងកិច្ចសហការនៅក្នុងគម្រោង ដើម្បីដោះស្រាយបញ្ហាប្រឈមរួម<br>➢ មានអារម្មណ៍ថាជាកម្មសិទ្ធិរបស់មនុស្សជាតិទូទៅ<br>➢ បណ្តុះទំនាក់ទំនងវិជ្ជមាន ជាមួយមនុស្សពីប្រភពផ្សេងៗនិងខុសៗគ្នា | **វត្ថុបំណងនៃការសិក្សា ៖ ពិនិត្យមើលប្រកបដោយការត្រិះរិះពិចារណាអំពីរបៀបដែលកម្រិតផ្សេងៗគ្នានៃអត្តសញ្ញាណ មានអន្តរកម្ម និងរស់នៅជាមួយក្រុមសង្គមផ្សេងៗគ្នាប្រកបដោយសន្តិភាព**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ អត្តសញ្ញាណបុគ្គល និងសមាជិកភាពនៅក្នុងបរិបទមូលដ្ឋាន ជាតិ តំបន់ និងសកល តាមរយៈពហុកញ្ចក់ឆ្លុះបញ្ចាំង<br>➢ អត្តសញ្ញាណរួម តម្លៃរួម និងផលប៉ះពាល់សម្រាប់ការបង្កើតវប្បធម៌ពលរដ្ឋសកលមួយ<br>➢ គោលគំនិងនិងសញ្ញាណ ប្រកបដោយភាពស្មុគស្មាញនិងពិពិធភាព នៃអត្តសញ្ញាណពលរដ្ឋ និងសមាជិកភាពទៅលើបញ្ហាឬព្រឹត្តិការសកល ឬតាមរយៈឧទាហរណ៍ផ្នែកវប្បធម៌ សេដ្ឋកិច្ច និងនយោបាយ (ក្រុមភាគតិច ជាតិពន្ធ និងសាសនា ជនភៀសខ្លួន មរតកជាប្រវត្តិសាស្ត្រនៃទាសភាព និងទេសន្តរប្រវេសន៍)<br>➢ កត្តាទាំងឡាយដែលនាំទៅដល់ ភាពជោគជ័យនៃការចូលរួមរបស់ពលរដ្ឋ (ផលប្រយោជន៍បុគ្គល និងផលប្រយោជន៍រួម ឥរិយាបថ តម្លៃ និងជំនាញ)<br>➢ ការប្តេជ្ញាចិត្តនៅក្នុងការលើកកម្ពស់ និងការការពារសុខុមាលភាពបុគ្គលនិងសមូហភាព |

## ខ.៥. សហគមន៍ផ្សេងៗគ្នាដែលជាចំណែករបស់មនុស្ស និងរបៀបដែលពួកគេត្រូវបានផ្សារភ្ជាប់

| ថ្នាក់មុនបឋមសិក្សា និង បឋមសិក្សាកម្រិតទាប (៥-៩ឆ្នាំ) | ថ្នាក់បឋមសិក្សាកម្រិតខ្ពស់ (៩-១២ឆ្នាំ) |
| --- | --- |
| **វត្ថុបំណងនៃការសិក្សា ៖ ពន្យល់ភាពខុសគ្នានិងទំនាក់ទំនងរវាងក្រុមសង្គមផ្សេងៗគ្នា។**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ ភាពប្រហាក់ប្រហែលគ្នា និងភាពខុសគ្នា នៅក្នុងនិងរវាងវប្បធម៌និងសង្គមទាំងឡាយ (យេនឌ័រ អាយុ ឋានៈសង្គមសេដ្ឋកិច្ច ប្រជាជនដែលទទួលរងការធ្វើទុក្ខបុកម្នេញ)<br>➢ ការតភ្ជាប់រវាងសហគមន៍<br>➢ តម្រូវការ និសិទ្ធិមនុស្សជាមូលដ្ឋានរួម<br>➢ ការឱ្យតម្លៃ និងការគោរពមនុស្សនិងសភាវៈមានជីវិតទាំងអស់ បរិស្ថាន និងវត្ថុ | **វត្ថុបំណងនៃការសិក្សា ៖ ប្រៀបធៀបនិងប្រៀបផ្ទុយបទដ្ឋានច្បាប់ វប្បធម៌ និងសង្គមដែលមានលក្ខណៈរួមនិងផ្សេងៗគ្នា**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ វប្បធម៌និងសង្គមផ្សេងៗគ្នា ដែលហួសពីពិសោធន៍ផ្ទាល់ខ្លួន និងតម្លៃនៃគោលគំនិតផ្សេងៗគ្នា<br>➢ ការធ្វើបទបញ្ញត្ត និងការចូលរួមនៅក្នុងផ្នែកផ្សេងៗនៃពិភពលោក និងនៅក្នុងចំណោមក្រុមផ្សេងៗ<br>➢ សញ្ញាណនៃយុត្តិធម៌ និងការទទួលបានយុត្តិធម៌<br>➢ ទទួលស្គាល់ និងគោរពពិពិធភាព |
| **ថ្នាក់មធ្យមសិក្សាបឋមភូមិ (១២-១៥ឆ្នាំ)**<br>**វត្ថុបំណងនៃការសិក្សា ៖ បង្ហាញការកោតសរសើរនិងការគោរពចំពោះភាពផ្សេងគ្នានិងពិពិធភាព និងបណ្តុះសេចក្តីអាណិតអាសូរ និងសាមគ្គីភាពទៅកាន់បុគ្គលនិងក្រុមសង្គមផ្សេងទៀត** | **ថ្នាក់មធ្យមសិក្សាទុតិយភូមិ (១៥-១៨ឆ្នាំ និងខ្ពស់ជាងនេះ)**<br>**វត្ថុបំណងនៃការសិក្សា ៖ វាយតម្លៃប្រកបដោយការត្រិះរិះពិចារណាទំនាក់ទំនងរវាងក្រុម សហគមន៍ និងប្រទេសខុសៗគ្នា**<br><br>**ខ្លឹមសារសំខាន់ៗ ៖** |

| | |
|---|---|
| **ខ្លឹមសារសំខាន់ៗ ៖**<br>➢ តម្លៃរួម និងតម្លៃបុគ្គល របៀបដែលតម្លៃទាំងពីរអាចខុសគ្នា និងអ្វីដែលសម្រួចតម្លៃទាំងពីរ<br>➢ សារៈសំខាន់នៃតម្លៃរួម (ការគោរព ការអត់ធ្មត់ ការយល់គ្នា សាមគ្គីភាព សេចក្ដីអាណិតអាសូរ ការយកចិត្តទុកដាក់ សមភាព បរិយាប័ន្ន សេចក្ដីថ្លៃថ្នូរបស់មនុស្ស) នៅក្នុងការរៀនរួមរស់នៅជាមួយគ្នាប្រកបដោយសន្តិភាព<br>➢ ការប្ដេជ្ញាចិត្តក្នុងការលើកកម្ពស់ និងការការពារភាពខុសគ្នា និងពិពិធភាព (សង្គមនិងបរិស្ថាន) | ➢ សិទ្ធិនិងការទទួលខុសត្រូវរបស់ពលរដ្ឋ ក្រុម និងរដ្ឋ នៅក្នុងសហគមន៍អន្តរជាតិ<br>➢ ទស្សនាទាននៃធម្មានុភាព នីតិរដ្ឋ នីតិវិធីត្រឹមត្រូវ និងយុត្តិធម៌<br>➢ ការលើកកម្ពស់សុខុមាលភាព នៅក្នុងសហគមន៍ និងការយល់ដឹងអំពីការគំរាមកំហែង និងសក្ដានុពលសម្រាប់សុខុមាលភាពនៅកម្រិតសកល<br>➢ លើកកម្ពស់ និងការពារសិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា |

| **ខ.៦. ភាពខុសគ្នា និងការគោរពចំពោះពិពិធភាព** | |
|---|---|
| **ថ្នាក់មុនបឋមសិក្សា និង បឋមសិក្សាកម្រិតទាប (៥-៩ឆ្នាំ)**<br>**វត្ថុបំណងនៃការសិក្សា ៖ បែងចែករវាងភាពដូចគ្នានិងភាពផ្សេងគ្នា និងទទួលស្គាល់ថាមនុស្សគ្រប់រូបមានសិទ្ធិនិងការទទួលខុសត្រូវ**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ អ្វីដែលធ្វើឱ្យយើងមានភាពប្រហាក់ប្រហែល និងអ្វីដែលធ្វើឱ្យយើងមានខុសគ្នាពីមនុស្សផ្សេងទៀត នៅក្នុងសហគមន៍ (ភាសា អាយុ វប្បធម៌ របៀបរស់នៅ ប្រពៃណី អត្តចរិត)<br>➢ សារៈសំខាន់នៃការគោរព និងទំនាក់ទំនងល្អសម្រាប់សុខុមាលភាពរបស់យើង<br>➢ រៀនស្ដាប់ យល់ យល់ស្រប និងមិនយល់ស្រប ទទួលយកទស្សននិងគោលគំនិតផ្សេងៗគ្នា<br>➢ គោរពអ្នកដទៃ និងគោរពខ្លួនឯង និងកោតសរសើរចំពោះភាពផ្សេងគ្នា | **ថ្នាក់បឋមសិក្សាកម្រិតខ្ពស់ (៩-១២ឆ្នាំ)**<br>**វត្ថុបំណងនៃការសិក្សា ៖ បណ្ដុះទំនាក់ទំនងល្អជាមួយបុគ្គលនិងក្រុមប្រកបដោយពិពិធភាព**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ យល់អំពីភាពប្រហាក់ប្រហែលគ្នា និងភាពខុសគ្នារវាងសង្គម និងវប្បធម៌ (ជំនឿ ភាសា ប្រពៃណី សាសនា បែបផែនជីវិត ជាតិពន្ធុ)<br>➢ រៀនកោតសរសើរនិងគោរពពិពិធភាព និងធ្វើអន្តរកម្មជាមួយអ្នកដទៃនៅក្នុងសហគមន៍ និងពិភពលោកទូលំទូលាយជាងមុន<br>➢ អភិវឌ្ឍតម្លៃនិងជំនាញ ដែលអនុញ្ញាតឱ្យមនុស្ស អាចរស់នៅជាមួយគ្នាប្រកបដោយសន្តិភាព (ការគោរព សមភាព ការយកចិត្តទុកដាក់ សេចក្ដីអាណិតអាសូរ សាមគ្គីភាព ការអត់ធ្មត់ បរិយាប័ន្ន ការប្រាស្រ័យទាក់ទង ការចរចារ ការគ្រប់គ្រងនិងការដោះស្រាយជម្លោះ ការទទួលយកគោលគំនិតផ្សេងៗគ្នា និងអហិង្សា |
| **ថ្នាក់មធ្យមសិក្សាបឋមភូមិ (១២-១៥ឆ្នាំ)**<br>**វត្ថុបំណងនៃការសិក្សា ៖ ជជែកដេញដោលទៅលើផលប្រយោជន៍ និងបញ្ហាប្រឈមនៃភាពផ្សេងគ្នានិងពិពិធភាព**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ សារៈសំខាន់នៃទំនាក់ទំនងល្អ រវាងបុគ្គល ក្រុម សង្គម និងរដ្ឋប្រជាជាតិ សម្រាប់ការរស់នៅជាមួយគ្នាដោយសន្តិភាព និងសម្រាប់សុខុមាលភាពបុគ្គល និងសមូហភាព<br>➢ របៀបដែលអត្តសញ្ញាណប្រកបដោយពិពិធភាព (ជាតិពន្ធុ វប្បធម៌ សាសនា ភាសា យែនឌ័រ អាយុ) និងកត្តាផ្សេងៗទៀត មានឥទ្ធិពលទៅលើលទ្ធភាពរបស់យើង ក្នុងការរស់នៅជាមួយគ្នា | **ថ្នាក់មធ្យមសិក្សាទុតិយភូមិ (១៥-១៨ឆ្នាំ និងខ្ពស់ជាងនេះ)**<br>**វត្ថុបំណងនៃការសិក្សា ៖ អភិវឌ្ឍនិងអនុវត្តនូវតម្លៃ ឥរិយាបថ និងជំនាញ ដើម្បីគ្រប់គ្រងនិងចូលរួមជាមួយក្រុមនិងគោលគំនិតប្រកបដោយពិពិធភាព**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ ការអាស្រ័យគ្នាទៅវិញទៅមក និងបញ្ហាប្រឈមនៃការរស់នៅក្នុងសង្គមនិងវប្បធម៌ប្រកបដោយពិពិធភាព (វិសមភាពអំណាច វិសមភាពសេដ្ឋកិច្ច ជម្លោះ ការរើសអើង និងការវិនិច្ឆ័យអវិជ្ជមាន)<br>➢ គោលគំនិតប្រកបដោយពិពិធភាព និងភាពស្មុគស្មាញ |

| | |
|---|---|
| ➢ បញ្ហាប្រឈមក្នុងការរស់នៅជាមួយគ្នា និងអ្វីដែលអាចបង្កជម្លោះ (អបរិយាប័ន្ន ការមិនអត់ឱន ការវិនិច្ឆ័យអវិជ្ជមាន ការរើសអើង វិសមភាព បុព្វសិទ្ធិ ការផ្តល់ផលប្រយោជន៍ ភាពភ័យខ្លាច កង្វះខាតនូវការប្រាស្រ័យទាក់ទងគ្នា សេរីភាពក្នុងការបញ្ចេញមតិ កង្វះខាតនិងវិសមភាពនៃការទទួលបានធនធាន)<br>➢ របៀបដែលបុគ្គលនិងក្រុម ដែលមានអត្តសញ្ញាណនិងសមាជិកភាពផ្សេងគ្នា ចូលរួមជាសមូហភាពនៅក្នុងបញ្ហា ដែលជាការខ្វល់ខ្វាយជាសកល ដើម្បីនាំមកនូវភាពល្អប្រសើរនៃពិភពលោកទាំងមូល<br>➢ អនុវត្តជំនាញសន្ទនា ការចរចារ និងការគ្រប់គ្រងជម្លោះ | ➢ សកម្មភាពដោយអង្គការផ្សេងៗ ដើម្បីនាំមកនូវការផ្លាស់ប្តូរវិជ្ជមាន ទាក់ទងនឹងបញ្ហាសកល (ចលនាជាតិ និងចលនាអន្តរជាតិ ដូចជាស្ត្រី ពលកម្ម ក្រុមភាគតិច ក្រុមជនជាតិដើម ក្រុមភេទភាគតិច)<br>➢ តម្លៃនិងឥរិយាបថនៃសេចក្តីអាណិតអាសូរ និងការគោរពហួសពីក្រុមរបស់យើង<br>➢ ទស្សនាទាននៃសន្តិភាព ការកសាងមតិរួម និងអហិង្សា<br>➢ ការចូលរួមនៅក្នុងសកម្មភាព សម្រាប់យុត្តិធម៌សង្គម (នៅកម្រិតមូលដ្ឋាន ជាតិ និងអន្តរជាតិ) |

## ខ.៧. សកម្មភាពដែលអាចត្រូវបានធ្វើឡើងដោយបុគ្គលនិងដោយសមូហភាព

| **ថ្នាក់មុនបឋមសិក្សា និង បឋមសិក្សាកម្រិតទាប (៥-៩ឆ្នាំ)** | **ថ្នាក់បឋមសិក្សាកម្រិតខ្ពស់ (៩-១២ឆ្នាំ)** |
|---|---|
| **វត្ថុបំណងនៃការសិក្សា ៖ ស្វែងយល់អំពីវិធីទាំងឡាយដែលអាចធ្វើបាន ក្នុងការចាត់វិធានការ ដើម្បីធ្វើឱ្យពិភពលោកដែលយើងរស់នៅមានភាពល្អប្រសើរ**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ តើជម្រើសនិងសកម្មភាពរបស់យើង អាចធ្វើឱ្យផ្ទះ សាលា សហគមន៍ ប្រទេស និងភពផែនដីរបស់យើង ជាកន្លែងដ៏ល្អប្រសើរជាងមួយ សម្រាប់រស់នៅ និងអាចការពារបរិស្ថានរបស់យើងដោយរបៀបណា<br>➢ រៀនធ្វើការជាមួយគ្នា (គម្រោងសហប្រតិបត្តិការទៅលើបញ្ហាជីវិតជាក់ស្តែងនៅក្នុងសហគមន៍ ឧទាហរណ៍ ការធ្វើការងារជាមួយអ្នកដទៃ ដើម្បីប្រមូលនិងបង្ហាញព័ត៌មាន និងការប្រើប្រាស់វិធីសាស្រ្តផ្សេងគ្នា ដើម្បីបង្ហាញការរកឃើញនិងទស្សន)<br>➢ ជំនាញនៃការធ្វើសេចក្តីសម្រេចចិត្ត និងការដោះស្រាយបញ្ហា | **វត្ថុបំណងនៃការសិក្សា ៖ ពិភាក្សាអំពីសារសំខាន់នៃសកម្មភាពជាបុគ្គលនិងសកម្មភាពជាសមូហភាព និងការចូលរួមនៅក្នុងកិច្ចការសហគមន៍**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ ទំនាក់ទំនងរវាងបញ្ហានៅកម្រិតបុគ្គល មូលដ្ឋាន ជាតិ និងសកល<br>➢ ប្រភេទនៃការចូលរួមរបស់ពលរដ្ឋ សម្រាប់សកម្មភាពជាបុគ្គលនិងសកម្មភាពជាសមូហភាព នៅក្នុងវប្បធម៌និងសង្គមផ្សេងគ្នា (ការតស៊ូមតិ សេវាសហគមន៍ សារព័ត៌មាន ដំណើរការអភិបាលកិច្ចជាផ្លូវការ ដូចជាការបោះឆ្នោត)<br>➢ តួនាទីដែលអនុវត្តដោយក្រុមស្ម័គ្រចិត្ត ក្រុមសង្គម និងពលរដ្ឋនៅក្នុងការធ្វើឱ្យប្រសើរឡើងនូវសហគមន៍ ដែលពួកគេរស់នៅ និងនៅក្នុងការកំណត់ដំណោះស្រាយចំពោះបញ្ហាសកល<br>➢ ឧទាហរណ៍នៃបុគ្គលនិងក្រុម ដែលចូលរួមនៅក្នុងសកម្មភាពពលរដ្ឋ ដែលបានធ្វើអ្វីមួយប្លែក នៅកម្រិតមូលដ្ឋាននិងសកល (ឧទាហរណ៍ ៖ លោក ណែលសុន ម៉ាន់ឌីឡា, កញ្ញា ម៉ាឡាឡា យូសាហ្សៃ្ស, កាកបាទក្រហមនិងអធិច័ន្ទក្រហម ក្រុមគ្រូពេទ្យគ្មានព្រំដែន និងកីឡាអូឡាំពិក) និងគោលគំនិត សកម្មភាព និងទំនាក់ទំនងសង្គមរបស់ពួកគេ<br>➢ យល់ដឹងថា សកម្មភាពនឹងហុចជាលទ្ធផល |
| **ថ្នាក់មធ្យមសិក្សាបឋមភូមិ (១២-១៥ឆ្នាំ)**<br>**វត្ថុបំណងនៃការសិក្សា ៖ ពិនិត្យមើលអំពីរបៀបដែលបុគ្គលនិងក្រុមចាត់វិធានការទៅលើបញ្ហាដែលមានសារសំខាន់នៅថ្នាក់មូលដ្ឋាន** | **ថ្នាក់មធ្យមសិក្សាទុតិយភូមិ (១៥-១៨ឆ្នាំ និងខ្ពស់ជាងនេះ)**<br>**វត្ថុបំណងនៃការសិក្សា ៖ អភិវឌ្ឍនិងអនុវត្តជំនាញដើម្បីអនុវត្តការចូលរួមរបស់ពលរដ្ឋប្រកបដោយប្រសិទ្ធភាព**<br><br>**ខ្លឹមសារសំខាន់ៗ ៖** |

| | |
|---|---|
| **ជាតិ និងសកល និងចូលរួមនៅក្នុងការឆ្លើយតបទៅនឹងបញ្ហាទាំងនោះ នៅថ្នាក់មូលដ្ឋាន ជាតិ និងសកល**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ កំណត់និយមន័យនៃតួនាទី និងកតព្វកិច្ចរបស់បុគ្គល និងក្រុម (ស្ថាប័នរដ្ឋ សង្គមស៊ីវិល ក្រុមស្ម័គ្រចិត្ត) នៅក្នុងការធ្វើសកម្មភាព<br>➢ ប្រមើមើលនិងវិភាគផលវិបាកនៃសកម្មភាព<br>➢ កំណត់អត្តសញ្ញាណនៃសកម្មភាព ដែលត្រូវបានធ្វើឡើងដើម្បីធ្វើឱ្យប្រសើរដល់សហគមន៍ (ដំណើរការនយោបាយ ការប្រើប្រាស់សារព័ត៌មាននិងបច្ចេកវិជ្ជា ការដាក់សម្ពាធ ក្រុមដែលមានទិសដៅផលប្រយោជន៍រួម ចលនាសង្គម ក្រុមសកម្មនិយមអហិង្សា ក្រុមតស៊ូមតិ)<br>➢ កំណត់អត្តសញ្ញាណនៃផលប្រយោជន៍ កាលានុវត្តភាព និងផលប៉ះពាល់នៃការចូលរួមរបស់ពលរដ្ឋ<br>➢ កត្តាទាំងឡាយ ដែលរួមចំណែកដល់ជោគជ័យ និងកត្តាទាំងឡាយដែលកំហិតដល់ជោគជ័យ នៃសកម្មភាពបុគ្គលនិងសកម្មភាពសមូហភាព | ➢ វិភាគកត្តាទាំងឡាយដែលអាចពង្រឹង ឬកំណត់ការចូលរួមរបស់ពលរដ្ឋ (ថាមពលសេដ្ឋកិច្ច នយោបាយ និងសង្គម និងរនាំងចំពោះតំណាងនិងការចូលរួម របស់ក្រុមជាក់លាក់ទាំងឡាយ ដូចជាស្ត្រី ក្រុមភាគតិច ជាតិពន្ធុ និងសាសនា ជនពិការ និងយុវជន)<br>➢ ជ្រើសរើសវិធីសមស្របបំផុត សម្រាប់ទទួលបានព័ត៌មាន បង្ហាញទស្សន និងធ្វើសកម្មភាព ទៅលើបញ្ហាសកលសំខាន់ៗ (ប្រសិទ្ធភាព លទ្ធផល លទ្ធផលអវិជ្ជមាន ការពិចារណាផ្នែកសីលធម៌)<br>➢ គម្រោងសហការទៅលើបញ្ហា ដែលជាការខ្វល់ខ្វាយនៅកម្រិតមូលដ្ឋាននិងសកល (បរិស្ថាន ការកសាងសន្តិភាព ការរើសអើងអ្នកស្រលាញ់ភេទដូចគ្នា ការរើសអើងពូជសាសន៍)<br>➢ ជំនាញសម្រាប់ការចូលរួមនៅក្នុងសង្គម និងនយោបាយប្រកបដោយប្រសិទ្ធភាព (ការចោទសួរប្រកបដោយការត្រិះរិះពិចារណា ការស្រាវជ្រាវ ការវាយតម្លៃភស្តុតាង ការអះអាងប្រកបដោយហេតុផល ការធ្វើផែនការ ការរៀបចំសកម្មភាព ការធ្វើការប្រកបដោយការសហការ ការឆ្លុះបញ្ចាំងផលវិបាកប្រកបដោយសក្តានុពលនៃសកម្មភាព ការសិក្សាពីជោគជ័យនិងបរាជ័យ) |

## ខ.៨. អាកប្បកិរិយាទទួលខុសត្រូវប្រកបដោយសីលធម៌

| ថ្នាក់មុនបឋមសិក្សា និង បឋមសិក្សាកម្រិតទាប (៥-៩ឆ្នាំ) | ថ្នាក់បឋមសិក្សាកម្រិតខ្ពស់ (៩-១២ឆ្នាំ) |
|---|---|
| **វត្ថុបំណងនៃការសិក្សា ៖ ពិភាក្សាអំពីរបៀបដែលជម្រើសនិងសកម្មភាពរបស់យើង ប៉ះពាល់ទៅដល់អ្នកដទៃនិងភពផែនដី និងប្រកាន់យកនូវអាកប្បកិរិយាប្រកបដោយការទទួលខុសត្រូវ**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ តម្លៃនៃការយកចិត្តទុកដាក់ និងការគោរពចំពោះខ្លួនយើង ចំពោះអ្នកដទៃ និងចំពោះបរិស្ថានរបស់យើង<br>➢ ប្រភពធនធានរបស់បុគ្គល និងសហគមន៍ (វប្បធម៌និងសេដ្ឋកិច្ច និងទស្សនាទាននៃអ្នកមាននិងអ្នកក្រ និងយុត្តិធម៌និងអយុត្តិធម៌<br>➢ ការតភ្ជាប់គ្នាទៅវិញទៅមករវាងមនុស្ស និងបិរស្ថាន<br>➢ ទទួលយកមកអនុវត្តនូវទម្លាប់នៃការប្រើប្រាស់ ប្រកបដោយនិរន្តរភាព<br>➢ ជម្រើសនិងសកម្មភាពផ្ទាល់ខ្លួន និងថាតើជម្រើសនិងសកម្មភាពទាំងនេះ ប៉ះពាល់ដល់អ្នកដទៃនិងបរិស្ថានដោយរបៀបណា<br>➢ បង្ហាញភាពខុសគ្នារវាង«ត្រូវ»និង«ខុស» និងផ្តល់ហេតុផលសម្រាប់ជម្រើសនិងការវិនិច្ឆ័យរបស់យើង | **វត្ថុបំណងនៃការសិក្សា ៖ យល់អំពីទស្សនាទាននៃយុត្តិធម៌សង្គមនិងកតព្វកិច្ចប្រកបដោយសីលធម៌ និងសិក្សាអំពីរបៀបក្នុងការអនុវត្តទស្សនាទានទាំងនេះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ តើមានន័យដូចម្តេច ចំពោះពាក្យថាពលរដ្ឋសកលដែលប្រកបដោយការចូលរួម និងការទទួលខុសត្រូវប្រកបដោយសីលធម៌<br>➢ គោលគំនិតផ្ទាល់ខ្លួនចំពោះយុត្តិធម៌ និងបញ្ហានៃការខ្វល់ខ្វាយជាសកល (ការប្រែប្រួលអាកាសធាតុ ពាណិជ្ជកម្មយុត្តិធម៌ ការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ការទទួលបានធនធាន)<br>➢ ឧទាហរណ៍ពីជីវិតពិត នៃយុត្តិធម៌សកល (ការរំលោភសិទ្ធិមនុស្ស ការអត់ឃ្លាន ភាពក្រីក្រ ការរើសអើងផ្អែកលើយេនឌ័រ ការជ្រើសរើសកងទ័ពកុមារ)<br>➢ បង្ហាញជំនាញនៃការធ្វើសេចក្តីសម្រេចចិត្ត និងអាកប្បកិរិយាប្រកបដោយការទទួលខុសត្រូវ នៅក្នុងបរិបទផ្ទាល់ខ្លួន សាលារៀន និងសហគមន៍ |

<table>
<tr>
<td>ថ្នាក់មធ្យមសិក្សាបឋមភូមិ (១២-១៥ឆ្នាំ)<br>វត្ថុបំណងនៃការសិក្សា ៖ វិភាគបញ្ហាប្រឈមនិងទ្វេគ្រោះដែលពាក់ព័ន្ធជាមួយនឹងយុត្តិធម៌សង្គម និងកតព្វកិច្ចប្រកបដោយសីលធម៌ និងពិចារណាផលប៉ះពាល់ទៅលើសកម្មភាពជាបុគ្គលនិងសកម្មភាពជាសមូហភាព<br><br>ខ្លឹមសារសំខាន់ៗ ៖<br>➢ គោលគំនិតផ្សេងគ្នាអំពីយុត្តិធម៌សង្គម និងការទទួលខុសត្រូវប្រកបដោយសីលធម៌ នៅក្នុងផ្នែកផ្សេងៗនៃសកលលោក និងជំនឿ តម្លៃ និងកត្តាទាំងឡាយ ដែលមានឥទ្ធិពលទៅលើគោលគំនិតនិងការទទួលខុសត្រូវទាំងនេះ<br>➢ តើគោលគំនិតទាំងនេះ ប្រហែលជាមានឥទ្ធិពលទៅលើការអនុវត្តប្រកបដោយយុត្តិធម៌ឬអយុត្តិធម៌ ប្រកបដោយសីលធម៌ឬអសីលធម៌<br>➢ ការចូលរួមរបស់ពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងសីលធម៌ជាមួយនឹងបញ្ហាសកល (សេចក្តីមេត្តា សេចក្តីអាណិតអាសូរ សាមគ្គីភាព ការសន្ទនា ការយកចិត្តទុកដាក់និងការគោរពចំពោះមនុស្សនិងបរិស្ថាន)<br>➢ ទុក្ខលំបាកផ្នែកសីលធម៌ (ពលកម្មកុមារ សន្តិសុខស្បៀង ទម្រង់នៃសកម្មភាពប្រកបដោយធម្មានុភាព និងអធម្មានុភាព ដូចជាអំពើហិង្សា) ដែលប្រជាពលរដ្ឋជួបប្រទះ នៅក្នុងការអនុវត្តការទទួលខុសត្រូវផ្នែកសង្គម និងនយោបាយរបស់ពួកគេ និងតួនាទីរបស់ពួកគេក្នុងនាមជាពលរដ្ឋសកល</td>
<td>ថ្នាក់មធ្យមសិក្សាទុតិយភូមិ (១៥-១៨ឆ្នាំ និងខ្ពស់ជាងនេះ)<br>វត្ថុបំណងនៃការសិក្សា ៖ វាយតម្លៃប្រកបដោយការត្រិះរិះពិចារណាទៅលើបញ្ហាយុត្តិធម៌សង្គមនិងកតព្វកិច្ចប្រកបដោយសីលធម៌ និងចាត់វិធានការក្នុងការជំនះការរើសអើងនិងវិសមភាព<br><br>ខ្លឹមសារសំខាន់ៗ ៖<br>➢ របៀបដែលគោលគំនិតផ្សេងៗគ្នាទៅលើយុត្តិធម៌សង្គម និងការទទួលខុសត្រូវប្រកបដោយសីលធម៌ មានឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយ និងការចូលរួមរបស់ពលរដ្ឋ (សមាជិកភាពនៅក្នុងចលនានយោបាយ ការងារសហគមន៍និងការងារស្ម័គ្រចិត្ត ការចូលរួមនៅក្នុងក្រុមសាសនាឬក្រុមមនុស្សធម៌) ឬធ្វើឱ្យស្មុគស្មាញទៅដល់ដំណោះស្រាយនៃបញ្ហាសកល<br>➢ បញ្ហាដែលពាក់ព័ន្ធនឹងសំណួរផ្នែកសីលធម៌ (អំណាចនិងអាវុធមិនច្បាស់លាស់ សិទ្ធិជនជាតិដើមភាគតិច ការត្រួតពិនិត្យ អំពើឃោឃៅទៅលើសត្វ ការអនុវត្តធុរកិច្ច)<br>➢ បញ្ហាប្រឈមសម្រាប់អភិបាលកិច្ច នៃទស្សនផ្សេងគ្នានិងប្រកបដោយជម្លោះនៃភាពត្រឹមត្រូវ និងយុត្តិធម៌សង្គម<br>➢ ជំនះភាពអយុត្តិធម៌ និងវិសមភាព<br>➢ បង្ហាញការទទួលខុសត្រូវក្នុងសង្គម ប្រកបដោយសីលធម៌</td>
</tr>
</table>

<table>
<tr>
<th colspan="2">ខ.៩. ការចូលរួមនិងការចាត់វិធានការ</th>
</tr>
<tr>
<td>ថ្នាក់មុនបឋមសិក្សា និង បឋមសិក្សាកម្រិតទាប (៥-៩ឆ្នាំ)<br>វត្ថុបំណងនៃការសិក្សា ៖ ទទួលស្គាល់សារសំខាន់និងផលប្រយោជន៍នៃការចូលរួមរបស់ពលរដ្ឋ<br><br>ខ្លឹមសារសំខាន់ៗ ៖<br>➢ ផលប្រយោជន៍នៃការចូលរួមរបស់ពលរដ្ឋ ដោយផ្ទាល់ខ្លួននិងដោយសមូហភាព<br>➢ បុគ្គលនិងអង្គភាព ដែលចាត់វិធានការដើម្បីធ្វើឱ្យសហគមន៍មានភាពល្អប្រសើរ (ជនរួមជាតិ ក្លឹប បណ្តាញ ក្រុម អង្គការ កម្មវិធី និងការផ្តួចផ្តើម)<br>➢ តួនាទីរបស់កុមារ នៅក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនៅកម្រិតមូលដ្ឋាន ជាតិ និងសកល (នៅក្នុងសាលា គ្រួសារ សហគមន៍ដែលខ្លួនរស់នៅ ប្រទេស និងភពផែនដី)</td>
<td>ថ្នាក់បឋមសិក្សាកម្រិតខ្ពស់ (៩-១២ឆ្នាំ)<br>វត្ថុបំណងនៃការសិក្សា ៖ កំណត់កាលានុវត្តភាពសម្រាប់ការចូលរួមនិងផ្តួចផ្តើមសកម្មភាព<br><br>ខ្លឹមសារសំខាន់ៗ ៖<br>➢ របៀបដែលប្រជាជនពាក់ព័ន្ធជាមួយអង្គការទាំងនេះ និងចំណេះដឹង ជំនាញ និងគុណសម្បត្តិផ្សេងទៀតអ្វីខ្លះ ដែលពួកគេនាំមក<br>➢ កត្តាទាំងឡាយដែលអាចជួយទ្រទ្រង់ និងបំផ្លាញការផ្លាស់ប្តូរ<br>➢ តួនាទីរបស់ក្រុមនិងអង្គការ (ក្លឹប បណ្តាញ ក្រុមកីឡា សហជីព សមាគមវិជ្ជាជីវៈ)<br>➢ ចូលរួមនៅក្នុងគម្រោង និងការងារសំណេរ<br>➢ ចូលរួមនៅក្នុងសកម្មភាពនៅសហគមន៍<br>➢ ចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅសាលារៀន</td>
</tr>
</table>

| | |
|---|---|
| ➢ ទម្រង់នៃការចូលរួមនៅផ្ទះ សាលារៀន សហគមន៍ ក្នុងនាមជាទិដ្ឋភាពបឋមនៃភាពជាពលរដ្ឋ<br>➢ ចូលរួមនៅក្នុងការសន្ទនា និងការជជែកដេញដោល<br>➢ ចូលរួមនៅក្នុងសកម្មភាពនៅខាងក្រៅថ្នាក់រៀន<br>➢ ធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាព | |
| **ថ្នាក់មធ្យមសិក្សាបឋមភូមិ (១២-១៥ឆ្នាំ)**<br>**វត្ថុបំណងនៃការសិក្សា ៖ អភិវឌ្ឍជំនាញសម្រាប់ការចូលរួមយ៉ាងសកម្ម និងចាត់វិធានការដើម្បីជំរុញភាពល្អប្រសើររួម**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ ការជំរុញលើកទឹកចិត្តផ្ទាល់ខ្លួន និងថាតើការជំរុញលើកទឹកចិត្តនេះ ប៉ះពាល់ដូចម្តេចខ្លះទៅលើភាពជាពលរដ្ឋសកម្ម<br>➢ បណ្តុំនៃតម្លៃនិងសីលធម៌ផ្ទាល់ខ្លួន ដើម្បីជួយណែនាំការធ្វើសេចក្តីសម្រេចចិត្ត និងការធ្វើសកម្មភាព<br>➢ វិធីក្នុងការចូលរួមដោះស្រាយបញ្ហាមួយ ដែលមានសារសំខាន់ជាសកលនៅក្នុងសហគមន៍<br>➢ ចូលរួមយ៉ាងសកម្ម នៅក្នុងការផ្តួចផ្តើមនៅកម្រិតមូលដ្ឋាន ជាតិ និងសកល<br>➢ អភិវឌ្ឍនិងអនុវត្តចំណេះដឹង ជំនាញ តម្លៃ និងគោលការណ៍សិទ្ធិមនុស្ស ដែលចាំបាច់<br>➢ ការស្ម័គ្រចិត្ត និងកាលានុវត្តភាពនៃការសិក្សាពីសេវា<br>➢ បណ្តាញទំនាក់ទំនង (មិត្តភក្ត សង្គមស៊ីវិល អង្គការមិនរកប្រាក់ចំណេញ អង្គការតំណាងវិជ្ជាជីវ:)<br>➢ សហគ្រិនសង្គម<br>➢ ទទួលយកអាកប្បកិរិយាវិជ្ជមាន | **ថ្នាក់មធ្យមសិក្សាទុតិយភូមិ (១៥-១៨ឆ្នាំ និងខ្ពស់ជាងនេះ)**<br>**វត្ថុបំណងនៃការសិក្សា ៖ ស្នើវិធានការ និងធ្វើខ្លួនឱ្យទៅជាភ្នាក់ងារសម្រាប់ការផ្លាស់ប្តូរដោយវិជ្ជមាន**<br><br>**ខ្លឹមសារសំខាន់ៗ ៖**<br>➢ សិក្សាដើម្បីឱ្យក្លាយជាពលរដ្ឋសកលសកម្ម និងអំពីរបៀបក្នុងការផ្លាស់ប្តូរខ្លួនឯង និងសង្គម<br>➢ រួមចំណែកដល់ការវិភាគ និងការកំណត់អត្តសញ្ញាណនៃតម្រូវការ និងអាទិភាព ដែលតម្រូវឱ្យមានសកម្មភាពនិងការផ្លាស់ប្តូរនៅកម្រិតមូលដ្ឋាន ជាតិ និងសកល<br>➢ ចូលរួមយ៉ាងសកម្ម នៅក្នុងការបង្កើតទស្សនវិស័យមួយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់ការផ្លាស់ប្តូរវិជ្ជមាន<br>➢ ស្វែងរកកាលានុវត្តភាព សម្រាប់សហគ្រិនភាពសង្គម<br>➢ វិភាគប្រកបដោយការត្រិះរិះពិចារណា ទៅលើការរួមចំណែកនិងផលប៉ះពាល់នៃការងារ របស់តួអង្គផ្សេងៗទៀត<br>➢ ជំរុញលើកទឹកចិត្ត តស៊ូមតិ និងបង្រៀនអ្នកផ្សេងទៀត ឱ្យធ្វើសកម្មភាព<br>➢ អនុវត្តជំនាញនៃការប្រាស្រ័យទាក់ទង ការចរចារ និងការតស៊ូមតិ<br>➢ ទទួលព័ត៌មាន និងបង្ហាញទស្សនរបស់ពួកគេ អំពីបញ្ហាសកលសំខាន់ៗ<br>➢ លើកកម្ពស់អាកប្បកិរិយាសង្គមវិជ្ជមាន |

## តារាង គ ៖ ពាក្យគន្លិះ

តារាងនេះបង្ហាញបញ្ជីចង្អុលបង្ហាញនៃពាក្យគន្លិះ ដែលអាចត្រូវបានប្រើប្រាស់ ជាមូលដ្ឋានមួយសម្រាប់ការពិភាក្សានិងសកម្មភាពទាំងឡាយ ពាក់ព័ន្ធនឹងវត្ថុបំណងនៃការសិក្សា ដែលត្រូវបានបង្ហាញនៅខាងលើ។ ពួកគេត្រូវបានរៀបចំឡើងទៅតាមខ្លឹមសារ នៅក្នុងន័យជាការចង្អុលបង្ហាញមួយ។ បញ្ហាទាំងនេះជាច្រើនមានទំនាក់ទំនងគ្នាទៅវិញទៅមក និងពាក់ព័ន្ធច្រើនជាងមួយប្រធានបទនិងវត្ថុបំណងនៃការសិក្សា ដែលបានបង្ហាញពីខាងដើម។ បញ្ហាសកលផ្សេងទៀត និងបញ្ហាដែលសមស្របទៅនឹងបរិបទជាក់លាក់ ក៏អាចត្រូវបានបញ្ចូលទៅក្នុងបញ្ជីតាមការចាំបាច់។

| | |
|---|---|
| **បញ្ហានៅមូលដ្ឋាននិងសកល និងទំនាក់ទំនងរវាងបញ្ហាទាំងនេះ/រចនាសម្ព័ន្ធនិងប្រព័ន្ធអភិបាលកិច្ចនៅកម្រិតមូលដ្ឋាន ជាតិ និងសកល/បញ្ហាដែលប៉ះពាល់ដល់អន្តរកម្មនិងទំនាក់ទំនង/ឥទ្ធិពលនៃការសន្ទត់និងថាមពលនៃអំណាច** | ▪ ភាពជាពលរដ្ឋ ភាពមានការងារធ្វើ សកលភាវូបនីយកម្ម អន្តោប្រវេសន៍ ទំនាក់ទំនងគ្នាទៅវិញទៅមក ការអាស្រ័យគ្នាទៅវិញទៅមក ទេសន្តរប្រវេសន៍ ចលនា ទំនាក់ទំនងជើងត្បូង នយោបាយ ទំនាក់ទំនងអំណាច<br>▪ ការទទួលបានយុត្តិធម៌ អាយុស្របច្បាប់ ការធ្វើសេចក្តីសម្រេចចិត្ត ប្រជាធិបតេយ្យ ដំណើរការប្រជាធិបតេយ្យ សន្តិសុខស្បៀង អភិបាលកិច្ចល្អ សេរីភាពក្នុងការបញ្ចេញមតិ សមភាពយេនឌ័រ ច្បាប់មនុស្សធម៌ សន្តិភាព ការកសាងសន្តិភាព ភាពល្អប្រសើរសាធារណៈ ការទទួលខុសត្រូវ សិទ្ធិ (សិទ្ធិកុមារ សិទ្ធិវប្បធម៌ សិទ្ធិមនុស្ស សិទ្ធិជនជាតិដើមភាគតិច សិទ្ធិទទួលបានការអប់រំ សិទ្ធិស្ត្រី) នីតិរដ្ឋ បញ្ញត្ត តម្លាភាព សុខុមាលភាព (បុគ្គល និងសមូហភាព)<br>▪ អំពើឧក្រិដ្ឋកម្ម អ្នកស្វែងរកសិទ្ធិជ្រកកោននយោបាយ ពលកម្មកុមារ កងទ័ពកុមារ ការត្រួតពិនិត្យ ជម្លោះ ជំងឺ (អេបូឡា ហ៊ីវ និង អេដស៍) វិសមភាពសេដ្ឋកិច្ច ភាពជ្រុលនិយម អំពើប្រល័យពូជសាសន៍ ភាពក្រីក្រសកល វិសមភាព ការមិនអត់ឱន អំណាចនុយក្លេអ៊ែរ អាវុធប្រល័យលោក ការ |

| | |
|---|---|
| | រើសអើងពូជសាសន៍ ជនភៀសខ្លួន ការរើសអើងភេទ ភេរវកម្ម ភាពគ្មានការងារធ្វើ វិសមភាពធនធាន អំពើហិង្សា សង្គ្រាម<br>▪ សង្គមស៊ីវិល ការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន វិស័យឯកជន ពុទ្ធចក្រនិងអាណាចក្រ ភាគីពាក់ព័ន្ធ ការទទួលខុសត្រូវរបស់រដ្ឋ យុវជន<br>▪ ជីវចម្រុះ ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ ការកាត់បន្ថយហានិភ័យ គ្រាអាសន្ន ការឆ្លើយតបបន្ទាន់ បរិស្ថាន គ្រោះមហន្តរាយធម្មជាតិ ការអភិវឌ្ឍជានិរន្ត គុណភាពទឹក<br>▪ ភូមិវិទ្យា ប្រវត្តិវិទ្យា មរតកអាណានិគមនិយម មរតកនៃទាសភាព ចំណេះដឹងផ្នែកសារព័ត៌មាន សារព័ត៌មានសង្គម |
| **បណ្ដុះនិងគ្រប់គ្រងអត្តសញ្ញាណ ទំនាក់ទំនង និងការគោរពចំពោះពិពិធភាព** | ▪ សហគមន៍ ប្រទេស អនិកជន គ្រួសារ ជនជាតិដើម ជនជាតិភាគតិច ភូមិស្ថាន សាលារៀន ខ្លួនឯងនិងអ្នកដទៃ ពិភពលោក<br>▪ ឥរិយាបថ អាកប្បកិរិយា ជំនឿ វប្បធម៌ ពិពិធភាពនៃវប្បធម៌ ពិពិធភាពយេនឌ័រ អត្តសញ្ញាណ (អត្តសញ្ញាណរួម អត្តសញ្ញាណវប្បធម៌ អត្តសញ្ញាណយេនឌ័រ អត្តសញ្ញាណជាតិ អត្តសញ្ញាណបុគ្គល) កិច្ចសន្ទនាអន្តរវប្បធម៌ ភាសា (ទ្វេភាសានិយម ពហុភាសានិយម) សាសនា ភេទ ប្រព័ន្ធតម្លៃ តម្លៃ<br>▪ ការយកចិត្តទុកដាក់ សេចក្តីមេត្តា ការខ្វល់ខ្វាយ សេចក្តីអាណិតអាសូរ ភាពត្រឹមត្រូវ ភាពស្មោះត្រង់ សុចរិតភាព ចិត្តល្អ សេចក្តីស្រលាញ់ ការគោរព សាមគ្គីភាព ការអត់ឱន ការយល់ សេចក្តីស្រាលាញ់ចំពោះពិភពលោក<br>▪ ការអះអាង ការប្រាស្រ័យទាក់ទង ដំណោះស្រាយជម្លោះ ការសន្ទនា បរិយាប័ន្ន កិច្ចសន្ទនាអន្តរវប្បធម៌ ជំនាញជីវិត ការគ្រប់គ្រងភាពខុសគ្នា (ឧទាហរណ៍ ភាពខុសគ្នាផ្នែកវប្បធម៌) ការគ្រប់គ្រងការផ្លាស់ប្តូរ ការសម្របសម្រួល ការចរចារ ជំនាញនៃភាពជាដៃគូ (អន្តរជាតិ និង មូលដ្ឋាន) ការទប់ស្កាត់ (ជម្លោះ ការធ្វើទុក្ខបុកម្នេញ អំពើហិង្សា) ទំនាក់ទំនង ការផ្សះផ្សា ការផ្លាស់ប្តូរ ដំណោះស្រាយឈ្នះឈ្នះ<br>▪ អំពើឃោរឃៅលើសត្វ ការធ្វើទុក្ខបុកម្នេញ ការរើសអើង ការរើសអើងពូជសាសន៍ អំពើហិង្សា (ដែលរួមទាំង អំពើហិង្សាផ្នែកយេនឌ័រ អំពើហិង្សាផ្នែកយេនឌ័រពាក់ព័ន្ធនឹងសាលារៀន SRGBV) |

| | |
|---|---|
| **ការចូលរួម សកម្មភាព និងការទទួលខុសត្រូវប្រកបដោយសីលធម៌** | ▪ ទម្លាប់នៃការប្រើប្រាស់ ការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន សំណួរបែបសីលធម៌ ការទទួលខុសត្រូវផ្នែកសីលធម៌ យុត្តិធម៌ពាណិជ្ជកម្ម សកម្មភាពមនុស្សធម៌ យុត្តិធម៌សង្គម<br>▪ សហគ្រិនភាព ជំនាញហិរញ្ញវត្ថុ ការច្នៃប្រឌិត |

# ៣

# ការអនុវត្តការអប់រំភាពជាពលរដ្ឋសកល

## ៣.១. តើត្រូវបញ្ជ្រាបប្រធានបទនេះទៅក្នុងប្រព័ន្ធអប់រំដោយរបៀបណា?

មិនមានវិធីសាស្ត្រទោល ក្នុងការអនុវត្តការអប់រំភាពជាពលរដ្ឋសកលទេ ទោះបីជាបទពិសោធន៍បានណែនាំថា កត្តាមួយចំនួនរួមចំណែកក្នុងការអនុវត្តការបង្រៀននេះប្រកបដោយជោគជ័យ។ កត្តាទាំងនេះនឹងត្រូវបានបង្ហាញនៅក្នុងប្រអប់ខាងក្រោម។ នៅក្នុងន័យនេះ ការធ្វើសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយ នឹងត្រូវបានផ្តល់ឱ្យដោយកត្តាបរិបទជាច្រើន ដែលរួមមានគោលនយោបាយអប់រំ ប្រព័ន្ធ សាលារៀននិងកម្មវិធីសិក្សា សមត្ថភាពគ្រូបង្រៀន ក៏ដូចជាតាមរយៈតម្រូវការនិងពិពិធភាពរបស់អ្នកសិក្សា និងបរិបទសង្គមវប្បធម៌ នយោបាយ និងសេដ្ឋកិច្ចទូលំទូលាយជាងមួយ។ ប្រធានបទសំខាន់ៗដែលត្រូវពិចារណា ត្រូវបានពិភាក្សានៅក្នុងផ្នែកនេះ។

**កត្តាទាំងឡាយដែលរួមចំណែកដល់ការអនុវត្តការអប់រំភាពជាពលរដ្ឋសកល ប្រកបដោយជោគជ័យ ៖**

- ដាក់បញ្ចូលទៅក្នុងគោលនយោបាយ ដោយមានការគាំទ្រពីភាគីពាក់ព័ន្ធទូលំទូលាយ
- ផែនការយូរអង្វែង និងប្រកបដោយនិរន្តភាព
- ការរួមបញ្ចូលគ្នាទាំងអស់ ដែលរួមទាំងប្រធានបទរងទាំងឡាយ នៅក្នុងលក្ខណៈជាប្រព័ន្ធមួយ
- ពង្រឹងបន្ថែមនៅក្នុងឆ្នាំសិក្សានីមួយៗ និងនៅក្នុងសង្គមទូលំទូលាយជាងមួយ
- គ្របដណ្តប់សមាសធាតុមូលដ្ឋាន ជាតិ និងសកល
- គាំទ្រដោយការបណ្តុះបណ្តាលគ្រូបង្រៀនដែលមិនទាន់បានបម្រើការងារ (គរុសិស្ស និងគរុនិស្សិត) និងគ្រូបង្រៀនដែលកំពុងបម្រើការងារ
- អភិវឌ្ឍនិងទ្រទ្រង់ ដោយមានកិច្ចសហការជាមួយសហគមន៍មូលដ្ឋាន
- អាចពង្រីកបាន ដោយរក្សាបាននូវគុណភាព
- ទទួលយកយោបល់ត្រឡប់ ពីដំណើរការនៃការគ្រប់គ្រងនិងវាយតម្លៃ
- ផ្អែកលើការរៀបចំប្រកបដោយការសហការ ដែលធានាបាននូវជំនាញជាជាងរយៈពេលយូរអង្វែង តាមរយៈការផ្តល់ការត្រួតពិនិត្យមើលជាប្រចាំ

ប្រភព ៖ *ការអប់រំនៅពីលើអ្វីៗទាំងអស់* (ឆ្នាំ២០១២) និង *ការអប់រំភាពជាពលរដ្ឋសកល*

## ៣.១.១. ការបង្កើតវត្ថុបំណងនៃការសិក្សា

ការកំណត់វត្ថុបំណងនៃការសិក្សាជាអាទិភាព គឺជាជំហានចាំបាច់ទីមួយដើម្បីកំណត់សមត្ថភាព ដែលអ្នកសិក្សាត្រូវបានរំពឹងថានឹងអាចអនុវត្តបាន និងនៅក្នុងការតម្រង់ទិសសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តទាំងឡាយ អំពីការអនុវត្តនិងការវាយតម្លៃការអប់រំភាពជាពលរដ្ឋសកល។ វត្ថុបំណងនៃការសិក្សាដែលត្រូវបានណែនាំនៅក្នុងផ្នែកទី២ គូសបញ្ជាក់ការបញ្ជ្រាបទៅលើបណ្តុំនៃការសិក្សាបែបចំណេះដឹង ចិត្តសង្គម និងឥរិយាបថ ផ្តល់ឧទាហរណ៍នៅក្នុងការតម្រង់ទិសដំណើរការនេះ និងអាចត្រូវបានទទួលយកទៅអនុវត្តនៅក្នុងបរិបទប្រទេសជាក់លាក់ និងទៅតាមតម្រូវការ និងដំណាក់កាលនៃការអភិវឌ្ឍរបស់អ្នកសិក្សា (សូមមើលឧទាហរណ៍ខាងក្រោម)។

**នៅក្នុងប្រទេសអូស្ត្រាលី** កម្មវិធីសិក្សារួមបញ្ចូលអាទិភាពកម្មវិធីសិក្សាចម្រុះ៣ និងសមត្ថភាពទូទៅ៧ ដែលផ្សាភ្ជាប់ទៅនឹងការអប់រំភាពជាពលរដ្ឋសកល។ អាទិភាពកម្មវិធីសិក្សាចម្រុះរួមមាន ៖ និរន្តរភាព, អាស៊ី និងការតភ្ជាប់អូស្ត្រាលីជាមួយអាស៊ី, ប្រវត្តិសាស្ត្រនិងវប្បធម៌អ្នកស្រុកដើម និងជនជាតិដើមនៅតំបន់ Torres Strait Islander។ សមត្ថភាពទូទៅរួមមាន ៖ ការចេះអក្សរ ការចេះលេខ សមត្ថភាពផ្នែកបច្ចេកវិជ្ជាព័ត៌មាននិងទំនាក់ទំនង ការគិតប្រកបដោយការត្រិះរិះពិចារណានិងការច្នៃប្រឌិត សមត្ថភាពផ្ទាល់ខ្លួននិងសង្គម ការយល់ដឹងអន្តរវប្បធម៌ និងអាកប្បកិរិយាប្រកបដោយសីលធម៌។ ទាំងនេះត្រូវបានអនុវត្តនៅក្នុងគ្រប់កម្មវិធីសិក្សានៃមុខវិជ្ជាទាំងអស់។

**នៅក្នុងប្រទេសកូឡុំប៊ី** កម្មវិធីសិក្សាមានគោលបំណងអភិវឌ្ឍសមត្ថភាពស្នូលចំនួន៤ ៖ ភាសា គណិតវិទ្យា វិទ្យាសាស្ត្រ និងសមត្ថភាពពលរដ្ឋ។ សមត្ថភាពពលរដ្ឋ ដែលរួមមានភាពសមហេតុផល ការយកចិត្តទុកដាក់ចំពោះអ្នកដទៃ ជំនាញនៃការប្រាស្រ័យទាក់ទង ការឆ្លុះបញ្ចាំងទៅលើសកម្មភាព ចំណេះដឹងនិងការចូលរួមយ៉ាងសកម្មនៅក្នុងថ្នាក់រៀន និងបញ្ហាសាលារៀននិងសហគមន៍ ត្រូវបានអភិវឌ្ឍនៅក្នុងអត្ថន័យនៃកម្មវិធីសិក្សាចម្រុះ។ ការរំពឹងទុកពីការសិក្សាសម្រាប់ថ្នាក់ទី៣ ទី៥ ទី៧ ទី៩ និងទី១១ ត្រូវបានរៀបចំទៅជា៣ក្រុម ៖ ការរួមរស់នៅជាមួយគ្នានិងសន្តិភាព ការចូលរួមក្នុងដំណើរការប្រជាធិបតេយ្យ និងពិពិធភាព។ ទាំងនេះមានទំនាក់ទំនងទៅនឹងចំណេះដឹង អារម្មណ៍ និងសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងនិងការបញ្ជ្រាប។ ស្របជាមួយនឹងធម្មជាតិនៃវិមជ្ឈការនៃប្រព័ន្ធសាលារៀន សាលារៀនអភិវឌ្ឍសម្ភារៈសិក្សានិងសម្ភារៈបង្រៀនដោយខ្លួនឯង។ http://www.mineducation.gov.co/1621/articles-340021_recurso_1.pdf

**នៅក្នុងប្រទេសឥណ្ឌូនេស៊ី** កម្មវិធីសិក្សារួមបញ្ចូលសមត្ថភាពស្នូល ដែលទាក់ទងទៅនឹងការអប់រំភាពជាពលរដ្ឋសកល។ ឧទាហរណ៍ តាមរយៈឥរិយាបថសង្គម វាសំដៅទៅដល់អាកប្បកិរិយាស្មោះត្រង់ ការទទួលខុសត្រូវ និងការយកចិត្តទុកដាក់ ដែលរួមទាំងការអត់ឱននិងការយោគយល់គ្នាទៅវិញទៅមក។

**នៅក្នុងប្រទេសហ្វីលីពីន** កម្មវិធីសិក្សាថ្នាក់ទី១២ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់សម្រាប់ឆ្នាំសិក្សា២០១២-២០១៣ ផ្តោតជាក់ស្តែងទៅលើការរៀនរួមរស់នៅជាមួយគ្នា។ កម្មវិធីនេះប្រើប្រាស់ «វិធីសាស្ត្រមនុស្សទាំងមូល» ដោយផ្តោតជាសំខាន់ទៅលើជំនាញប្រាស្រ័យ

ទាក់ទងប្រកបដោយប្រសិទ្ធភាព ក៏ដូចជាចំណេះដឹងផ្នែកសារព័ត៌មាន។ តម្លៃអប់រំដែលពាក់ព័ន្ធដោយផ្ទាល់ទៅការអប់រំភាពជាពលរដ្ឋសកល រួមមានខ្លឹមសារទាំងឡាយដូចជាតម្លៃផ្ទាល់ខ្លួន សុខដុមភាពជាមួយអ្នកដទៃ ការស្រលាញ់ប្រទេសជាតិ និងសាមគ្គីភាពជាសកល។

**នៅក្នុងសាធារណរដ្ឋកូរ៉េ** កម្មវិធីសិក្សាជាតិបង្ហាញនិងគូសបញ្ជាក់ជាក់លាក់ ទៅលើសារៈសំខាន់នៃភាពជាពលរដ្ឋសកល ដែលត្រូវមានសមត្ថភាពសមស្របផ្សេងៗដូចជាការអត់ឱនសេចក្តីអាណិតអាសូរ និងចំណេះដឹងផ្នែកវប្បធម៌។ ជាងនេះទៅទៀត ការអប់រំភាពជាពលរដ្ឋសកល ត្រូវបានលើកកម្ពស់តាមរយៈកិច្ចសហប្រតិបត្តិការត្រីភាគី ដែលពាក់ព័ន្ធនឹងរដ្ឋាភិបាលកណ្តាល រដ្ឋាភិបាលថ្នាក់ខេត្ត និងសាលារៀន និងនឹងត្រូវបានពង្រីកបន្ថែមទៀតជាមួយនិងការរៀនសូត្រមួយឆមាសដោយគ្មានការប្រលង ដែលនឹងត្រូវអនុវត្តនៅទូទាំងប្រទេសនៅក្នុងឆ្នាំ២០១៦។

**នៅក្នុងប្រទេសទុយនេស៊ី** វិធីសាស្រ្តផ្អែកលើសមត្ថភាពមួយត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្នុងកម្មវិធីសិក្សាក្នុងឆ្នាំ២០០០។ ជាងនេះទៅទៀត បច្ចេកវិជ្ជាព័ត៌មាននិងទំនាក់ទំនង ត្រូវបានគូសបញ្ជាក់ (InfoDev) ដោយមានការជួយទ្រទ្រង់ពីអង្គការអន្តរជាតិដូចជាធានាគារពិភពលោក ដើម្បីបញ្ចូលបច្ចេកវិជ្ជាព័ត៌មាននិងទំនាក់ទំនង ទៅក្នុងគ្រប់កម្រិតទាំងអស់នៃការអប់រំ។ កម្មវិធីអប់រំពលរដ្ឋដែលត្រូវបានរៀបចំឡើងវិញថ្មីមួយ កំពុងត្រូវបានដាក់ឱ្យប្រើប្រាស់ តាមរយៈអង្គការដៃគូនៅថ្នាក់មូលដ្ឋាននិងអន្តរជាតិ ដែលរួមមានការលើកកម្ពស់គោលការណ៍នៃការអភិវឌ្ឍជានិរន្ត ការផ្តល់អំណាចដល់ស្រ្តី និងសមភាពយែនឌ័រ។ (សហាជីពសម្រាប់តំបន់មេឌីទែរ៉ាណេ ឆ្នាំ២០១៤)

## ៣.១.២. វិធីសាស្រ្តក្នុងការអនុវត្ត

វិធីសាស្រ្តសាមញ្ញបំផុតក្នុងការអនុវត្តការអប់រំភាពជាពលរដ្ឋសកល នៅក្នុងក្របខណ្ឌនៃការអប់រំក្នុងប្រព័ន្ធគឺ ៖ ជាប្រធានបទមួយសម្រាប់សាលាទាំងមូល ជាប្រធានបទនៅក្នុងកម្មវិធីសិក្សាចម្រុះ ជាសមាសភាពសម្រាប់ការបញ្ជ្រាបទៅក្នុងមុខវិជ្ជាផ្សេងៗ ឬជាមុខវិជ្ជាដាច់ដោយលែកនៅក្នុងកម្មវិធីសិក្សា។ វិធីសាស្រ្តទាំងនេះអាចបំពេញឱ្យគ្នាទៅវិញទៅមក និងអាចមានឥទ្ធិពលអតិបរិមា នៅពេលដែលត្រូវបានទទួលយកមកប្រើប្រាស់រួមគ្នា។ អ្នករៀបចំផែនការនិងអ្នកធ្វើគោលនយោបាយ ត្រូវធ្វើការសម្រេចចិត្ត ថាតើវិធីសាស្រ្តមួយណាដែល

សមស្របបំផុតសម្រាប់បរិបទរបស់ពួកគេ។ ការសម្រេចចិត្តនេះអាចទទួលរងឥទ្ធិពលពីកត្តាមួយចំនួនដូចជា គោលនយោបាយនិងប្រព័ន្ធអប់រំ អាទិភាពប្រកបដោយការប្រកួតប្រជែងនៅក្នុងកម្មវិធីសិក្សា ប្រភពធនធានដែលមាន ឬកត្តាផ្សេងៗទៀត។

**ការអនុវត្តនៅទូទាំងសាលា ៖** ខ្លឹមសារនិងប្រធានបទនៃការអប់រំភាពជាពលរដ្ឋសកលត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ នៅក្នុងអាទិភាពរបស់សាលាទាំងមូល និងបាវចនារបស់សាលា។ ជាមួយនឹងវិធីសាស្ត្រនេះ ការអប់រំភាពជាពលរដ្ឋសកលផ្តល់ឱ្យនូវកាលានុវត្តភាពមួយ ដើម្បីផ្លាស់ប្តូរមាតិកានៅក្នុងកម្មវិធីសិក្សា បរិស្ថាននៃការសិក្សា និងការអនុវត្តការបង្រៀន និងការវាយតម្លៃ។ ឧទាហរណ៍នៃវិធីសាស្ត្រនៃការអនុវត្តនៅទូទាំងសាលា ឬ«សាលាទាំងមូល»រួមមាន ការបញ្ជ្រាបវត្ថុបំណងនៃការសិក្សាការអប់រំភាពជាពលរដ្ឋសកល ទៅក្នុងមុខវិជ្ជាដែលមានស្រាប់ នៅគ្រប់កម្រិតទាំងអស់ ការប្រើប្រាស់វិធីសាស្ត្រនៃការសិក្សាប្រកបដោយការចូលរួម នៅគ្រប់មុខវិជ្ជាទាំងអស់ សកម្មភាពដើម្បីសម្គាល់ថ្ងៃបុណ្យអន្តរជាតិ ការលើកកម្ពស់ការយល់ដឹង ក្លិបសកម្មជនតម្រង់ទិស ការចូលរួមរបស់សហគមន៍ និងការតភ្ជាប់សាលារៀនទៅក្នុងកន្លែងផ្សេងៗ។

| ឧទាហរណ៍នៅក្នុងប្រទេស |
| --- |
| នៅក្នុង**ប្រទេសអង់គ្លេស** នាយកដ្ឋានសម្រាប់ការអប់រំនិងជំនាញ បានបង្កើតសៀវភៅដែលមានចំណងជើងថា ***អភិវឌ្ឍន៍សមាសធាតុសកលនៅក្នុងកម្មវិធីសិក្សារបស់សាលា*** ដែលជាសៀវភៅសម្រាប់ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន អ្នកគ្រប់គ្រងជាន់ខ្ពស់ និងអ្នកទាំងឡាយដែលទទួលខុសត្រូវនៅក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។ សៀវភៅនេះមានគោលបំណងបង្ហាញអំពីរបៀបដែលសមាសធាតុសកល អាចត្រូវបានបញ្ជ្រាបទៅក្នុងកម្មវិធីសិក្សា និងនៅទូទាំងសាលា។ សៀវភៅនេះផ្តល់ឱ្យនូវឧទាហរណ៍អំពីរបៀបក្នុងការបញ្ជ្រាបសមាសធាតុសកល ពីអាយុពផ្នាំទៅ១៦ឆ្នាំ ដោយបង្ហាញអំពីទស្សនាទានសំខាន់ៗចំនួន៨ ៖ ភាពជាពលរដ្ឋសកល ដំណោះស្រាយជម្លោះ ពិពិធភាព សិទ្ធិមនុស្ស ភាពអាស្រ័យគ្នាទៅវិញទៅមក ការអភិវឌ្ឍជានិរន្ត តម្លៃនិងទស្សន និងយុត្តិធម៌សង្គម។ ឧទាហរណ៍ សៀវភៅនេះផ្តល់ឱ្យនូវការណែនាំសម្រាប់ការលើកកម្ពស់ការអភិវឌ្ឍបុគ្គល សង្គម និងអារម្មណ៍ សម្រាប់អ្នក |

សិក្សាវ័យក្មេងបំផុត តាមរយៈការពិភាក្សាទៅលើរូបភាពរបស់កុមារមកពីជុំវិញពិភពលោក សកម្មភាព រឿងរ៉ាវ និងការពិភាក្សាអំពីកន្លែងផ្សេងៗដែលកុមារធ្លាប់បានទៅទស្សនា។

**កម្មវិធីសិក្សាចម្រុះ ៖** ការអប់រំភាពជាពលរដ្ឋសកល អាចជម្រុញលើកទឹកចិត្ត និងទទួលផលប្រយោជន៍ពីកិច្ចសហការរបស់គ្រូបង្រៀននៃមុខវិជ្ជាជាច្រើន។ នៅក្នុងបរិបទទាំងនេះ ប្រធានបទដែលទាក់ទងនឹងការអប់រំភាពជាពលរដ្ឋសកល អាចត្រូវបានយកមកសិក្សានៅក្នុងមុខវិជ្ជាជាច្រើន។ វិធីសាស្ត្រកម្មវិធីសិក្សាចម្រុះ ហាក់ដូចជាប្រកបដោយបញ្ហាប្រឈម និងអាចមានការលំបាកនៅក្នុងការអនុវត្ត ប្រសិនបើគ្មានការប្ដេជ្ញាចិត្តជាមុន ឬគ្មានពិសោធន៍នៅក្នុងវិធីសាស្ត្រធ្វើកិច្ចការរបៀបនេះ។ ទោះជាយ៉ាងនេះក្ដី វិធីសាស្ត្រនេះឆ្លើយតបទៅនឹងតម្រូវការនៃការរៀនសូត្រស៊ីជម្រៅជាងមួយរបស់សិស្ស និងលើកកម្ពស់កិច្ចសហប្រតិបត្តិការនៅក្នុងចំណោមក្រុមគ្រូបង្រៀននិងក្រុមកូនសិស្ស។

**ការបញ្ជ្រាបទៅក្នុងមុខវិជ្ជាមួយចំនួន ៖** ការអប់រំភាពជាពលរដ្ឋសកល អាចត្រូវបានបញ្ជ្រាបទៅក្នុងមុខវិជ្ជាជាច្រើន ដូចជាសីលធម៌ សិក្សាសង្គម ការសិក្សាពីបរិស្ថាន ភូមិវិទ្យា ប្រវត្តិវិទ្យា ការអប់រំពីសាសនា វិទ្យាសាស្ត្រ តន្ត្រី និងសិល្បៈ។ មុខវិជ្ជាសិល្បៈ ដែលរួមទាំងសិល្បៈរូបិយ តន្ត្រី និងអក្សរសាស្ត្រ អាចកសាងសមត្ថភាពសម្រាប់ការបញ្ចេញមតិផ្ទាល់ខ្លួន អភិវឌ្ឍអារម្មណ៍នៃភាពជាម្ចាស់ និងសម្របសម្រួលដល់ការយល់ដឹង និងការសន្ទនាជាមួយមនុស្សដែលមកពីវប្បធម៌ផ្សេង។ មុខវិជ្ជាទាំងនេះក៏ដើរតួនាទីដ៏សំខាន់ នៅក្នុងការចោទសួរប្រកបដោយការត្រិះរិះពិចារណា និងការវិភាគទៅលើបញ្ហាសង្គម និងបញ្ហាផ្សេងៗទៀត។ កីឡាក៏អាចផ្ដល់ឱ្យនូវកាលានុវត្តភាពសម្រាប់អ្នកសិក្សា នៅក្នុងការអភិវឌ្ឍការយល់ដឹងរបស់ខ្លួនទៅលើបញ្ហាទាំងឡាយដូចជា ការងារជាក្រុម ពិពិធភាព សាមគ្គីភាពសង្គម និងយុត្តិធម៌។

**មុខវិជ្ជាដាច់ដោយឡែក ៖** មុខវិជ្ជាដាច់ដោយឡែកស្ដីអំពីការអប់រំភាពជាពលរដ្ឋសកល មិនសូវទូលំទូលាយទេ ទោះបីជាប្រទេសមួយចំនួនបានបង្រៀនទិដ្ឋភាពទាំងឡាយនៃការសិក្សាដែលពាក់ព័ន្ធនឹងការអប់រំភាពជាពលរដ្ឋសកលដាច់ដោយឡែកក៏ដោយ។ ឧទាហរណ៍ នៅក្នុងសាធារណរដ្ឋកូរ៉េ កម្មវិធីសិក្សាឆ្នាំ២០០៩បានណែនាំមុខវិជ្ជាចម្បងមួយ ដែលមាន

ចំណងជើងថា«សកម្មភាពពិសោធន៍ប្រកបដោយការច្នៃប្រឌិត» ដែលមានបំណងពង្រឹងកិច្ចសហការ ការច្នៃប្រឌិត និងការកសាងអត្តចរិតនៅក្នុងចំណោមសិស្ស។ ទោះជាយ៉ាងនេះក្តី សកម្មភាពដែលត្រូវបានធ្វើឡើងដើម្បីសម្រេចឱ្យបាននូវគោលបំណងនេះ (ឧទាហរណ៍ អង្គការយុវជន ការស្ម័គ្រចិត្តនៅតាមសាលានិងសហគមន៍ និងការការពារបរិស្ថាន) មានភាពប្រហាក់ប្រហែលទៅនឹងសកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងវិធីសាស្ត្រសាលាទាំងមូល។

ការអប់រំភាពជាពលរដ្ឋសកល ក៏អាចត្រូវបានអនុវត្តនៅក្នុងការអប់រំក្រៅប្រព័ន្ធផងដែរ ឧទាហរណ៍ តាមរយៈការផ្តួចផ្តើមដែលដឹកនាំដោយយុវជន អង្គការក្រៅរដ្ឋាភិបាលចម្រុះ និងកិច្ចសហការជាមួយនឹងស្ថាប័នអប់រំផ្សេងទៀត និងតាមរយៈប្រព័ន្ធអ៊ីនធឺណែត។ ការពិចារណាអាចត្រូវបានផ្តល់ឱ្យភាពជាដៃគូ រវាងសាលានិងតួអង្គសង្គមស៊ីវិល ដែលធ្វើការលើបញ្ហានៅក្នុងមូលដ្ឋាននិងសកល និងការផ្សាភ្ជាប់តួអង្គទាំងនេះទៅក្នុងសកម្មភាពរបស់សាលា។ (សូមមើលឧទាហរណ៍ខាងក្រោម និងឧបសម្ព័ន្ធទី១)

**ឧទាហរណ៍នៅក្នុងប្រទេស**

អែកធីវេត (Activate) គឺជាបណ្តាញមួយនៃក្រុមអ្នកដឹកនាំវ័យក្មេង នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ដែលមានបំណងនាំមកនូវការផ្លាស់ប្តូរ តាមរយៈការបង្កើតដំណោះស្រាយប្រកបដោយការច្នៃប្រឌិតទៅនឹងបញ្ហាទាំងឡាយនៅក្នុងសង្គម។ យុវជនពីគ្រប់មជ្ឈដ្ឋាននិងខេត្តទាំងអស់នៅក្នុងប្រទេស ចូលរួមនៅក្នុងកម្មវិធីមួយដែលមានរយៈពេលពីរឆ្នាំ។ នៅក្នុងឆ្នាំទី១ មានកម្មវិធីបណ្តុះបណ្តាលនៅតាមលំនៅដ្ឋានចំនួនបី ដែលធ្វើការទៅលើកិច្ចការជាក់លាក់មួយ។ នៅក្នុងឆ្នាំទី២ អ្នកចូលរួមបង្កើតក្រុមសកម្មភាព ដែលធ្វើការទៅលើកិច្ចការជាក់លាក់ ដោយបាននាំយកការងាររបស់ពួកគេ ទៅក្នុងបណ្តុំអប់រំសាធារណៈ។ នៅក្នុងឧទាហរណ៍មួយ សមាជិកអែកធីវេតម្នាក់ ពណ៌នាអំពីរបៀបដែលគាត់ធ្វើការនៅក្នុងសហគមន៍មូលដ្ឋានរបស់គាត់ ដើម្បីជម្រុញលើកទឹកចិត្តមនុស្សវ័យក្មេង កុំឱ្យចូលរួមនៅក្នុងសកម្មភាពក្រុមក្មេងទំនើង ឬចូលរួមនៅក្នុងការប្រើប្រាស់គ្រឿងញៀន។ គាត់បានលើកយកបទពិសោធន៍ផ្ទាល់ខ្លួន ជាមួយនឹងក្រុមក្មេងទំនើង និងក្រុមអ្នកប្រើប្រាស់ថ្នាំញៀន ដោយបានជាប់គុកអស់រយៈពេល៧ឆ្នាំ។ នៅក្នុងបទសម្ភាសន៍ គាត់បាននិយាយថា «ទស្សនវិស័យ

របស់ខ្ញុំសម្រាប់ប្រទេសអាហ្វ្រិកខាងត្បូង គឺការមើលឃើញមនុស្សវ័យក្មេងក្រោកឈរឡើង និងក្លាយទៅជាជនគំរូ។ ត្រូវមានការតាំងចិត្តដោយខ្លួនឯង ត្រូវតែពិតប្រាកដ និងប្រឹងប្រែង ដើម្បីសម្រេចនូវក្តីសុបិន្តរបស់អ្នក»។

http://www.activateleadership.co.za/blog/5-mins-with-fernando#sthash.dRCXMqPx.dpuf

**ហាយ រីហ្សូល** (**High Resolves**) គឺជាការផ្តួចផ្តើមការអប់រំនៅក្នុងកម្រិតបឋមភូមិមួយ (ដែលត្រូវបានអនុវត្តដោយអង្គការ FYA ដែលជាអង្គការជាតិមិនរកប្រាក់ចំណេញ និងឯករាជ្យតែមួយគត់សម្រាប់មនុស្សវ័យក្មេងនៅក្នុងប្រទេសអូស្ត្រាលី)។ ការផ្តួចផ្តើមនេះរួមបញ្ចូលកម្មវិធីភាពជាពលរដ្ឋសកលសម្រាប់សិស្សអាយុ៨ឆ្នាំ និងកម្មវិធីភាពជាអ្នកដឹកនាំសកលសម្រាប់សិស្សថ្នាក់ទី៩និងថ្នាក់ទី១០។ កម្មវិធីនេះមានបំណងអនុញ្ញាតឱ្យសិស្ស អាចពិចារណាអំពីតួនាទីផ្ទាល់ខ្លួនរបស់ពួកគេ នៅក្នុងការអភិវឌ្ឍសង្គមឱ្យទៅជាសហគមន៍សកលមួយ តាមរយៈសិក្ខាសាលា ការធ្វើជាគំរូ ការបណ្តុះបណ្តាលជំនាញភាពជាអ្នកដឹកនាំ និងគម្រោងសកម្មភាពដែលអនុវត្តជាក់ស្តែង។ សិស្សជាង៨ម៉ឺននាក់បានចូលរួមនៅក្នុងកម្មវិធីនេះ នៅក្នុងសាលាចំនួន១២០ចាប់តាំងពីឆ្នាំ២០០៥មក។ ឧទាហរណ៍ នៅក្នុងឆ្នាំ២០១៣ សិស្សចូលរួមនៅក្នុងគម្រោងជាច្រើន ដោយធ្វើការទៅលើប្រធានបទផ្សេងៗដូចជាសិទ្ធិរបស់ជនពិការ ការជួញដូរមនុស្ស បរិយាប័ន្នជនភៀសខ្លួន និងការអភិរក្សធនធានសមុទ្រ។

http://www.highresolves.org

http://www.fya.org.au/inside-fya/initiatives/high-resolves

**សន្តិភាពជាចម្បង** (**Peace First**) គឺជាអង្គការមិនរកប្រាក់ចំណេញដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក។ អង្គការនេះមានកម្មវិធីមួយ ដែលក្រុមយុវជនស្ម័គ្រចិត្ត ធ្វើការជាមួយកុមារដើម្បីរៀបចំនិងអនុវត្តគម្រោងសហគមន៍ ដោយប្រើប្រាស់វិធីសាស្ត្រនៃការចូលរួម។ គោលបំណងនៃកម្មវិធីនេះគឺថា កុមារគឺជាអ្នកគិត និងជាអ្នកដោះស្រាយបញ្ហា ប្រកបដោយការច្នៃប្រឌិតបែបធម្មជាតិ។ កម្មវិធីនេះផ្តោតទៅលើការអភិវឌ្ឍជំនាញសង្គម និងជំនាញផ្លូវអារម្មណ៍ សម្រាប់ការភ្ញាក់រឭកដឹងដោយខ្លួនឯង សេចក្តីអាណិតអាសូរ បរិយាប័ន្ន និងទំនាក់

ទំនង។ កម្មវិធីនេះក៏ត្រូវបានអនុវត្តផងដែរនៅក្នុងតំបន់ជនបទនៃប្រទេសកូឡុំប៊ី តាមរយៈភាពជាដៃគូមួយរវាងអាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលកូឡុំប៊ី។ សន្តិភាពជាចម្បងបានអភិវឌ្ឍកម្មវិធីសិក្សាមួយបន្ថែមទៀត ដែលអាចត្រូវបានប្រើប្រាស់នៅតាមសាលា។ កម្មវិធីនេះពិភាក្សាខ្លឹមសារសំខាន់ៗដូចជា មិត្តភាព យុត្តិធម៌ កិច្ចសហការ ដំណោះស្រាយជម្លោះ និងផលវិបាកនៃសកម្មភាព តាមរយៈសកម្មភាពពិសោធន៍ និងល្បែងសហការ។ ឧទាហរណ៍ សិស្សថ្នាក់ទី១ រៀនអំពីរបៀបក្នុងការប្រាស្រ័យទាក់ទងអារម្មណ៍របស់ពួកគេ សិស្សថ្នាក់ទី៣អភិវឌ្ឍជំនាញនិងការយល់ដឹង ជុំវិញការប្រាស្រ័យទាក់ទងនិងកិច្ចសហការ សិស្សថ្នាក់ទី៤អនុវត្តសេចក្តីក្លាហាននិងការប្រកាន់យកនូវជំហរមួយ និងសិស្សថ្នាក់ទី៥ស្វែងរករបៀបក្នុងការដោះស្រាយនិងបន្ថយជម្លោះ។ http://peacefirst.org

### ៣.១.៣. ការអនុវត្តប្រធានបទនេះនៅក្នុងស្ថានភាពលំបាក

នៅក្នុងស្ថានភាពជាក់ស្តែងមួយចំនួន អ្នកអប់រំនិងអ្នកធ្វើគោលនយោបាយ ប្រហែលជានឹងជួបប្រទះសម្ពាធផ្នែកហិរញ្ញវត្ថុនិងធនធាន និងបញ្ហាប្រឈមផ្នែកបរិបទផ្សេងៗទៀត ដែលធ្វើឱ្យមានការលំបាកដល់ការអនុវត្តកំណែទម្រង់ប្រព័ន្ធទាំងមូល និងកម្មវិធីការអប់រំភាពជាពលរដ្ឋសកល។ ឧទាហរណ៍ សាលារៀនប្រហែលជាខ្វះខាតសៀវភៅនិងធនធានផ្សេងៗទៀត ឬមានថ្នាក់រៀនដែលមានចំនួនសិស្សលើសលុប ខណៈពេលដែលគ្រូបង្រៀនប្រហែលជានៅមានកម្រិត ឬមិនដែលទទួលការអប់រំនិងការបណ្តុះបណ្តាលអំពីប្រធានបទនេះ ឬប្រឈមនឹងសម្ពាធក្នុងការរៀបចំសិស្សសម្រាប់ការប្រលងថ្នាក់ជាតិ។ នៅក្នុងបរិបទដែលប្រកបដោយហានិភ័យបែបនេះ វាអាចមានភាពរសើបផ្នែកនយោបាយ សង្គម និងវប្បធម៌បន្ថែមពីលើអាទិភាពប្រកបដោយការប្រកួតប្រជែង សម្រាប់ការអនុវត្តការអប់រំ និងការកសាងប្រព័ន្ធឡើងវិញ ដែលប្រការនេះបានបង្កើតជាបញ្ហាប្រឈមដ៏ចម្បង សម្រាប់ការរៀបចំផែនការ និងការអនុវត្តការអប់រំភាពជាពលរដ្ឋសកល។ នៅក្នុងករណីបែបនេះ ការអប់រំភាពជាពលរដ្ឋសកល អាចត្រូវបានអនុវត្តជាមួយនឹងធនធានកាន់តែមានកម្រិត និងនៅក្នុងស្ថានភាពលំបាក។ ខណៈពេលដែលភាពតឹងតែងផ្នែកធនធាន ឬការផ្តួចផ្តើមជាលក្ខណៈប្រព័ន្ធទាំងមូល ប្រហែលជាមិនប្រាកដប្រជានៅក្នុងរយៈពេលខ្លី មានគោលនយោបាយនិងការធ្វើសេចក្តីសម្រេចចិត្តផ្នែកផែនការ ដែលអាចត្រូវបានធ្វើឡើង ដោយចាប់ផ្តើមពីអ្វីដែលអាចធ្វើ

បានពិតប្រាកដ ដោយបញ្ជ្រាបការអប់រំភាពជាពលរដ្ឋសកលបន្ថែមទៀត ទៅក្នុងប្រព័ន្ធអប់រំនៅគ្រប់កម្រិតទាំងអស់។ ឧទាហរណ៍ ជម្រើសមួយប្រហែលជាត្រូវធ្វើការជាបឋមជាមួយនឹងផ្នែកណាមួយរបស់សាលា ដែលបង្ហាញការចាប់អារម្មណ៍ ឬសាលាដែលមានគម្រោងពាក់ព័ន្ធជាមួយនឹងអង្គការយូណេស្កូ។ ជម្រើសមួយទៀតប្រហែលជាផ្តោតទៅលើទិដ្ឋភាពមួយនៃដំណើរការអប់រំ ដូចជាការបណ្តុះបណ្តាលគ្រូដែលមិនទាន់ចូលបម្រើការងារ និងគ្រូដែលកំពុងបម្រើការងារ ឬធ្វើការកែសម្រួលសៀវភៅសិក្សាគោល ដើម្បីបញ្ចូលទស្សនៃការអប់រំភាពជាពលរដ្ឋសកល។[9] ជម្រើសមួយទៀតគឺផ្តួចផ្តើមគម្រោងសាលា ដែលផ្តល់ឱ្យអ្នកសិក្សានូវកាលានុវត្តភាពនិងការលើកទឹកចិត្ត ដើម្បីសិក្សាបន្ថែមអំពីអ្វីដែលមានន័យថាពលរដ្ឋសកលម្នាក់។ ការគូសបញ្ជាក់គួរតែចាប់ផ្តើមជាមួយនឹងអ្វី ដែលអាចធ្វើបាននិងប្រកបដោយយុទ្ធសាស្ត្រនៅក្នុងបរិបទមួយ (ដែលច្បាស់ជាមានការប្រែប្រួល) និងកសាងគម្រោងនេះឱ្យរីកចំរើនពីត្រឹមដំណាក់កាលនោះទៅ។

[9] សម្រាប់ការពិភាក្សាស៊ីជម្រៅបន្ថែម ស្តីអំពីវិធីសាស្ត្រសម្រាប់ការអនុវត្តការអប់រំភាពជាពលរដ្ឋសាកល នៅក្នុងស្ថានភាពដែលខ្វះខាតនូវប្រភេទធនធាន ឬស្ថានភាពលំបាក សូមអានសៀវភៅ «ការអប់រំនៅពីលើអ្វីៗទាំងអស់ (បោះពុម្ពឆ្នាំ២០១២)» និង «ការអប់រំភាពជាពលរដ្ឋសាកល»។

## ៣.២. តើត្រូវអនុវត្តប្រធានបទនេះនៅក្នុងថ្នាក់រៀនដោយរបៀបណា?

### ៣.២.១. តួនាទីនិងការទ្រទ្រង់សម្រាប់អ្នកអប់រំ

ការអប់រំភាពជាពលរដ្ឋសកល តម្រូវឱ្យមានអ្នកអប់រំប្រកបដោយជំនាញ ដែលមានការយល់ដឹងល្អអំពី ការបង្រៀននិងការរៀនប្រកបដោយការផ្លាស់ប្តូរនិងការចូលរួម។ តួនាទីចម្បងរបស់អ្នកអប់រំ គឺក្លាយទៅជាមគ្គុទេសន៍ និងជាអ្នកសម្របសម្រួល ដោយលើកទឹកចិត្តអ្នកសិក្សាឱ្យចូលរួមនៅក្នុងការចោទសួរប្រកបដោយការត្រិះរិះពិចារណា និងការទ្រទ្រង់ការអភិវឌ្ឍចំណេះដឹង ជំនាញ តម្លៃ និងឥរិយាបថ ដែលលើកកម្ពស់ការផ្លាស់ប្តូរសង្គម និងការផ្លាស់ប្តូរផ្ទាល់ខ្លួនប្រកបដោយភាពវិជ្ជមាន។ ទោះជាយ៉ាងនេះក្តី នៅក្នុងបរិបទជាច្រើនពិសោធន៍របស់អ្នកអប់រំទៅលើវិធីសាស្ត្រទាំងនេះនៅមានកម្រិត។ ការបណ្តុះបណ្តាលគ្រូដែលមិនទាន់ចូលបម្រើការងារ និងកាលានុវត្តភាពជាបន្តបន្ទាប់ សម្រាប់ការសិក្សានិងការអភិវឌ្ឍវិជ្ជាជីវៈ មានសារៈសំខាន់ណាស់ ដើម្បីធានាឱ្យបានថា អ្នកអប់រំមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីអនុវត្តការអប់រំភាពជាពលរដ្ឋសកលប្រកបដោយគុណភាព។[10,11] (សូមមើលឧទាហរណ៍នៃការផ្តួចផ្តើម ដើម្បីទ្រទ្រង់ការអភិវឌ្ឍវិជ្ជាជីវៈរបស់អ្នកអប់រំ នៅក្នុងឧបសម្ព័ន្ធទី ១)។

វាក៏មានសារៈសំខាន់ផងដែរក្នុងការទទួលស្គាល់ថា អ្នកអប់រំអាចអនុវត្តការអប់រំភាពជាពលរដ្ឋសកលប្រកបដោយប្រសិទ្ធភាពបាន លុះត្រាណាតែពួកគេទទួលបានការគាំទ្រនិងការ

---

[10] សូមអានសៀវភៅរបស់អង្គការយូណេស្កូ «ការអប់រំសម្រាប់ទាំងអស់គ្នា» ដោយ Gopinathan និងអ្នកនិពន្ធមួយចំនួនទៀត, បោះពុម្ពផ្សាយដោយសម្ព័ន្ធអន្តរជាតិសម្រាប់វិទ្យាស្ថានអប់រំនាំមុខ (បោះពុម្ពឆ្នាំ២០០៨) និងមូលនិធិ Longview (បោះពុម្ពឆ្នាំ២០០៩)។

[11] សូមអានសៀវភៅរបស់ Kirr (បោះពុម្ពឆ្នាំ២០០៩)

ប្តេជ្ញាចិត្តពីសំណាក់ប្រធានក្រុមបច្ចេកទេស សហគមន៍ និងមាតាបិតា។ ជាងនេះទៅទៀត ការអនុវត្តអាចធ្វើទៅបាន លុះត្រាតែប្រព័ន្ធសាលារៀនអនុញ្ញាតឱ្យប្រើវិធីសាស្ត្រសម្រាប់ការបង្រៀននិងការរៀន ដែលចាំបាច់សម្រាប់ការអប់រំភាពជាពលរដ្ឋសកលប្រកបដោយប្រសិទ្ធភាព។ ឧទាហរណ៍ នៅក្នុងបរិបទជាច្រើន វិធីសាស្ត្របង្រៀនបែបប្រពៃណី ដែលលើកកម្ពស់ការរៀនដោយទន្ទេញចាំមាត់គឺជាទម្លាប់។ ការអនុវត្តអាចធ្វើទៅបាន ប្រសិនបើអ្នកអប់រំមានពេលវេលានិងធនធានគ្រប់គ្រាន់។[12]

## ៣.២.២ បរិស្ថាននៃការសិក្សា

បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាប័ន្ន និងការចូលរួម ក៏មានសារៈសំខាន់ផងដែរសម្រាប់ការអប់រំភាពជាពលរដ្ឋសកល។ បរិស្ថានបែបនេះពង្រីកពិសោធន៍នៃការបង្រៀននិងការសិក្សា គាំទ្រប្រភេទផ្សេងៗនៃការសិក្សា ឱ្យតម្លៃទៅលើចំណេះដឹងនិងបទពិសោធន៍របស់អ្នកសិក្សាដែលមានស្រាប់ និងអនុញ្ញាតឱ្យមានការចូលរួមរបស់អ្នកសិក្សាពីគ្រប់មជ្ឈដ្ឋានទាំងអស់។ បរិស្ថានបែបនេះធានាបានថា អ្នកសិក្សាទាំងអស់មានអារម្មណ៍ថា ខ្លួនត្រូវបានផ្តល់តម្លៃនិងរួមបញ្ចូល និងជម្រុញឱ្យមានកិច្ចសហការ អន្តរកម្មប្រកបដោយសុខភាព ការគោរព ភាពរសើបផ្នែកវប្បធម៌ និងតម្លៃនិងជំនាញផ្សេងៗទៀត ដែលត្រូវការសម្រាប់ការរស់នៅក្នុងពិភពលោកមួយប្រកបដោយពិពិធភាព។ បរិស្ថានរបៀបនេះក៏នឹងផ្តល់ឱ្យនូវលទ្ធភាពប្រកបដោយសុវត្ថិភាពមួយ សម្រាប់ការពិភាក្សាទៅលើប្រធានបទប្រកបដោយភាពចម្រូងចម្រាស់។

អ្នកអប់រំដើរតួនាទីដ៏សំខាន់ នៅក្នុងការបង្កើតបរិស្ថានមួយ សម្រាប់ការសិក្សាប្រកបដោយប្រសិទ្ធភាព។ អ្នកសិក្សាអាចប្រើប្រាស់វិធីសាស្ត្រជាច្រើន ដើម្បីបង្កើតបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាប័ន្ន និងការចូលរួម។ ឧទាហរណ៍ អ្នកសិក្សាអាចធ្វើការជាមួយគ្រូ ដើម្បីយល់ស្របគ្នាទៅលើបទបញ្ញត្តជាមូលដ្ឋានសម្រាប់អន្តរកម្ម។ ថ្នាក់រៀនអាចត្រូវបានរៀបចំឡើង ដើម្បីអនុញ្ញាតឱ្យអ្នកសិក្សា ធ្វើការប្រកបដោយការសហការនៅក្នុងក្រុមតូច។ អ្នកសិក្សាអាចកំណត់ប្រភពធនធាន ដោយមានការគាំទ្រពីគ្រូ ហើយអ្នកសិក្សានឹងទទួលបានលទ្ធភាព ក្នុងការបង្ហាញការងាររបស់ខ្លួន។ ចំណាប់អារម្មណ៍ជាក់លាក់ ត្រូវតែផ្តោតការយក

[12] សូមអានរបាយការណ៍របស់ Ajegbo (បោះពុម្ពឆ្នាំ២០០៧)

ចិត្តទុកដាក់ទៅលើកត្តាទាំងឡាយ ដែលអាចបំផ្លាញដល់បរិយាប័ន្ន និងកម្រិតកាលានុវត្តភាពសម្រាប់ការសិក្សា។ កត្តាទាំងអស់នេះ នៅក្នុងចំណោមកត្តាផ្សេងៗ អាចរួមមានប្រវត្តិផ្នែកសេដ្ឋកិច្ច សមត្ថភាពផ្លូវកាយនិងផ្លូវចិត្ត ពូជសាសន៍ វប្បធម៌ សាសនា យេនឌ័រ និងទំនោរផ្លូវភេទ។

| ឧទាហរណ៍នៅក្នុងប្រទេស |
| --- |
| នៅក្នុងប្រទេស **សៀរ៉ាឡេអូន** នៅក្នុងឆ្នាំ២០០៨ ក្រសួងអប់រំ និងវិទ្យាស្ថានជាតិសម្រាប់ការបណ្តុះបណ្តាលគ្រូ បានធ្វើការជាមួយអង្គការយូនីសេហ្វ (UNICEF) ដើម្បីអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូស្តីអំពី **បញ្ហាកំពុងកើតឡើង** ដែលមានគោលបំណងគាំទ្រការកសាងឡើងវិញក្រោយជម្លោះ តាមរយៈទាំងមាតិកានៃការសិក្សា និងវិធីសាស្ត្រនៃការបង្រៀន។ ការបណ្តុះបណ្តាលគ្រប់ដណ្តប់ទៅលើប្រធានបទខ្លឹមសារសំខាន់ៗដូចជា សិទ្ធិមនុស្ស ភាពជាពលរដ្ឋ សន្តិភាព បរិស្ថាន សុខភាពបន្តពូជ ការប្រើប្រាស់ថ្នាំញៀន សមភាពយេនឌ័រ និងការគ្រប់គ្រងគ្រោះមហន្តរាយ ក៏ដូចជាវិធីសាស្ត្របង្រៀននិងរៀន ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរអាកប្បកិរិយា។ សម្ភារៈឧបទ្ទេសត្រូវបានអភិវឌ្ឍឡើង សម្រាប់មុខវិជ្ជាទាំងឡាយនៅទូទាំងការបណ្តុះបណ្តាលគ្រូដែលមិនទាន់ចូលបម្រើការងារ ក៏ដូចជាការបណ្តុះបណ្តាលគ្រូដែលកំពុងបម្រើការងារ ទាំងលក្ខណៈកម្មវិធីសិក្សាខ្លី និងកម្មវិធីសិក្សាពីចម្ងាយ។<br>http://learningforpeace.unicef.org/resources/sierra-leone-emerging-issues-teacher-training-programme/<br><br>នៅក្នុងប្រទេស **ស្រីឡង្កា** ក្រសួងអប់រំនិងអង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិអាលឺម៉ង់ (GIZ) កំពុងអភិវឌ្ឍកម្មវិធី**ការអប់រំសម្រាប់សាមគ្គីភាពសង្គម (ESC)** ដែលស្របទៅនឹងគោលនយោបាយជាតិឆ្នាំ២០០៨ ស្តីអំពីការអប់រំសម្រាប់សាមគ្គីភាពសង្គមនិងសន្តិភាព។ ដោយត្រូវបានទទួលស្គាល់ថាជាភាពខ្លាំងមួយនៃគម្រោង កម្មវិធីនេះផ្តោតទៅលើសាលាសាកល្បងចំនួន២០០ នៅក្នុងខេត្ត៥នៅក្នុងចំណោមខេត្តទាំងអស់ចំនួន៩នៃប្រទេសនេះ ដែលភាគច្រើនគឺជាតំបន់ដែលងាយទទួលរងគ្រោះ និងតំបន់ក្រោយជម្លោះ និងដែលតំណាងឱ្យក្រុមភាសាផ្សេងៗគ្នា ដែលនៅទីនោះសកម្មភាពទាំងឡាយនៃកម្មវិធីសិក្សា ESC អាចត្រូវ |

បាននាំយកមកជាមួយគ្នានៅក្រោមដំបូលតែមួយ និងដែលអាចធ្វើពិសោធបាន។ សកម្មភាពទាំងនេះគ្របដណ្ដប់ទៅលើផ្នែកចំនួន៤ ដែលរួមមានសន្តិភាពនិងតម្លៃនៃការអប់រំ ការអប់រំពហុភាសា ការថែរក្សាចិត្តសង្គម និងការគ្រប់គ្រងគ្រោះមហន្តរាយ។ ការផ្តោតការយកចិត្តទុកដាក់ គឺទៅលើការអភិវឌ្ឍសាលាទាំងមូល ដែលចាប់ពីការចូលរួមរបស់សិស្ស ទៅការបណ្តុះបណ្តាលនិងការគាំទ្រសម្រាប់គ្រូនិងមន្ត្រីរដ្ឋបាល និងការវាយតម្លៃលទ្ធផលទាំងបរិមាណនិងគុណភាព។ យោងតាមការត្រួតពិនិត្យមើលទៅលើកម្មវិធី សាលាសាកល្បងទាំងនេះ បានដើរតួជាគំរូរួចទៅហើយ សម្រាប់ការងារសាលាទាំងមូលបែបនេះ។ http://www.giz.de/en/worldwide/18393.html

## ៣.២.៣. ការអនុវត្តការបង្រៀននិងការរៀន

ដោយសារកាយល់ដឹងអំពីការអប់រំភាពជាពលរដ្ឋសកល មានការវិវឌ្ឍទៅមុខ មានការផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនឡើង ទៅលើការអនុវត្តការបង្រៀននិងការរៀនដែលពាក់ព័ន្ធ ដោយទទួលស្គាល់ថា ការអនុវត្តដែលមានស្រាប់ ជាញឹកញយផ្តោតទៅលើទម្រង់ជាក់លាក់នៃការសិក្សា។[13] នៅក្នុងការអប់រំភាពជាពលរដ្ឋសកល ការចូលរួម អ្នកសិក្សាមជ្ឈមណ្ឌល ការបង្រៀនប្រកបដោយបរិយាប័ន្ន និងការអនុវត្តការរៀន គឺជាចំណុចសំខាន់ដូចគ្នាទៅនឹងការចូលរួមរបស់សិស្សនៅក្នុងជម្រើសផ្សេងៗ អំពីដំណើរការនៃការបង្រៀននិងការរៀន។ ការអនុវត្តបែបនេះគឺជាមូលដ្ឋានគ្រឹះ ទៅនឹងចេតនានៃការផ្លាស់ប្តូរការអប់រំភាពជាពលរដ្ឋសកល។ វិសាលភាពទូលំទូលាយនិងការសិក្សាស៊ីជម្រៅ ពាក់ព័ន្ធនឹងការអប់រំភាពជាពលរដ្ឋសកល ក៏តម្រូវឱ្យមានការអនុវត្តការបង្រៀននិងការរៀនប្រកបដោយភាពវៃឆ្លាតដែលការអនុវត្តមួយចំនួនរួមមាន ការរៀនសូត្រដែលផ្អែកលើគម្រោង គម្រោងនៃការចូលរួមការងារបែបសហការ ការរៀនសូត្របែបពិសោធន៍ និងការរៀនសូត្រពីសេវាកម្ម។ មានការកើនឡើងនូវបណ្តុំចំណេះដឹងនិងប្រភពធនធានសម្រាប់អ្នកអប់រំ ដើម្បីជួយពួកគេក្នុងការស្វែងរកនិងការបញ្ចូលភាពជាពលរដ្ឋសកល ទៅក្នុងសាលាទាំងមូល និងការអនុវត្តនៅតាមថ្នាក់រៀន

---

[13] សូមអានសៀវភៅរបស់ Evans (បោះពុម្ពឆ្នាំ២០០៨), សៀវភៅរបស់ Kerr (បោះពុម្ពឆ្នាំ២០០៦) និងសៀវភៅរបស់ Paker (បោះពុម្ពឆ្នាំ១៩៩៥)។

(សូមមើលប្រភពធនធាននៅក្នុងឧបសម្ព័ន្ធទី១)។ ប្រអប់ខាងក្រោមកំណត់នូវការអនុវត្តការបង្រៀននិងការរៀនចម្បងៗ សម្រាប់ការអប់រំភាពជាពលរដ្ឋសកល។

**ការអប់រំភាពជាពលរដ្ឋសកល ត្រូវការការអនុវត្តការបង្រៀននិងការរៀនចម្បងៗដែល ៖**

- បណ្តុះនូវសាលារៀនមួយ ដែលប្រកបដោយការគោរព បរិយាប័ន្ន និងអន្តរកម្ម និងបណ្តុះគោលការណ៍របស់សាលា (ឧទាហរណ៍ សមភាពយេនឌ័រ បរិយាប័ន្ន ការចែករំលែកការយល់ដឹងអំពីបទដ្ឋានថ្នាក់រៀន សម្លេងរបស់សិស្ស ការរៀបចំការអង្គុយ និងការប្រើប្រាស់ទីធ្លា)។
- បណ្តុះគំនិតសិស្សមជ្ឈមណ្ឌល និងវប្បធម៌នៃវិធីសាស្ត្រនៃការរៀននិងការបង្រៀន ប្រកបដោយអន្តរកម្ម ឯករាជ្យ និងការឆ្លើយតប ដែលស្របទៅនឹងគោលដៅនៃការសិក្សា (ឧទាហរណ៍ ការសិក្សាដោយឯករាជ្យនិងសហការ និងចំណេះដឹងផ្នែកសារព័ត៌មាន)។
- បញ្ចូលកិច្ចការយថាភូត (ឧទាហរណ៍ បង្កើតពិពណ៌ស្តីអំពីសិទ្ធិកុមារ បង្កើតកម្មវិធីការកសាងសន្តិភាព បង្កើតកាសែតសម្រាប់សិស្សសម្រាប់ដោះស្រាយបញ្ហាសកល)។
- ដាក់បញ្ចូលប្រភពធនធាននៃការសិក្សា ដែលមានទំនោរទៅរកលក្ខណៈសកល ដែលជួយអ្នកសិក្សានៅក្នុងការយល់ដឹង អំពីរបៀបដែលពួកគេអាចសម្របខ្លួនចូលទៅក្នុងពិភពលោក ទាក់ទងទៅនឹងស្ថានភាពនៅកម្រិតមូលដ្ឋានរបស់ពួកគេ (ឧទាហរណ៍ ការប្រើប្រាស់ប្រភពធនធាននិងសារព័ត៌មានផ្សេងៗជាច្រើន និងគោលគំនិតបែបប្រៀបធៀបនិងពិពិធភាព)។
- ប្រើប្រាស់យុទ្ធសាស្ត្រនៃការវាយតម្លៃ ដែលស្របទៅនឹងគោលដៅនៃការសិក្សា និងទម្រង់នៃការណែនាំ ដែលត្រូវបានប្រើប្រាស់សម្រាប់គាំទ្រដល់ការសិក្សា (ឧទាហរណ៍ ការឆ្លុះបញ្ចាំង និងស្វ័យវាយតម្លៃ ការផ្តល់យោបល់ត្រឡប់ពីមិត្តភក្តិ ការវាយតម្លៃពីគ្រូ ទិន្នានុប្បវត្តិ និងសំណុំនៃការសិក្សា)។
- ផ្តល់កាលានុវត្តភាពដល់អ្នកសិក្សា ដើម្បីពិសោធនការសិក្សានៅក្នុងបរិបទផ្សេងៗ ដែលរួមមាននៅក្នុងថ្នាក់រៀន សកម្មភាពនៅក្នុងសាលាទាំងមូលនិងសហគមន៍ ពី

ថ្នាក់មូលដ្ឋានទៅថ្នាក់សកល (ឧទាហរណ៍ ការចូលរួមនៅក្នុងសហគមន៍ ការផ្លាស់ប្តូរជាអន្តរជាតិតាមប្រព័ន្ធអ៊ីនធឺណែត និងសហគមន៍សោតទស្សន៍)។

- គូសបញ្ជាក់អំពីតួនាទីជាគំរូរបស់គ្រូនិងអ្នកអប់រំ (ឧទាហរណ៍ បច្ចុប្បន្នភាពនៃព្រឹត្តិការនាពេលបច្ចុប្បន្ន ការចូលរួមរបស់សហគមន៍ ការអនុវត្តបទដ្ឋានប្រកបដោយសមភាពនិងបរិស្ថាន)។
- ប្រើប្រាស់អ្នកសិក្សានិងគ្រួសាររបស់ពួកគេ ជាប្រភពធនធានសម្រាប់ការបង្រៀននិងការរៀន ជាពិសេសនៅក្នុងបរិស្ថានពហុវប្បធម៌។

ប្រភព ៖ Evans, M និងអ្នកនិពន្ធផ្សេងទៀត (បោះពុម្ពឆ្នាំ២០០៩) រៀបចំ«សមាសធាតុសកល»នៃការអប់រំអំពីភាពជាពលរដ្ឋ នៅក្នុងប្រទេសកាណាដា ៖ ទំនាក់ទំនងដ៏ស្មុគស្មាញរវាងទ្រឹស្តី ការអនុវត្ត និងបរិបទ។ «ភាពជាពលរដ្ឋ ការបង្រៀន និងការរៀន» លេខទី២ ភាគ ៥ ទំព័រ១៦-៣៤។

វាក៏មានសារៈសំខាន់ណាស់ដែរ ក្នុងការធានាថា ការជ្រើសរើសការអនុវត្តការបង្រៀននិងការរៀន ត្រូវបានតាក់តែងឡើង ដើម្បីសម្រេចឱ្យបាននូវវត្ថុបំណងនៃការសិក្សាដែលត្រូវបានរំពឹងទុក និងថាមានភាពស្របគ្នារវាងសកម្មភាព កិច្ចការ សមត្ថភាពរំពឹងទុក និងវត្ថុបំណងនៃការសិក្សា។[14] សកម្មភាពនៃការសិក្សាដូចជាការពិភាក្សានៅក្នុងថ្នាក់ អានអត្ថបទមួយ ឬមើលខ្សែភាពយន្ត ហើយឆ្លើយនឹងសំណួរ ត្រូវបានតាក់តែងឡើងដើម្បីជំរុញការអភិវឌ្ឍការត្រិះរិះពិចារណានិងជំនាញសង្គម ស្វែងរកតម្លៃ គាំទ្រដល់ការទទួលបានចំណេះដឹង និងអភិវឌ្ឍសមត្ថភាពជាក់ស្តែង។ ការអនុវត្តការបង្រៀននិងការរៀនដែលមានភាពស្មុគស្មាញជាងនេះ (ឧទាហរណ៍ ការស៊ើបអង្កេតជាក្រុម ការវិភាគទៅលើបញ្ហា ការសិក្សាផ្អែកលើបញ្ហា និងសកម្មភាពសង្គម) ត្រូវបានតាក់តែងឡើង ដើម្បីគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនិងជាក់លាក់ជាច្រើន នៅក្នុងស្មារតីនៃការបញ្ច្រាបចូលគ្នាមួយ។[15] កិច្ចការជីវិតជាក់ស្តែង ឬការបង្ហាញប្រកបដោយយថាភូត ដូចជាគម្រោងស្រាវជ្រាវប្រធានបទសកល សកម្មភាពសេវាសហគមន៍ ការតាំងពិពណ៌ព័ត៌មានសាធារណ និងវេទិកាយុវជនអន្តរជាតិតាមបណ្តាញអ៊ីន

[14] សូមអានសៀវភៅរបស់ Mortimore (បោះពុម្ពឆ្នាំ១៩៩៩)។

[15] សូមអានសៀវភៅរបស់ Joyce និង Weil (បោះពុម្ពឆ្នាំ២០០៨)។

ធីណែត ត្រូវបានប្រើប្រាស់កាន់តែច្រើន ដើម្បីអភិវឌ្ឍសមត្ថភាព ដែលពាក់ព័ន្ធនឹងការអប់រំភាពជាពលរដ្ឋសកល។[16]

បច្ចេកវិជ្ជាព័ត៌មាននិងទំនាក់ទំនង (ITC) និងសារព័ត៌មានសង្គម ផ្ដល់កាលានុវត្តភាពក្នុងការគាំទ្រការបង្រៀននិងការរៀនការអប់រំភាពជាពលរដ្ឋសកល (សូមមើលប្រអប់ខាងក្រោម) ដោយតភ្ជាប់ថ្នាក់រៀនទៅនឹងសហគមន៍ និងចែករំលែកគំនិតនិងធនធាន។ ទិដ្ឋភាពដែលត្រូវពិចារណារួមមាន បច្ចេកវិជ្ជាដែលមាន (ឧទាហរណ៍ អ៊ីនធឺណែត ភាពយន្ត ទូរស័ព្ទចល័ត ការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអ៊ីនធឺណែត) និងរបៀបដែលអ្នកសិក្សាអាចប្រើប្រាស់បច្ចេកវិជ្ជាព័ត៌មាននិងទំនាក់ទំនង និងសារព័ត៌មានសង្គម នៅក្នុងការអប់រំភាពជាពលរដ្ឋសកល (ឧទាហរណ៍ ការបង្កើតកម្មវិធីវិទ្យុ ការសរសេរប្លុក ការស្រាវជ្រាវ ការធ្វើអន្តរកម្មជាមួយនឹងស្ថានភាពជីវិតជាក់ស្ដែង និងការសហការជាមួយអ្នកសិក្សាផ្សេងទៀត)។ ការរៀនពីចម្ងាយនិងការរៀនតាមប្រព័ន្ធអ៊ីនធឺណែត និងវេទិការចែករំលែកព័ត៌មាន ក៏អាចត្រូវបានប្រើប្រាស់ដោយអ្នកអប់រំ ដើម្បីអភិវឌ្ឍការយល់ដឹងនិងសមត្ថភាពផ្ទាល់ខ្លួនផងដែរ។

**ឧទាហរណ៍នៅក្នុងប្រទេស**

គំនិតផ្ដួចផ្ដើមកម្មវិធី**ការតភ្ជាប់ថ្នាក់រៀន** របស់ក្រុមប្រឹក្សាអង់គ្លេស បានបង្កើតភាពជាដៃគូរវាងថ្នាក់រៀនពីផ្នែកផ្សេងៗនៃពិភពលោក ដោយផ្ដល់ឱ្យអ្នកសិក្សានូវកាលានុវត្តភាព ក្នុងការទទួលបានការយល់ដឹងមួយអំពីវប្បធម៌ផ្សេងៗ និងចូលរួមនៅក្នុងបញ្ហា និងអភិវឌ្ឍជំនាញនៃភាពជាពលរដ្ឋសកល។ គ្រូអភិវឌ្ឍជំនាញរបស់ខ្លួនក្នុងការបង្រៀនប្រធានបទទាំងឡាយ ដែលទាក់ទងនឹងភាពជាពលរដ្ឋសកល សិក្សាអំពីប្រព័ន្ធអប់រំផ្សេងៗ និងធ្វើឱ្យប្រសើរឡើងនូវជំនាញបង្រៀនរបស់ខ្លួន។ ឧទាហរណ៍មួយគឺភាពជាដៃគូរវាងសាលាបឋមសិក្សានៅក្នុងតំបន់ជនបទ Linclnshire ក្នុងប្រទេសអង់គ្លេស និងសាលាបឋមសិក្សានៅក្នុងទីក្រុង Beirut ក្នុងប្រទេស លីបង់ (Lebanon) ដែលសិស្សមានឱកាសក្នុងការនិយាយទៅកាន់គ្នាតាមរយៈ ប្រព័ន្ធ Skype ទៅលើខ្លឹមសារស្ដីអំពី«ការរស់នៅជាមួយគ្នា»។ ដោយសារ

[16] សូមអានសៀវភៅរបស់ Andreotti (បោះពុម្ពឆ្នាំ២០០៦), Larsen (បោះពុម្ពឆ្នាំ២០០៨), ទទួលយកជាសាកល (បោះពុម្ពឆ្នាំ២០១២), គិតជាសាកល (បោះពុម្ពឆ្នាំ២០១៣), និងគម្រោងសាលារៀនដែលពាក់ព័ន្ធនឹងអង្គការយូណេស្កូ។

វិបត្តិដែលចេះតែបន្តនៅក្នុងប្រទេស ស៊ីរី (Syria) សាលានៅក្នុងទីក្រុង Beirut មានសិស្សដែលជាជនភៀសខ្លួនជនជាតិ ស៊ីរី ជាច្រើន ក៏ដូចជាសិស្សដែលជាជនជាតិ លីបង់ និង ប៉ាលេស្ទីន ផងដែរ។ កម្មវិធីផ្តួចផ្តើមគំនិតបានបង្កើតអារម្មណ៍នៃសេចក្តីអាណិតអាសូរ រវាងសិស្សនៅក្នុងសាលាទាំងពីរ និងលើកកម្ពស់សេចក្តីអាណិតអាសូររវាងសហគមន៍ផ្សេងៗដែលស្ថិតនៅជុំវិញសាលានៅក្នុងទីក្រុង Beirut។

https://schoolsonline.britishcouncil.org/linking-programmes-worldwide/connecting-classrooms/spotlight/Lebanon

នៅក្នុង**ប្រទេសអង់គ្លេស** សាលាអនុវិទ្យាល័យមួយនៅក្នុងទីក្រុង Slough បានផ្តួចផ្តើមទំនាក់ទំនងមួយជាមួយសាលាមួយនៅក្នុងទីក្រុង Delhi **ក្នុងប្រទេសឥណ្ឌា**។ ជាង៩០ភាគរយនៃសិស្សនៅក្នុងសាលាក្នុងទីក្រុង Slough គឺមានដើមកំណើតពីអាស៊ីខាងត្បូង។ ការតភ្ជាប់នេះត្រូវបានមើលឃើញថា គឺជាវិធីមួយក្នុងការជួយអ្នកសិក្សា ក្នុងការរក្សាទំនាក់ទំនងជាមួយនឹងដើមកំណើតនៃវប្បធម៌របស់ពួកគេ ក៏ដូចជាអនុញ្ញាតឱ្យគ្រូអភិវឌ្ឍការយល់ដឹងប្រសើរជាងមុន ទៅលើប្រវត្តិវប្បធម៌របស់សិស្ស។ តាមរយៈការអភិវឌ្ឍទំនាក់ទំនងនៅលើមូលដ្ឋានមួយទល់នឹងមួយ ដោយប្រើប្រាស់ទាំងអ៊ីនធឺណែតនិងអ៊ីម៉េល កុមារនិងគ្រូដែលចូលរួមនៅក្នុងកម្មវិធីនេះ បានអភិវឌ្ឍកិច្ចសន្ទនាជាបន្តបន្ទាប់ និងគោលគំនិតជាសកល។

http://webarchive.nationalarchives.gov.uk/20130401151716/

http://education.gov.uk/publications/eorderingdownload/1409-2005pdf-en-01.pdf

iEARN គឺជាអង្គការមិនរកប្រាក់ចំណេញ ដែលជាបណ្តាញសាលានិងអង្គការយុវជនជាង៣ម៉ឺន នៅក្នុងប្រទេសជាង១៤០។ iEARN គាំទ្រគ្រូបង្រៀននិងមនុស្សវ័យក្មេង ក្នុងការធ្វើការជាមួយគ្នាតាមប្រព័ន្ធអ៊ីនធឺណែត ដោយប្រើប្រាស់អ៊ីនធឺណែត និងបច្ចេកវិជ្ជាទំនាក់ទំនងផ្សេងទៀត។ នៅរៀងរាល់ថ្ងៃ សិស្សជាងពីរលាននាក់ ចូលរួមនៅក្នុងការងារគម្រោងសហការនៅទូទាំងពិភពលោក តាមរយៈ iEARN។ http://www.iearn.org/

នៅក្នុងប្រទេស **ណៃជីរៀ** (Nigeria) និងប្រទេស **ស្កុតឡែន** (Scotland) **អំណាចនយោបាយ** ដែលជាគម្រោងសហការមួយដែលទាក់ទងទៅនឹងសាលា មានគោលបំណងលើកកម្ពស់ការយល់ដឹង អំពីប្រធានបទនៃការអភិវឌ្ឍជាសកល និងដើម្បីលើកកម្ពស់ទំនាក់ទំនងរវាងប្រទេសនិងប្រទេស។ ដោយធ្វើការជាមួយអ្នកសិក្សានិងគ្រូនៅក្នុងទីក្រុង Port Harcourt នៃប្រទេស ណៃជីរៀ និងនៅក្នុងទីក្រុង Aberdeen នៃប្រទេស ស្កុតឡែន គម្រោងនេះបានអភិវឌ្ឍឯកសារកម្មវិធីសិក្សា ដែលឆ្លើយតបទៅនឹងបញ្ហាទាំងឡាយ ទាក់ទងទៅនឹងប្រេងនិងឧស្ម័ន ដែលជាឧស្សាហកម្មចម្បងនៅក្នុងតំបន់ទាំងពីរ។ ឧទាហរណ៍ សិស្សនៅក្នុងទីក្រុង Port Harcourt បានផលិតខ្សែភាពយន្តមួយ អំពីផលប៉ះពាល់វិជ្ជមាននិងអវិជ្ជមាននៃប្រេងទៅលើប្រទេសរបស់ពួកគេ ដោយកំណត់ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គម បរិស្ថាន និងនយោបាយ។ សិស្សមកពីទីក្រុង Aberdeen បានអភិវឌ្ឍរឿងថ្លុក ដើម្បីពន្យល់អំពីគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (MDGs) និងដើម្បីគិតអំពីរបៀបក្នុងការកំណត់អាទិភាព សម្រាប់របៀបវារៈសម្រាប់ក្រោយឆ្នាំ២០១៥។ http://www.powerpolitics.org.uk/resources

**ការប្រព្រឹត្តជាសកលសម្រាប់អ្នកអប់រំ** គឺជាបណ្ដាញនៃសាលាចំនួន៤ពាន់ និងគ្រូ១ម៉ឺន១ពាន់នាក់នៅក្នុងប្រទេសចំនួន១២៥ ដែលមានបំណងផ្តល់អំណាចឱ្យមនុស្សវ័យក្មេង ដើម្បីសិក្សានិងចូលរួមនៅក្នុងបញ្ហាប្រឈមជាសកល ដោយផ្តោតទៅលើភាពជាពលរដ្ឋសកល ភាពជាអ្នកថែរក្សាបរិស្ថាន និងសម្លេងសិស្ស។ អ្នកអប់រំទទួលបានការគាំទ្រក្នុងការប្រើប្រាស់បច្ចេកវិជ្ជា ដើម្បីបង្កើតពិសោធន៍នៃការសិក្សាប្រកបដោយការផ្លាស់ប្តូរ សម្រាប់សិស្សរបស់ពួកគេ។ បណ្ដាញនេះផ្តល់ឱ្យនូវសហគមន៍អ្នកអប់រំ ដែលមានចំណាប់អារម្មណ៍នៅក្នុងការសហការ ទៅលើគម្រោងសិក្សាជាអន្តរជាតិ និងវេទិការថ្នាក់រៀនតាមប្រព័ន្ធកុំព្យូទ័រដែលមានសុវត្ថិភាពនិងមិនមានការផ្សព្វផ្សាយពាណិជ្ជកម្ម ដែលត្រូវបានតាក់តែងឡើងដើម្បីគាំទ្រកិច្ចសហការជាអន្តរជាតិ តាមរយៈការប្រើប្រាស់ឧបករណ៍ព័ត៌មានឌីជីថល។ វាក៏ផ្តល់ឱ្យនូវការអភិវឌ្ឍប្រកបដោយវិជ្ជាជីវៈនិងអាចអនុវត្តបាននូវមុខវិជ្ជាសិក្សាតាមប្រព័ន្ធអ៊ីនធឺណែត ការពិភាក្សាតាមអ៊ីនធឺណែត និងសិក្ខាសាលាដោយផ្ទាល់ ទៅលើភាពជាពលរដ្ឋសកល ភាពជាអ្នកថែរក្សាបរិស្ថាន និងសម្លេងសិស្ស។ វាក៏ផ្តល់ឱ្យនូវកម្មវិធីជាច្រើន ដែលបើកចំហរសម្រាប់ថ្នាក់រៀនទាំងអស់នៅជុំវិញពិភពលោក ដែលផ្តល់ឱ្យនូវវិធីប្រកបដោយ

ការច្នៃប្រឌិត ដើម្បីបង្រៀននិងរៀនអំពីបញ្ហាជាសកល និងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃបញ្ហាទាំងឡាយ កម្មវិធីសិក្សាដែលផ្សាភ្ជាប់ទៅនឹងប្រភពធនធានស្តីអំពីការអប់រំសកល ដែលអភិវឌ្ឍដោយគ្រូនិងសម្រាប់គ្រូ។ បណ្តាញសកម្មភាពយុវជនសកល ដែលជាកម្មវិធីនៃការប្រព្រឹត្តជាសកលសម្រាប់អ្នកអប់រំ ក៏បានបង្កើតការិយាល័យកណ្តាល សម្រាប់គាំទ្រចលនាយុវជន និងសកម្មជនយុវជន។

http://www.tigweb.org http://www.youthlink.org/gyanv5/index.htm

នៅក្នុងគំនិតផ្តួចផ្តើមរួមមួយរវាងរដ្ឋាភិបាល ទុយនេស៊ី (Tunisia) វិទ្យាស្ថានអារ៉ាប់សម្រាប់សិទ្ធិមនុស្ស អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងទីភ្នាក់ងារអង្គការសហប្រជាជាតិ ប្រទេសទុយនេស៊ី បានបង្កើតក្លិបសាលារៀនស្តីពីសិទ្ធិមនុស្សនិងភាពជាពលរដ្ឋ នៅក្នុងសាលាបឋមសិក្សានិងអនុវិទ្យាល័យចំនួន២៥។ គោលបំណងគឺដើម្បីផ្ទេរចំណេះដឹងអំពីប្រជាធិបតេយ្យ ដែលផ្សាភ្ជាប់ទៅនឹងបរិបទសង្គម និងដើម្បីផ្សព្វផ្សាយតម្លៃនិងគោលការណ៍ស្តីពីសិទ្ធិមនុស្សនិងភាពជាពលរដ្ឋ នៅក្នុងចំណោមយុវជនដែលប្រកបដោយការអប់រំ ដោយប្រើប្រាស់គរុកោសល្យនៃការចូលរួម ដែលមានទំនោរទៅរកគម្រោងនៃភាពជាពលរដ្ឋ។ ក្លិបសាលាដំបូងត្រូវបានបើកនៅក្នុងសាលាបឋមសិក្សា Bab Khaled នៅក្នុងស្រុក Mellassine ដែលជាស្រុកក្រីក្រមួយនៃរដ្ឋធានី ទុយនីស។ សិស្សចូលរួមនៅក្នុងការគ្រប់គ្រងទីធ្លាសាលារបស់ខ្លួន និងនៅក្នុងគម្រោងសហគមន៍ ដើម្បីអភិវឌ្ឍជំនាញសម្រាប់ការចូលរួមរបស់ពលរដ្ឋ និងដើម្បីលើកកម្ពស់សហគមន៍មូលដ្ឋាន។

http://www.unesco.org/new/en/media-services/single-view/news/launch_of_the_first_citizenship_and_human_rights_school_club_in_tunisia/#.VDoyblFpvJw

## ៣.៣. តើត្រូវវាយតម្លៃលទ្ធផលសិក្សាដោយរបៀបណា

ការវាយតម្លៃការអប់រំភាពជាពលរដ្ឋសកល អាចបម្រើឱ្យគោលបំណងផ្សេងៗគ្នា។ ឧទាហរណ៍ ការវាយតម្លៃអាចត្រូវបានប្រើប្រាស់សម្រាប់ ៖

- ប្រមូលព័ត៌មាន និងកត់ត្រាការរីកចំរើននិងសមិទ្ធិផលរបស់អ្នកសិក្សា សំដៅទៅរកការរំពឹងទុកនៅក្នុងកម្មវិធីសិក្សា។
- ឆ្លើយឆ្លងការរីកចំរើនទៅកាន់អ្នកសិក្សា កំណត់ចំណុចខ្លាំងនិងចំណុចសម្រាប់កែលម្អ និងប្រើប្រាស់ព័ត៌មាននេះ ដើម្បីកំណត់គោលដៅនៃការសិក្សា។
- ណែនាំការធ្វើសេចក្តីសម្រេចចិត្ត សម្រាប់ការដាក់ពិន្ទុដល់អ្នកសិក្សា និងសម្រាប់ជម្រើសនៃការសិក្សានិងអាជីព។
- ផ្តល់យោបល់ត្រឡប់អំពីជោគជ័យនៃដំណើរការនៃការបង្រៀន និង/ឬមុខវិជ្ជា/កម្មវិធី ដើម្បីជួយដល់ការធ្វើផែនការ ការអនុវត្ត និងការធ្វើឱ្យប្រសើរឡើងនូវសេចក្តីណែនាំ។

នៅក្នុងក្របខណ្ឌនៃសេចក្តីណែនាំនេះ ការវាយតម្លៃត្រូវបានពិចារណាជាបឋម នៅក្នុងបរិបទនៃការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៃការសិក្សា និងការជួយកំណត់ភាពខ្លាំងនិងកន្លែងដែលត្រូវកែលម្អ សម្រួលកម្មវិធីសិក្សានិងវិធីសាស្ត្រនៃការធ្វើសេចក្តីណែនាំទៅតាមតម្រូវការរបស់អ្នកសិក្សា និងវាយតម្លៃប្រសិទ្ធភាពទូទៅនៃការអនុវត្តកម្មវិធីនិងការអនុវត្តនៅក្នុងថ្នាក់រៀន។ វាមានសារៈសំខាន់ ដែលការវាយតម្លៃត្រូវតែធ្វើឡើងឱ្យហួសពីចំណេះដឹងទៅលើការពិតរបស់អ្នកសិក្សា ហើយត្រូវរួមបញ្ចូលការវាយតម្លៃទៅលើជំនាញ តម្លៃ និងឥរិយាបថផងដែរ។

សំណួរផ្សេងគ្នាត្រូវតែពិចារណា នៅពេលធ្វើផែនការសម្រាប់ការវាយតម្លៃ ទៅលើការអប់រំភាពជាពលរដ្ឋសកល ដែលសំណួរទាំងនោះមានដូចជា ៖

- តើអ្វីជាទិដ្ឋភាពសំខាន់នៃការសិក្សា ដែលត្រូវដោះស្រាយនៅក្នុងផែនការវាយតម្លៃគ្រប់ជ្រុងជ្រោយ?
- តើយើងនឹងដឹងថា អ្នកសិក្សារៀនបានជោគជ័យដោយរបៀបណា? តើសុញ្ញនករអ្វីខ្លះអាចត្រូវបានប្រើប្រាស់?
- តើអ្វីដែលយើងនឹងទទួលយកជាភស្តុតាង នៃការយល់ដឹងនិងការអភិវឌ្ឍជំនាញរបស់អ្នកសិក្សា?
- តើប្រភេទនៃការវាយតម្លៃអ្វី ដែលមានប្រយោជន៍បំផុត នៅក្នុងការប្រមូលភស្តុតាងនៃការសិក្សា?

វិធីសាស្ត្រដែលត្រូវបានជ្រើសរើសយក អាស្រ័យទៅលើបរិបទ ដោយសារប្រព័ន្ធអប់រំផ្សេងគ្នា ត្រូវការវិធីសាស្ត្រផ្សេងគ្នា នៅក្នុងការវាយតម្លៃការសិក្សា។ វាក៏នឹងអាស្រ័យទៅលើរបៀបដែលការអប់រំភាពជាពលរដ្ឋសកល ត្រូវបានអនុវត្ត ឧទាហរណ៍នៅទូទាំងកម្មវិធីសិក្សា ឬនៅក្នុងមុខវិជ្ជាជាក់លាក់ណាមួយ ឬគំរូណាផ្សេងទៀត។

វិធីសាស្ត្រក្នុងការវាយតម្លៃ Formative ឬ Summative ត្រូវតែស្របជាមួយនឹងវត្ថុបំណងនៃការសិក្សា និងការអនុវត្តការបង្រៀននិងការរៀន។ ដោយសារវត្ថុបំណងនៃការសិក្សានិង

សមត្ថភាពសិក្សាមានភាពផ្សេងៗគ្នា ដែលមាននៅក្នុងការអប់រំភាពជាពលរដ្ឋសកល វិធីសាស្ត្រជាច្រើនប្រហែលជាត្រូវការ (ឧទាហរណ៍ កិច្ចការផ្ទះ ការបង្ហាញ ការអង្កេត គម្រោង កិច្ចការអនុវត្ត ការធ្វើតេស្ត) ដើម្បីវាយតម្លៃការសិក្សាឱ្យបានត្រឹមត្រូវ។ វិធីសាស្ត្រនៃការវាយតម្លៃដែលចង្អៀតពេក នឹងផ្តល់ឱ្យនូវលទ្ធផលមានកម្រិត នូវអ្វីដែលអ្នកសិក្សាបានរៀន។

អ្នកអប់រំការអប់រំភាពជាពលរដ្ឋសកល អាចពិចារណាគោលបំណងនៃការវាយតម្លៃទូលំទូលាយជាងមួយ និងធ្វើឱ្យលើសពីការប្រើប្រាស់ប្រកបដោយអបរិយាប័ន្ននៃ**ការវាយតម្លៃនៃការសិក្សា** (assessment of learning) ទៅបញ្ចូល**ការវាយតម្លៃសម្រាប់ការសិក្សា** (assessment for learning) និង**ការវាយតម្លៃក្នុងនាមជាការសិក្សា** (assessment as learning)។ នេះគឺជាការចាំបាច់ជាក់ស្តែង ដោយសារការវាយតម្លៃទាំងនេះទាក់ទងទៅនឹងទិដ្ឋភាពមួយនៃការអប់រំ ដែលមានគោលបំណងក្នុងការផ្លាស់ប្តូរយ៉ាងធំសម្បើម។ ការអនុវត្តនាពេលបច្ចុប្បន្នបង្ហាញថា អ្នកអប់រំប្រើប្រាស់វិធីសាស្ត្រចម្រុះ នៃវិធីសាស្ត្រវាយតម្លៃជាប្រពៃណី និងវិធីសាស្ត្រដែលមានការឆ្លុះបញ្ចាំងជាងនិងផ្អែកលើលទ្ធផលនៃស្នាដៃនៃការអនុវត្ត ដូចជាស្វ័យវង្វាយតម្លៃ និងវង្វាយតម្លៃគ្នាទៅវិញទៅមក ដែលចាប់បានទៅលើការយល់ដឹងរបស់អ្នកសិក្សាទៅលើ ឧទាហរណ៍ការផ្លាស់ប្តូរផ្ទាល់ខ្លួន ការយល់ដឹងស៊ីជម្រៅទៅលើការចោទសួរប្រកបដោយការត្រិះរិះពិចារណា ការចូលរួម និងទីភ្នាក់ងារពលរដ្ឋ។ ការអនុវត្តការវាយតម្លៃមានគោលបំណងវាយតម្លៃទាំងការរីកចំរើនផ្ទាល់ខ្លួន សមាហរណកម្ម និងការយល់ដឹងពីសង្គម។ ជាផ្នែកមួយនៃការវាយតម្លៃ អ្នកអប់រំផ្តល់ឱ្យអ្នកសិក្សានូវយោបល់ត្រឡប់ពិស្តារ ដែលនឹងដឹកនាំកិច្ចខិតខំប្រឹងប្រែងរបស់គេទៅរកភាពល្អប្រសើរ។ ឱកាសសម្រាប់ស្វ័យវង្វាយតម្លៃ ទិន្នានុប្បវត្តិឆ្លុះបញ្ចាំង និងសំណុំនៃការសិក្សា ក៏ដូចជាយោបល់ត្រឡប់ពីមិត្តភក្តិ ក៏ត្រូវបានជម្រុញផងដែរនៅក្នុងដំណើរការនៃការវាយតម្លៃ។

បញ្ហាផ្សេងៗទៀតសម្រាប់ពិចារណា នៅក្នុងការវាយតម្លៃលទ្ធផលសិក្សានៃការអប់រំភាពជាពលរដ្ឋសកល រួមមានដំណើរការទាំងឡាយ (ឧទាហរណ៍ ៖ ការអនុវត្តការបង្រៀននិងការរៀន និងការចូលរួមរបស់អ្នកសិក្សា) និងលទ្ធផល (ឧទាហរណ៍ ៖ ចំណេះដឹងបុគ្គលនិងក្រុម ជំនាញ តម្លៃ ឥរិយាបថ និងសមិទ្ធិផល) ក៏ដូចជាបញ្ហាបរិបទ (ឧទហរណ៍ ៖ ឯកសារកម្មវិធីសិក្សា គោលនយោបាយរបស់ស្ថាប័ន សមត្ថភាពក្នុងការបង្រៀន ការប្តេជ្ញាចិត្តនិងនិងការគាំទ្រផ្នែករដ្ឋបាល ធនធាន បរិស្ថាននៃការសិក្សា និងទំនាក់ទំនងសហគមន៍)។ នៅក្នុងដំណើរ

ការនៃការធ្វើផែនការ បញ្ហាស្តីអំពីសុពលភាព ភាពអាចជឿទុកចិត្តបាន និងយុត្តិធម៌ ត្រូវតែពិចារណានៅក្នុងការតាក់តែងនិងការអនុវត្តការវាយតម្លៃ។

ទោះបីជាមិនទាន់មានសុញ្ញនករឯកភាពជាសកល សម្រាប់ការគ្រប់គ្រងលទ្ធផលសិក្សានៃការអប់រំភាពជាពលរដ្ឋសកលក៏ដោយ វាត្រូវបានគេរំពឹងថា ក្របខណ្ឌវាស់ស្ទង់ដែលត្រូវបានស្នើឡើងមួយ និងសុញ្ញនករសក្តានុពល នឹងមាននៅក្នុងពេលឆាប់ៗនេះ។ ការស្ទង់មតិជាច្រើនត្រូវបានធ្វើឡើង ដែលមានបំណងវាយតម្លៃលទ្ធផលនៃការអប់រំភាពជាពលរដ្ឋសកល នៅក្នុងបរិបទផ្សេងៗគ្នា (សូមមើលឧបសម្ព័ន្ធទី១) ខណៈពេលអ្នកពាក់ព័ន្ធផ្សេងៗទៀតកំពុងតែខិតខំប្រឹងប្រែង ជាពិសេសទាក់ទងទៅនឹងសំណើរនៅក្នុងដាក់បញ្ចូលការអប់រំភាពជាពលរដ្ឋសកល ជាមួយគ្នានឹងការអប់រំសម្រាប់ការអភិវឌ្ឍជានិរន្ត ជាគោលដៅមួយនៃគោលដៅអប់រំ នៅក្នុងរបៀបវារៈអភិវឌ្ឍក្រោយឆ្នាំ២០១៥។ អង្គការយូណេស្កូកំពុងរួមចំណែកនៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ដោយបានបង្កើតបេសកកម្មស្រាវជ្រាវ ដែលនឹងអាចត្រូវបានប្រើប្រាស់ សម្រាប់អភិវឌ្ឍសំណើរដែលផ្អែកលើភស្តុតាង ទៅលើសុញ្ញនករសក្តានុពល និងការពិចារណាសម្រាប់ការប្រមូលទិន្នន័យ។

| ឧទាហរណ៍នៅក្នុងប្រទេស |
| --- |
| ដំណើរការនៃការវាយតម្លៃ ត្រូវបានធ្វើឡើងដោយអង្គការផែនការអន្តរជាតិ និងមជ្ឈមណ្ឌលស្រាវជ្រាវយុវជននៃសកលវិទ្យាល័យម៉ែលប៊ន សម្រាប់កម្មវិធីការអប់រំភាពជាពលរដ្ឋសកលនៅក្នុងប្រទេសអូស្រ្តាលីនិងប្រទេសឥណ្ឌូនេស៊ី។ កម្មវិធីនេះតភ្ជាប់ក្រុមសិស្សនៅក្នុងសាលារៀនក្នុងប្រទេសអូស្រ្តាលី ជាមួយសិស្សនៅក្នុងសហគមន៍ក្នុងប្រទេសឥណ្ឌូនេស៊ី ដើម្បីជំរុញការយល់ដឹងអំពីរបៀបដែលបញ្ហា ដែលមនុស្សវ័យក្មេងប្រឈមនៅក្នុងសហគមន៍របស់ខ្លួន ទាក់ទងទៅនឹងបញ្ហាសកលទូលំទូលាយជាងមួយ។ ការស្រាវជ្រាវដែលត្រូវបានធ្វើឡើងនៅរវាងឆ្នាំ២០០៨និងឆ្នាំ២០១១ ដើម្បីវាយតម្លៃលទ្ធផលនៃកម្មវិធីនេះ បានរកឃើញការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសម្បជញ្ញៈនិងការយល់ដឹង ស្តីអំពីបញ្ហាសកល និងការអភិវឌ្ឍជំនាញ។ ដោយជាក់លាក់ ក្រុមអ្នកស្រាវជ្រាវបានរកឃើញថា អ្នកចូលរួមដែលអាចចូលរួមនៅក្នុងរយៈពេលវែង អាចកំណត់វត្ថុបំណងនៃការសិក្សាធំធេងជាង និងពិចារណាតួនាទីរបស់ខ្លួននៅក្នុងពិភពលោក នៅក្នុងន័យនៃការផ្លាស់ប្តូរប្រកបដោយខ្លឹមសារ។ |

**មជ្ឈមណ្ឌលសិក្សាអន្តរជាតិសម្រាប់ការសិក្សាពីពលរដ្ឋវិជ្ជានិងការអប់រំភាពជាពលរដ្ឋ** (ICCS) ដែលត្រួតពិនិត្យដោយសមាគមអន្តរជាតិសម្រាប់ការវាយតម្លៃសមិទ្ធិផលនៃការអប់រំ (IEA) វាយតម្លៃសមិទ្ធិផលរបស់សិស្ស នៅក្នុងការធ្វើតេស្តទៅលើចំណេះដឹង និងការយល់ដឹងអំពីទស្សន ក៏ដូចជាអត្តចរិតនិងឥរិយាបថរបស់សិស្ស ទាក់ទងទៅនឹងពលរដ្ឋវិជ្ជានិងភាពជាពលរដ្ឋ។ កម្រងសំណួរសម្រាប់គ្រូបង្រៀននិងសាលា ប្រមូលព័ត៌មានអំពីបរិបទទាំងឡាយ ដែលសិស្សរៀនអំពីពលរដ្ឋវិជ្ជានិងភាពជាពលរដ្ឋ ដែលរួមទាំងការអនុវត្តការបង្រៀន និងការគ្រប់គ្រងថ្នាក់រៀន អភិបាលកិច្ចសាលា និងអាកាសធាតុ។ នៅក្នុងឆ្នាំ២០០៩ អង្គការ ICCS បានវាយតម្លៃទៅលើសិស្ស ដែលបានចុះឈ្មោះចូលរៀនថ្នាក់ទី៨ (មានន័យថាអាយុ១៣,៥ឆ្នាំ)។ របាយការណ៍ដែលនឹងមកដល់នៅឆ្នាំ២០១៦របស់អង្គការ ICCS និងវាយការទៅលើចំណេះដឹងនិងការយល់ដឹងរបស់សិស្សទៅលើទស្សនាទាន និងប្រធានបទទាំងឡាយដែលទាក់ទងទៅនឹងពលរដ្ឋវិជ្ជានិងភាពជាពលរដ្ឋ ក៏ដូចជាជំនឿ ឥរិយាបថ និងអាកប្បកិរិយារបស់ពួកគេ។

បន្ថែមពីលើការវាយតម្លៃលទ្ធផលសិក្សា **ការត្រួតពិនិត្យនិងការវាយតម្លៃបន្តទៅលើគុណភាពនៃកម្មវិធីការអប់រំភាពជាពលរដ្ឋសកល** ក៏មានសារៈសំខាន់ផងដែរ និងអាចត្រូវបានធ្វើឡើងទៅតាមវិធីផ្សេងៗ។ កិច្ចការនេះអាចត្រូវបានធ្វើ ដោយពិចារណាទៅលើទិដ្ឋភាពផ្សេងៗនៃកម្មវិធី (ឧទាហរណ៍ ការរំពឹងទុកនៃការសិក្សា ធនធាន សមត្ថភាពបង្រៀន និងបរិស្ថាននៃការសិក្សា) ដំណើរការ (ឧទាហរណ៍ ការអនុវត្តការបង្រៀន ធនធានសម្រាប់ការសិក្សា ការចូលរួមរបស់អ្នកសិក្សា) លទ្ធផល (ឧទាហរណ៍ ចំណេះដឹង ជំនាញ តម្លៃ និងឥរិយាបថ ប្រសិទ្ធភាពនៃការផ្លាស់ប្តូរ និងការពិចារណាទៅលើបរិបទ)។

ការវាយតម្លៃប្រកបដោយប្រសិទ្ធភាព នៃកម្មវិធីការអប់រំភាពជាពលរដ្ឋសកល គួរត្រូវបានបញ្ចូលទៅក្នុងការវាយតម្លៃទាំងឡាយ ដែលមាននាពេលបច្ចុប្បន្នតាមតែអាចធ្វើទៅបាន និងតម្រូវឱ្យមានការយកចិត្តទុកដាក់ប្រកបដោយការប្រុងប្រយ័ត្ន ទៅលើកត្តាជាច្រើន។ គោលបំណងនិងសុញ្ញនករនៃការវាយតម្លៃ (ឧទាហរណ៍ ឋានៈ ការសម្របស្រួល និងលទ្ធផល) ត្រូវតែកំណត់និយមឱ្យបានច្បាស់ ធម្មជាតិនៃចំនួននៃការបង្រៀននិងការរៀននិងបរិបទ

ត្រូវតែពិចារណា និងប្រភេទព័ត៌មានដែលចាត់ទុកថាជាភស្តុតាងដែលអាចទទួលយកបាន និងវិធីសាស្ត្រនៃការប្រមូលទិន្នន័យ ត្រូវតែកំណត់។ សមាសធាតុផ្សេងទៀត ត្រូវតែពិចារណាឱ្យបានល្អិតល្អន់ ជាផ្នែកមួយនៃយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយជាងមួយ ដែលរួមទាំងឯកសារកម្មវិធីសិក្សាផ្លូវការ កម្មវិធីនិងគោលនយោបាយស្ថាប័ន បរិស្ថាននិងទំនាក់ទំនងនៃការអប់រំ ទំនាក់ទំនងសហគមន៍ ការសិក្សាប្រកបដោយវិជ្ជាជីវៈ និងការការប្តេជ្ញាចិត្តនិងការគាំទ្រផ្នែករដ្ឋបាល។ ការពិចារណាផ្សេងៗទៀត (ឧទាហរណ៍ វិសាលភាព ភាពទាក់ទង សន្និយោគ និរន្តរភាព) ក៏ត្រូវការការយកចិត្តទុកដាក់បន្ត នៅក្នុងកម្មវិធីវាយតម្លៃ។

លទ្ធផលនៃការវាយតម្លៃកម្មវិធី អាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងផ្សេងៗជាច្រើនដូចជា ឧទាហរណ៍ កំណត់ព្រំដែននៃកម្មវិធី កំណត់គោលដៅទិដ្ឋភាពជាក់លាក់សម្រាប់ការកែលម្អ រាយការអំពីនិន្នាការនិងលទ្ធផលនៅមូលដ្ឋាន ជាតិ និងអន្តរជាតិ វាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី និងលើកកម្ពស់គណនេយ្យភាពនិងតម្លាភាព។ ទិន្នន័យត្រូវផ្តល់ព័ត៌មានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តអំពីវិថីឆ្ពោះទៅមុខ និងដើម្បីធ្វើឱ្យប្រសើរឡើងនិងរក្សាការសិក្សា។ វប្បធម៌ដែលមានទំនោរទៅរកការសិក្សាបែបនេះ កំណត់និយមន័យនៃជោគជ័យថាជាភាពល្អប្រសើរ និងចាត់ទុកការខុសឆ្គងទាំងឡាយ ថាជាផ្នែកធម្មតាមួយនៃដំណើរការកែលម្អការបង្រៀននិងការរៀន៕